**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តគ្រប់គ្រង លើវិស័យសំណង់នៅកម្ពុជា
## (ពីឆ្នាំ១៩៩៤-បច្ចុប្បន្ន)

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **ចឿន វណ្ណឌេត**
កញ្ញា **ឆាង សុមារនី**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១៣

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **មឿន វណ្ណរដេត** និងនាងខ្ញុំ **ឆាង សុមារនី** ជានិស្សិតបរិញ្ញាបត្រ រដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០២០ សូមធ្វើការសម្តែងនូវមនោសញ្ចេតនាប្រកបដោយកត្តញ្ញុតាធម៌ និងគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

ជាបឋម យើងខ្ញុំ សូមប្រណម្យអញ្ជលីដាក់សិរសា លំឱនកាយ វាចា ចិត្ត អភិវន្ទនាការ គោរពដល់:

- **លោកពុក មឿន វណ្ណៈ**
- **អ្នកម៉ែ ខួន លាបឃាង**
- **ក្រុមគ្រួសារបងប្រុស ជុង សុខចេង**
- **បងប្រុសទាំងពីរ**
- **លោកពុក ទេង សំអាត**
- **អ្នកម៉ែ ឆង ធារី**
- **លោកតា ឆង អាង**
- **លោកយាយ ឡោ សាវ៉ាត**

ដែលបានផ្តល់នូវកំណើត ដំបូន្មាន ភាពកក់ក្តៅ ការមើលថែ តាំងពីតូចរហូតមក ព្រមទាំងផ្តល់នូវឱកាសឱ្យយើងខ្ញុំបានសិក្សារៀនសូត្រ ព្រមទាំងឧបត្ថម្ភគាំទ្រទាំងផ្នែកថវិកា និងផ្នែកប្រាជ្ញាស្មារតី ដោយធ្វើការលើកទឹកចិត្ត ជំរុញ និងបណ្តុះនូវស្មារតី ខិតខំ ប្រឹងប្រែង សង្វាត ឧិហាត ក្នុងការសិក្សារៀនសូត្រ ក្នុងបេសកកម្មក្រេបជញ្ជក់នូវចំណេះដឹង ពង្រឹងនូវពុទ្ធិ តាំងពីកម្រិតមត្តេយ្យសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សានេះ ។

**ឯកឧត្តមបណ្ឌិត លុយ ចន្ថា សាកលវិទ្យាធិការ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលសិក្សារៀនសូត្រនៅសាកលវិទ្យាល័យនេះ នឹងផ្តល់នូវភាពកក់ក្តៅ ទំនុកចិត្ត ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការរៀនសូត្រ នៅកម្រិតឧត្តមសិក្សានេះ ។

**លោកស្រីសាស្ត្រាចារ្យ ម៉ូលី បញ្ញា** ដែលជាសាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតឱកាសដ៏មមាញឹក ព្រមទាំងចំណាយពេលវេលាដ៏មានតម្លៃផ្ទាល់ខ្លួន ដើម្បីបង្ហាត់បង្ហាញ ណែនាំ ជាពិសេសផ្តល់នូវការលើកទឹកចិត្ត រួមជាមួយនិងឯកសារមួយចំនួនមកដល់យើងខ្ញុំ ក្នុងការសម្រួលដល់ដំណើរការរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង ។

**សាកលវិទ្យាធិការ ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សា** គ្រប់រូបនៃសាកលវិទ្យាភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានធ្វើការខិតខំប្រឹងប្រែងក្នុងការផ្ទេរនូវពុទ្ធិ ចំណេះដឹង ព្រមទាំងបង្កនូវភាពងាយស្រួល និងភាពកក់ក្តៅក្នុងដំណើរការសិក្សានេះផងដែរ ។

ជាទីបញ្ចប់យើងខ្ញុំ សូមគោរពប្រសិទ្ធពរបវរសួស្តីជូនដល់ **លោកពុក អ្នកម្តាយ ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សា** ទាំងអស់ភប់ប្រសព្វតែសេចក្តីសុខ សេចក្តីចម្រើន និងជោគជ័យគ្រប់ភារកិច្ចការងារ ។

# អារម្ភកថា

ក្រោយរលត់ទៅនៃសង្គ្រាមស៊ីវិលនៅកម្ពុជា ពន្លកត្រួយនៃការអភិវឌ្ឍចាប់ផ្តើមលូតលាស់ដុះដាលរីកត្រសុំត្រសាយ និងចាក់ឫសយ៉ាងរឹងមាំ ។ រហូតមកដល់បច្ចុប្បន្ននេះ ពន្លកនៃការអភិវឌ្ឍដែលបានធ្វើការខិតខំប្រឹងប្រែងថែទាំ និងរក្សាកាលគ្រាកន្លងនោះ បាននឹងកំពុងផ្តល់ភោគផលជាផ្លែផ្កាគួរជាទីពេញចិត្ត ។ ប្រសិនបើយើងក្រឡេកមើលពីវឌ្ឍនភាពនៃការអភិវឌ្ឍវិញ ឃើញថាសន្ទុះនៃការអភិវឌ្ឍនៅកម្ពុជា មានការរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័ស ។ ដោយឡែកវិស័យសំណង់ឯណោះវិញ ក៏មានសន្ទុះហក់ឡើងយ៉ាងគំហុកដោយកំណើនអគារប្រណិតៗ ខ្ពស់ទាប ជាច្រើនមានការលូតលាស់ជាបន្តបន្ទាប់ជាប់គ្នាយ៉ាងរដឹក ។ មួយវិញទៀតដោយកម្រិតជីវភាពប្រជាពលរដ្ឋកាន់តែល្អប្រសើរផងនោះ ការណ៍នេះធ្វើឱ្យសំណង់បុរី លំនៅឋាន និងអគារខុនដូ អាផាតមិន បាននឹងកំពុងរីកដុះដាលមីរដេរដាស ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំ ។

ដោយក្រឡេកឃើញនូវភាពវិជ្ជមានរបស់វិស័យសំណង់ មានអត្រាកើនឡើងឥតថមថយនេះ ជាពិសេសដើម្បីជាឧត្តមប្រយោជន៍ ដល់សាធារណជន វិនិយោគិន អ្នកអភិវឌ្ឍ ដែលមានទំនាក់ទំនាក់ទំនងទៅនឹងវិស័យសំណង់នេះ ក៏ដូចជាសាធារណជនទូទៅ អ្នកស្រាវជ្រាវ ជាពិសេសបងប្អូន មិត្ត និស្សិត បានស្វែងយល់ ពីវិស័យច្បាប់ក្នុងការគ្រប់គ្រងលើវិស័យនេះ ទើបក្រុមយើងខ្ញុំធ្វើការស្រាវជ្រាវនូវប្រធានបទពាក់ព័ន្ធនឹង " **របបគតិយុត្តគ្រប់គ្រងលើវិស័យសំណង់** " ដែលធ្វើការសិក្សាពីឆ្នាំ១៩៩៤ រហូតដល់បច្ចុប្បន្ន ។ វិស័យសំណង់នេះដែរ កំពុងតែទទួលបាននូវការចាប់អារម្មណ៍យ៉ាងខ្លាំង ពីសំណាក់ប្រជាពលរដ្ឋ អ្នកវិនិយោគ អ្នកអភិវឌ្ឍ ជាពិសេសរាជរដ្ឋាភិបាលដែលលោកបានយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងយ៉ាងខ្លាំង ព្រមទាំងបានខិតខំបង្កើតច្បាប់ អនុក្រឹត្យ ឬបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសុខដុមនីយកម្ម ដល់គ្រប់ភាគីដែលជាប់ទាក់ទងនឹងវិស័យសំណង់ ។

តាមរយៈអត្ថបទនៃការស្រាវជ្រាវ ការចងក្រងជាសារណានេះ យើងខ្ញុំសង្ឃឹម និងជឿជាក់ថាអាចជាគតិដល់សាធារណជនទូទៅ អ្នកវិនិយោគ អ្នកអភិវឌ្ឍ អ្នកបច្ចេកទេស ឬសាធារណជនដែលធ្វើការទាក់ទងទៅនឹងវិស័យសំណង់ ជាពិសេសសម្រាប់បងប្អូន មិត្តនិស្សិតគ្រប់ជំនាន់ រួមនឹងគ្រប់ភាគីទាំងអស់ ដែលមានបំណងចង់ស្វែងយល់ សិក្សាស្រាវជ្រាវ ដើម្បីទុកជាទុកជំនួយដល់ការដោះស្រាយនូវរាល់ចម្ងល់ដែលទាក់ទងនឹងវិស័យគ្រប់គ្រងសំណង់ ។

ជាទីអវសានកថា យើងខ្ញុំសូមគោរពជូនពរដល់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បងប្អូនមិត្តនិស្សិតគ្រប់ជំនាន់ ព្រមទាំងសាធារណជនទាំងអស់ ដែលបានអាន និងស្រាវជ្រាវពីសារណាដែលយើងខ្ញុំបានចងក្រងនេះ សូមខន្តី អភ័យទោស និងអធ្យាស្រ័យនូវរាល់កង្វះខាតទាំងឡាយដែលបានកើតមានឡើង ។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំក៏សូមជូនពរសូមឱ្យមានសុខភាពល្អ សំណាងល្អ ជោគជ័យគ្រប់ភារកិច្ចទាំងអស់ ព្រមទាំងសមប្រកបតែនឹងពុទ្ធពរទាំង ៥ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ------------------------------------------------------------------------------------------------- ១

## ជំពូក១

## របបគតិយុត្តនៃការគ្រប់គ្រងសំណង់នៅកម្ពុជា ១៩៩៤-២០០៧

**ផ្នែកទី១៖ វិធាន និងលិខិតបទដ្ឋានគ្រប់គ្រងសំណង់នៅកម្ពុជា** ------------------------------- ៤

**កថាខណ្ឌទី១៖ ខ្លឹមសារនៃលិខិតបទដ្ឋានគ្រប់គ្រងសំណង់នៅកម្ពុជា**----------------------------------- ៤

វាក្យខណ្ឌទី១៖ សុពលភាពនៃអនុក្រឹត្យលេខ៨៦ ស្ដីពីលិខិតអនុញ្ញាតសាងសង់ ------------------- ៤

វាក្យខណ្ឌទី២៖ ខ្លឹមសារនៃច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ----------------- ៥

**កថាខណ្ឌទី២៖ ស្ថាប័នទទួលបន្ទុកគ្រប់គ្រងលើវិស័យសំណង់**------------------------------------------- ៦

វាក្យខណ្ឌទី១៖ ស្ថាប័នរាជរដ្ឋាភិបាល ----------------------------------------------------------------- ៦

វាក្យខណ្ឌទី២៖ សមត្ថកិច្ចរបស់អាជ្ញាធរដែនដី ------------------------------------------------------- ៦

**ផ្នែកទី២៖ វិមជ្ឈការនៃការគ្រប់គ្រងសំណង់**------------------------------------------------------- ៦

**កថាខណ្ឌទី១៖ ការគ្រប់គ្រងការងារសាងសង់** ------------------------------------------------------------ ៧

វាក្យខណ្ឌទី១៖ ការគ្រប់គ្រងអាជ្ញាប័ណ្ណសាងសង់ -------------------------------------------------------៧

ក. ការផ្ដល់អាជ្ញាប័ណ្ណសាងសង់ ------------------------------------------------------------------៧

ក.១ នីតិវិធីស្នើសុំលិខិតអនុញ្ញាតសាងសង់ ---------------------------------------------------៧

ក.២ សុពលភាពនៃលិខិតអនុញ្ញាតសាងសង់------------------------------------------------- ៩

ខ. ប្រភេទសំណង់ដែលចាំបាច់ត្រូវសុំលិខិតអនុញ្ញាតសាងសង់-------------------------------- ៩

គ. ប្រភេទសំណង់ដែលពុំចំណុះឱ្យលិខិតអនុញ្ញាតសាងសង់ --------------------------------- ១០

វាក្យខណ្ឌទី២៖ ការគ្រប់គ្រងការដ្ឋានសំណង់ ----------------------------------------------------- ១០

ក. លិខិតបើកការដ្ឋានសំណង់--------------------------------------------------------------------- ១០

ខ. ការទទួលខុសត្រូវការដ្ឋានសំណង់---------------------------------------------------------------- ១១

គ. លិខិតបិទការដ្ឋានសំណង់ ----------------------------------------------------------------------១៣

វាក្យខណ្ឌទី៣៖ ការគ្រប់គ្រងក្រុមជាងសំណង់ ---------------------------------------------------១៣

**កថាខណ្ឌទី២៖ ការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់នៃសំណង់** ------------------ ១៥

វាក្យខណ្ឌទី១៖ ប្រភេទ នៃសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ --------------------------- ១៥

វាក្យខណ្ឌទី២៖ ទម្រង់បែបបទស្នើសុំប្រកបអាជីវកម្ម និងការចុះបញ្ជី ------------------------------ ១៨
ក. ការស្នើសុំប្រកបអាជីវកម្ម------------------------------------------------------------------------ ១៨
ខ. ការចុះបញ្ជីអាជីវកម្ម---------------------------------------------------------------------------- ១៩


**ជំពូក២**

**របបគតិយុត្តនៃការគ្រប់គ្រងសំណង់នៅកម្ពុជា ២០០៨-បច្ចុប្បន្ន**


**ផ្នែកទី១៖ វិធាន ឬលិខិតបទដ្ឋាន និងស្ថាប័នទទួលបន្ទុកគ្រប់គ្រងសំណង់នៅកម្ពុជា**-----២១
**កថាខណ្ឌទី១៖ ខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រងលើវិស័យសំណង់** -----------------------២១
**កថាខណ្ឌទី២៖ ស្ថាប័នគ្រប់គ្រងលើវិស័យសំណង់** ---------------------------------------------------២២
វាក្យខណ្ឌទី១៖ ក្រសួងរៀបចំដែនដី នគរូបនីយម្ម និងសំណង់ ------------------------------------២២
ក. អគ្គនាយកដ្ឋានសំណង់ ------------------------------------------------------------------------២៣
ខ. មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានី-ខេត្ត------------------------------២៥
គ. ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក-ខណ្ឌ------------២៦
វាក្យខណ្ឌទី២៖ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត---------------------------------------------------------២៦
ក. ក្រសួងបរិស្ថាន-------------------------------------------------------------------------------២៧
ខ. ក្រសួងសាធារណការ និងដឹកជញ្ជូន--------------------------------------------------------២៨
គ. អាជ្ញាធរដែនដីៈ សាលារាជធានីភ្នំពេញ-----------------------------------------------------២៨
**ផ្នែកទី២៖ បច្ចុប្បន្នភាពនៃការគ្រប់គ្រងលើវិស័យសំណង់** ---------------------------------------៣១
**កថាខណ្ឌទី១៖ ការគ្រប់គ្រងលក្ខណៈបច្ចេកទេសសំណង់** -------------------------------------------៣១
វាក្យខណ្ឌទី១៖ ការគ្រប់គ្រងអ្នកវិជ្ជាជីវៈ និងអ្នកផ្គត់ផ្គង់សម្ភារសំណង់----------------------------៣១
វាក្យខណ្ឌទី២៖ ការគ្រប់គ្រងការប្រើប្រាស់សំណង់--------------------------------------------- ៣៣
ក. សំណង់បេតិកភណ្ឌ------------------------------------------------------------------------- ៣៣
ខ. ការកែប្រែសំណង់ចាស់ ------------------------------------------------------------------- ៣៣
គ. សំណង់ដែលចាស់ទ្រុឌទ្រោម ---------------------------------------------------------------៣៤
**កថាខណ្ឌទី២៖ ការគ្រប់គ្រងទៅតាមប្រភេទផ្សេងៗនៃសំណង់** ---------------------------------------៣៤
វាក្យខណ្ឌទី១៖ ការគ្រប់គ្រងប្រភេទលំនៅឋាន ផ្ទះល្វែង ភូមិគ្រឹះ ---------------------------------៣៤
វាក្យខណ្ឌទី២៖ ការគ្រប់គ្រងបុរី និងទីក្រុងរណប ----------------------------------------------៣៥
ក. ការគ្រប់គ្រងបុរី ---------------------------------------------------------------------------៣៦

ខ. ទីក្រុងរណប ---------------------------------------------------------------------------------- ៣៧
វាក្យខណ្ឌទី៣. ការគ្រប់គ្រងអគារសហកម្មសិទ្ធិ ---------------------------------------------------៣៩
**កថាខណ្ឌទី៣៖ ការធ្វើអធិការកិច្ចសំណង់** ------------------------------------------------------------ ៤១
វាក្យខណ្ឌទី១៖ នីតិវិធីនៃការធ្វើអធិការកិច្ច------------------------------------------------------------ ៤១
វាក្យខណ្ឌទី២៖ មន្ត្រីអធិការកិច្ច និងសមត្ថកិច្ច ----------------------------------------------------- ៤៤
ក. មន្ត្រីអធិការកិច្ច-------------------------------------------------------------------------------- ៤៤
ខ. សមត្ថកិច្ច ------------------------------------------------------------------------------------ ៤៥

**ជំពូក៣**

**របបនៃការគ្រប់គ្រងការដោះស្រាយវិវាទលើវិស័យសំណង់**

**ផ្នែកទី១៖ នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** -------------------------------------- ៤៦
កថាខណ្ឌទី១៖ ការចរចា --------------------------------------------------------------------------------៤៧
កថាខណ្ឌទី១៖ សន្ទានកម្ម ----------------------------------------------------------------------------៤៧
**ផ្នែកទី២. នីតិវិធីដោះស្រាយវិវាទតាមរយៈស្ថាប័នតុលាការ** --------------------------------- ៤៨
កថាខណ្ឌទី១៖ បណ្តឹងរដ្ឋប្បវេណី ---------------------------------------------------------------------- ៤៨
កថាខណ្ឌទី២៖ បណ្តឹងព្រហ្មទណ្ឌ --------------------------------------------------------------------- ៥០
**សេចក្តីសន្និដ្ឋាន** ------------------------------------------------------------------------------------ ៥១
**អនុសាសន៍** ----------------------------------------------------------------------------------------- ៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ក្រោយពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ និងចិត្តដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធជាតិលើគ្រប់វិស័យ គឺសង្គ្រោះប្រជាពលរដ្ឋឱ្យរួចចាកផុតពីសេចក្តីភ័យខ្លាចដោយសារសង្គ្រាមរ៉ាំរ៉ៃជាច្រើនទសវត្ស និងសេចក្តីស្រេកឃ្លាន ការកាត់បន្ថយភាពក្រីក្រ ដោយសារតែគិតអំពីអាទិភាពសេដ្ឋកិច្ចរបស់ប្រជាជនជាធំនេះហើយ ទើបរាជរដ្ឋាភិបាលហាក់ដូចជាមិនសូវចាប់អារម្មណ៍លើវិស័យសំណង់ ជាពិសេសគឺការគ្រប់គ្រងលើវិស័យសំណង់នៅកម្ពុជា ។ ប៉ុន្តែជាក់ស្តែង ចាប់តាំងពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន វិស័យសំណង់នៅកម្ពុជាហាក់មានសន្ទុះកើនឡើងហួសការរំពឹងទុកពីមួយឆ្នាំទៅមួយឆ្នាំ ។ បើយើងក្រឡេកទៅមើលរាជធានីភ្នំពេញ និងខេត្តព្រះសីហនុវិញ យើងនឹងសង្កេតឃើញថាវត្តមាននៃអគារខ្ពស់ៗបានបង្ហាញ និងបង្អួតរាងគ្នាគួរជាទីចាប់អារម្មណ៍ ។ ដោយយោងទៅតាមទិន្នន័យរបាយការណ៍របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានឱ្យដឹងថាគិតមកត្រឹមរយៈពេល៥ខែដើមឆ្នាំ២០២០នេះ ទិន្នន័យសំណង់ទូទាំងប្រទេសមានចំនួនសរុប ៤៦០គម្រោង ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន ១ ០០៧ ១៨០ ម៉ែត្រការេ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ ៤៣៣ ១៨២ ១៧៩ ដុល្លារ បើធៀបនឹង ខែឧសភា ឆ្នាំ២០១៩ មានចំនួន ២៧៨ គម្រោង មានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន ៣០០ ៤៣៣ ម៉ែត្រការេ ដែលប៉ាន់ស្មានទុនវិនិយោគប្រមាណ ១៥២ ១៥០ ៧៨៩ ដុល្លារ កើនឡើង ១៨៤,៧១% ។[1]

ប្រាកដហើយស្របពេលជាមួយនៃអត្រាកំណើនដ៏ល្អប្រសើរនេះផងដែរ បណ្តាលិខិតបទដ្ឋានគតិយុត្តដែលមានទាក់ទិនទៅនឹងការគ្រប់គ្រងសំណង់ត្រូវបានយកចិត្តទុកដាក់ ធ្វើវិសោធនកម្ម និងតាក់តែងបន្ថែមដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍវិស័យសំណង់នៅកម្ពុជា ។ របបគតិយុត្ត គឺជាវិធានដែលបង្កើតឡើងក្នុងគោលដៅដើម្បីគ្រប់គ្រងសម្របសម្រួល ក៏ដូចជាធានានូវភាពត្រឹមត្រូវ និងស្របច្បាប់នៃការសាងសង់សំណង់អគារ ព្រមជាមួយនឹងការទទួលខុសត្រូវនៃអ្នកសាងសង់ និងអ្នកប្រើប្រាស់ដូចគ្នាដែរ ។ បើយើងនិយាយត្រង់ចំណុចនេះប្រាដកជាយើងនឹងមានចម្ងល់មួយថា ស្របពេលជាមួយកំណើនជាលំដាប់នេះ តើរបបគតិយុត្តគ្រប់គ្រងវិស័យសំណង់មានខ្លឹមសារយ៉ាងដូចម្តេច? ហើយមានប្រសិទ្ធិភាពយ៉ាងណាដែរ? ជាងនេះទៅទៀតនោះ ទន្ទឹមនឹងតម្រូវការនៃវិធានច្បាប់នោះ អ្នកជំនាញ អ្នកបច្ចេកទេស ក៏ដូចជាអ្នកដែលយល់ដឹងខាងវិស័យនេះក៏មានតម្រូវការផងដែរ ប៉ុន្តែបើយើងនិយាយពីចំនួនអ្នកយល់ដឹងពីច្បាប់គ្រប់គ្រងលើវិស័យសំណង់ក៏មិនសូវមានចំនួនច្រើនផងដែរ រីឯសាធារណជនទូទៅក៏ពុំសូវមានចំនួនច្រើន ដែលបានយល់ដឹងច្បាស់ពីច្បាប់ សិទ្ធិកាតព្វកិច្ច ដែលត្រូវ

[1] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០២០ និងលើកទិសដៅការងារបន្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

បំពេញដើម្បីធានាភាពស្របច្បាប់នោះទេ ប៉ុន្តែចំនួនអ្នកបច្ចេកទេសវិញ មានចំនួនសមល្មមនឹងតម្រូវការប៉ុន្តែអ្នកបច្ចេកទេសទាំងនោះ ភាគច្រើនពុំបានធ្វើការចុះបញ្ជី ដើម្បីទទួលបាននូវការការពារនឹងគ្រប់គ្រងដោយច្បាប់ ក៏ដូចជាក្រសួងមានសមត្ថកិច្ចបានគ្រប់គ្នានោះទេ ។

ប៉ុន្តែមុននឹងបកស្រាយពីបញ្ហាទាំងអម្បាលមាននេះ យើងគួរងាកមកចាប់អារម្មណ៍ និងស្វែងយល់អំពីន័យនៃពាក្យសំណង់ជាមុនសិន ដោយសំណង់ ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាទៅតាមសម័យកាល និងបរិបទសង្គមខុសៗគ្នា៖

វចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត**[2] បានកំណត់ពាក្យសំណង់មានថ្នាក់ពាក្យជានាម មានន័យថាគឺជាការសង់ ការកសាង ការប្រជុំផ្គុំគ្រឿងសម្ភារៈធ្វើឱ្យកើតបានជាលំនៅដ្ឋាន, គ្រឹះស្ថាន, ប្រាសាទ ឬស្ថានជាដើមដែលគេបានសង់រួចហើយ ។

ដោយឡែកសន្ធានុក្រមនៃច្បាប់សំណង់ក៏បានកំណត់និយមន័យនៃពាក្យសំណង់ផងដែរ សំណង់ន័យថា ជាដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ ។[3]

ដោយសារតែមូលហេតុនេះហើយ ទើបយើងខ្ញុំទាំងពីរនាក់ក្នុងនាមជានិស្សិតផ្នែករដ្ឋបាលសាធារណៈដែលត្រៀមខ្លួននឹងបញ្ចប់ការសិក្សានាពេលខាងមុខនេះ ដោយទទួលបានការណែនាំ ជ្រោមជ្រែង និងចង្អុលបង្ហាញពីសំណាក់សាស្ត្រាចារ្យណែនាំរបស់យើងខ្ញុំផងនោះ ទើបយើងខ្ញុំបានស្រាវជ្រាវនូវប្រធានបទ "របបគតិយុត្តគ្រប់គ្រងលើវិស័យសំណង់នៅកម្ពុជា (សិក្សាពីឆ្នាំ១៩៩៤រហូតមកដល់បច្ចុប្បន្ន)" នេះដើម្បីជាប្រយោជន៍សម្រាប់អ្នកដែលមានបំណងស្វែងយល់ពីរបបគតិយុត្តសម្រាប់បម្រើឱ្យការគ្រប់គ្រងលើវិស័យនេះ បានដឹង បានស្វែងយល់ ។

ចាប់ពីឆ្នាំ១៩៩៤រហូតមកដល់បច្ចុប្បន្ននេះ មានរយៈពេលជាងម្ភៃឆ្នាំទៅហើយក្តី ក៏នៅតែមានសាធារណៈជនយើងមួយចំនួនធំ លោកនៅតែមិនបានយល់ដឹងពីវិធានច្បាប់ដែលមានវិសាលភាពទៅលើការសាងសងដដែល ។ បើទោះបីជាយ៉ាងនេះក៏ហើយចុះ ដោយវិស័យបច្ចេកវិទ្យាមានការរីកចម្រើន ហើយកាលពីថ្មីៗកន្លងទៅនេះផងដែរ រាជរដ្ឋាភិបាលដោយសម្លឹងឃើញពីភាពរីដ្ឋមាននៃវិស័យសំណង់នៅកម្ពុជានោះ បានអនុម័តនូវច្បាប់សំណង់ ដែលបានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលធ្វើឱ្យសាធារណៈបានយល់ដឹង នឹងបានស្វែងយល់ខ្លះពីវិស័យនេះ ក៏ដូចជារបបគតិយុត្តដែលទាក់ទង និងគ្រប់គ្រងទៅលើវិស័យ

---

[2] វចនានុក្រមខ្មែរ នៃសម្តេចព្រះសង្ឃរាជ **ជួន ណាត** ភាគ១ ភាគ២ បោះពុម្ពឆ្នាំ១៩៦៧

[3] សន្ធានុក្រមច្បាប់សំណង់ ឆ្នាំ២០១៩

នេះផងដែរ ។ ហើយអ្វីដែលជាចម្ងល់ដែលបានលើកឡើងនៅក្នុងប្រធានបទនេះគឺ តើរយៈពេលជាងម្ភៃឆ្នាំកន្លងទៅនេះតើមានរបបគតិយុត្តអ្វីខ្លះដែលបម្រើឱ្យការគ្រប់គ្រងវិស័យសំណង់? និងមានស្ថាប័នពាក់ព័ន្ធណាខ្លះទទួលបន្ទុកគ្រប់គ្រងលើវិស័យសំណង់? ហើយគ្រប់គ្រងទៅលើផ្នែកណាខ្លះ? នឹងក្នុងករណីមានវិវាទកើតមានជុំវិញវិស័យសំណង់ តើបុគ្គលអាចស្វែងរកដំណោះស្រាយតាមនីតិវិធីណាខ្លះ?

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីបង្ហាញអំពីខ្លឹមសារលំអិតនៃវិធានច្បាប់គោលធំៗដែលមានតួនាទីបម្រើឱ្យការគ្រប់គ្រងលើវិស័យសំណង់ ដែលអ្នកស្រាវជ្រាវ សាធារណជនទូទៅ ជាពិសេសអ្នកអភិវឌ្ឍដែលមានបំណងចង់ធ្វើការវិនិយោគខាងវិស័យសំណង់ អចលនទ្រព្យ ជាប្រភេទបុរីខុនដូ...មិនតែប៉ុណ្ណោះម្ចាស់កម្មសិទ្ធិករនៃអគារ មិនថាជាបុរី ភូមិគ្រឹះ ផ្ទះល្វែង ឬលំនៅឋានគ្រប់ប្រភេទចាំបាច់ត្រូវតែយល់ដឹងពី សិទ្ធិ និងកាតព្វកិច្ចដែលចាំបាច់ត្រូវតែបំពេញដោយខានពុំបាន ។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវមួយនេះក៏មានគោលបំណងសម្រាប់ជាប្រទីប បំភ្លឺផ្លូវដល់បងប្អូន មិត្តនិស្សិត ឬអ្នកសិក្សារៀនសូត្រក្រោយៗបានស្វែងយល់ និងពង្រីកនូវពុទ្ធិ ឱ្យកាន់តែដុះដាលបន្ថែមទៅទៀតពីការគ្រប់គ្រងលើវិស័យសំណង់នេះផងដែរ ព្រមទាំងបំផុសស្មារតីក្នុងការស្រាវជ្រាវ ក៏ដូចជាចងក្រងនូវស្នាដៃថ្មីៗ សម្រាប់ជាទុនដល់អ្នកសិក្សាទាំងអស់ ។

ប្រធានបទនេះគឺធ្វើការសិក្សាចំពោះតែខ្លឹមសារនៃច្បាប់ និងលិខិតបទដ្ឋានមួយចំនួនប៉ុណ្ណោះ ពោលគឺរួមមាន៖ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤ ច្បាប់សំណង់ដែលទើបទទួលបានការអនុម័តពីរាជរដ្ឋាភិបាល អនុក្រឹត្យលេខ៨៦ស្តីពីលិខិតអនុញ្ញាតសាសង់ និងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណង់ ជារួមមក គឺផ្តោតសំខាន់ទៅលើរបបគតិយុត្តគ្រប់គ្រងវិស័យសំណង់នៅកម្ពុជាពីឆ្នាំ១៩៩៤ រហូតដល់ពាក់កណ្តាលឆ្នាំ២០២០។

នៅក្នុងសារណានេះ យើងខ្ញុំបែងចែកនូវរចនាសម្ព័ន្ធនៃការស្រាវជ្រាវជា ៣ជំពូកផ្សេងៗគ្នា រួមមាន៖

ជំពូក១ សិក្សាពីរបបគតិយុត្តនៃការគ្រប់គ្រងសំណង់ពីចន្លោះឆ្នាំ ១៩៩៤ រហូតមកទល់ឆ្នាំ ២០០៧

ជំពូក២ សិក្សាពីរបបគតិយុត្តនៃការគ្រប់គ្រងសំណង់ពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន

ជំពូក៣ សិក្សាពីរបបនៃការគ្រប់គ្រងការដោះស្រាយវិវាទលើវិស័យសំណង់

# ជំពូក១
# របបគតិយុត្តនៃការគ្រប់គ្រងសំណង់នៅកម្ពុជា
# (សិក្សាពីឆ្នាំ១៩៩៤-២០០៧)

## ផ្នែកទី១៖ វិធាន និងលិខិតបទដ្ឋានគ្រប់គ្រងសំណង់នៅកម្ពុជា

### កថាខណ្ឌទី១៖ ខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រងសំណង់នៅកម្ពុជា

#### វាក្យខណ្ឌទី១៖ សុពលភាពនៃអនុក្រឹត្យលេខ៨៦ ស្តីពីលិខិតអនុញ្ញាតសាងសង់

ដើម្បីជាប្រយោជន៍ដល់សង្គម នឹងធានាដល់សុវត្ថិភាពសាធារណៈ និងសុខុមាលភាពនៃសំណង់ ព្រមទាំងការពារសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ និងអាជ្ញាធរសាធារណៈ ក្នុងការសាងសង់សំណង់សាធារណៈ និងសំណង់ឯកជន ។ រាល់រូបវន្តបុគ្គល ឬនីតិបុគ្គល សាធារណៈ ឬឯកជន មានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះត្រូវបានទទួលការការពារដោយច្បាប់ ។

គ្រប់ការសាងសង់ថ្មី កែប្រែ ឬប្តូរទ្រង់ទ្រាយ និងសាងសង់បន្ថែមទាំងអស់ចាំបាច់ត្រូវមានលិខិតអនុញ្ញាតសាងសង់ ដែលលិខិតនេះត្រូវបានផ្តល់ជូនដោយអាជ្ញាធរមានសមត្ថកិច្ចទៅតាមប្រភេទ និងទំហំនៃការសាងសង់ ។ ជាក់ស្តែងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ៨៦ ស្តីពីលិខិតអនុញ្ញាតសាងសង់ ដែលអនុក្រឹត្យនេះមានវិសាលភាពក្នុងការគ្រប់គ្រង និងកំណត់ពីកាតព្វកិច្ច និងករណីយកិច្ចដែលត្រូវបំពេញមុនពេលសាងសង់ ដើម្បីឱ្យសំណង់ដែលបានសង់ក្លាយជាសំណង់ស្របច្បាប់ ។ ដោយឡែកមាត្រា ៣ នៃអនុក្រឹត្យនេះ[4] ក៏បានលើកលែងនូវបណ្តាសំណង់មួយចំនួនដែលពុំតម្រូវឱ្យមានលិខិតសាងសង់នោះទេ ដែលជាកត្តាអំណោយផលមួយដល់ប្រជាពលរដ្ឋ ជាពិសេសប្រជាជនក្រីក្រមានលំនៅដ្ឋានរស់នៅ រាល់សំណង់តូចតាចធ្វើអំពីឈើ ឬស្លឹក រុក្ខជាតិនានា ។

អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ ក៏ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ដែលអនុក្រឹត្យនេះបែងចែកជា៥ជំពូក និង៥០មាត្រា ។ អនុក្រឹត្យនេះចុះហត្ថលេខាដោយសហនាយករដ្ឋមន្ត្រី ព្រមទាំងកំណត់ពីនីតិវិធី និងដំណើរការនៃការស្នើសុំ និងការផ្តល់ជូនលិខិតអនុញ្ញាតសាងសង់ ។ ពិសេសនោះគឺអនុក្រឹត្យនេះជាមូលដ្ឋាននៃការគ្រប់គ្រងទៅលើវិស័យសំណង់មុនពេលបង្កើតឱ្យមាន ក្រសួងទទួលបន្ទុកលើវិស័យនេះ ។

រហូតមកដល់បច្ចុប្បន្ន អនុក្រឹត្យនេះក៏នូវតែមានសុពលភាពដែរ បើទោះបីជាមានច្បាប់ស្តីពីសំណង់ក៏ដោយ ក៏អនុក្រឹត្យលេខ៨៦ នៅតែជាមូលដ្ឋានគោលក្នុងការគ្រប់គ្រងរបៀបរបបស្នើសុំអនុញ្ញាតសាងសង់ដដែល ។

---

[4] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧

# ជំពូក ១

# ប្រវត្តិយុត្តិនៃការគ្រប់គ្រងសំណង់នៅកម្ពុជា

# ១៩៩៤-២០០៧

## វាក្យខណ្ឌទី២៖ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

ក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាបានប្រកាសរំលាយកម្មសិទ្ធិដែលបានកាន់កាប់មុនឆ្នាំ១៩៧៩ ។[5] ដើម្បីឆ្លើយតបទៅនឹងការរៀបចំប្រទេសជាតិ និងទីក្រុងពីការបំផ្លាញក្នុងកំឡុងពេលសង្គ្រាមឡើងវិញ ច្បាប់ស្តីពីការៀបចំទឹកដី នគរូបនីយកម្ម និងសំណង់បានបង្កើតឡើង ។ ច្បាប់នេះត្រូវបានបង្កើតឡើងក្នុងគោលបំណងៈ

- ការពារប្រយោជន៍រួម និងឯកជន ការគោរពសិទ្ធិ និងការត្រួតពិនិត្យការសាងសង់
- ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុង និងតំបន់ជនបទ តាមភូមិសាស្ត្រ និងលក្ខណៈពិសេសនៃជនបទនីមួយៗ
- ការពារតម្លៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ទេសចរណ៍ និងរក្សានូវគុណភាពបរិស្ថាន ។

ជាងនេះទៅទៀត ស្របជាមួយនឹងបរិបទនៃទំនើបភាវូបនីយកម្មនៅកម្ពុជា ច្បាប់នេះក៏បានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងសកម្មភាពនៃការអភិវឌ្ឍន៍នៅកម្ពុជា ដែលត្រូវបានយកជាមូលដ្ឋាននៃដំណើរការនូវការគ្រប់គ្រងការសាងសង់ រៀបចំទឹកដី និងនគរូបនីយកម្មនៅ កម្ពុជា ។ ម្យ៉ាងវិញទៀត នៅក្នុងវិស័យសំណង់ច្បាប់រៀបចំទឹកដី នគរូបនីយ៍កម្ម និងសំណង់ ក៏ចូលរួមយ៉ាងសកម្ម នៅក្នុងសកម្មភាពនៃការគ្រប់គ្រងវិស័យសំណង់ផងដែរ ដែលធានានូវការសាងសង់ និងកំណត់ពីតំបន់ដែលអាចឱ្យមានសកម្មសាងសង់បាន និងមិនអាចអនុញ្ញាតឱ្យមានសកម្មភាពសាងសង់ដំណើរការបាន ។

ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយ៍កម្ម និងសំណង់ ត្រូវបានអនុម័តឡើងក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៤ មានចំនួន៨ជំពូក និង២៣មាត្រា រួមមាន៖

- ជំពូកទី១ កំណត់ពីកម្មវត្ថុ ឬគោលបំណងនៃការអនុម័តច្បាប់នេះ និងគោលបំណង និងវិសាលភាពនៃច្បាប់
- ជំពូកទី២ មានពីរមាត្រា ចែងពីសមត្ថកិច្ច និងឯកសារដែលពាក់ព័ន្ធទៅនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- ជំពូកទី៣ មានប្រាំមាត្រា ដែលជំពូកនេះនិយាយពីប្លង់នៃការប្រើប្រាស់ដីធ្លី និងសំណង់ ដែលជាកត្តាចំបាច់មួយបន្ទាប់ពីការលុបចោលរបបកម្មសិទ្ធិចាស់ និងជាមូលដ្ឋាននៃការអភិវឌ្ឍប្រកបដោយចីរភាព ។

---

[5] ព្រះរាជក្រម នស/រកម/០៨០១/១៤ ស្តីពីច្បាប់ភូមិបាល ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១, មាត្រា ៧

- ជំពូកទី៤ មានដប់បីមាត្រា ដែលចែងពីការការងារសំណង់ ដោយកំណត់ពីរបៀបរបប និងលក្ខខណ្ឌនៃការសាងសង់ ។

ជារួមមកច្បាប់នេះមានគោលដៅគ្រប់គ្រងនូវរាល់ការសាងសង់ រៀបចំដែនដី និងការអភិវឌ្ឍ ដើម្បីធានាភាពស្របច្បាប់ និងប្រកបដោយសុខដុមរមនីយកម្ម ។

### កថាខណ្ឌទី២៖ ស្ថាប័នទទួលបន្ទុកគ្រប់គ្រងសំណង់នៅកម្ពុជា

#### វាក្យខណ្ឌទី១៖ ស្ថាប័នរាជរដ្ឋាភិបាល (សមត្ថកិច្ចរាជរដ្ឋាភិបាល)

ដោយយោងតាមអនុក្រឹត្យលេខ៨៦ រាជរដ្ឋាភិបាលមានសមត្ថកិច្ចផ្តល់ជូនរាល់បណ្តាសំណង់ដែលមានផ្ទៃក្រឡាកម្រាលលើសពី ៣.០០០ម៉ែត្រទ្វេគុណ ឬចាប់ពី៥០០ហិចតាឡើងទៅ ។[6] ចំពោះការសាងសង់នូវរាល់បណ្តាអគារ ឬសំណង់ផ្សេងៗដែលស្ថិតនៅក្នុងទីធ្លា ការពារ និងបម្រើផលប្រយោជន៍ ក្នុងក្របខណ្ឌបរិស្ថានទេសភាព បេតិកភ័ណ្ឌ ប្រវត្តិសាស្ត្រ បូរាណវត្ថុ និងវប្បធម៌ ឬអគារយោធា ចាំបាច់ត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់ ដែលសមត្ថកិច្ចនៃការវិនិច្ឆ័យលក្ខណៈបច្ចេកទេសក្នុងការអនុញ្ញាតផ្តល់លិខិតអនុញ្ញាតដើម្បើសាងសង់ជាបន្ទុករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ជាងនេះទៅទៀត លិខិតអនុញ្ញាតនេះត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងទទួលបានការឯកភាពពីស្ថាប័នពាក់ព័ន្ធ ។

#### វាក្យខណ្ឌទី២៖ សមត្ថកិច្ចរបស់អាជ្ញាធរដែនដី (សាលាខេត្ត ឬសាលាក្រុង)

រាជធានី-ខេត្តមានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ក្រោមការទទួលខុសត្រូវរបស់ខ្លួនចំពោះការសាងសង់ដែលមានផ្ទៃក្រលាកម្រាស់តិចជាង ៣,០០០ ម៉ែត្រទ្វេគុណ មុនពេលចេញលិខិតអនុញ្ញាតសាងសង់ អាជ្ញាធរមានសមត្ថកិច្ចចុះទៅពិនិត្យផ្ទាល់ ដល់កន្លែងសាងសង់ដើម្បីពិនិត្យមើលភាពស្របច្បាប់ និងផលប៉ះពាល់ណាមួយ ។ លិខិតនេះត្រូវបានចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង ឬដោយអភិបាលខេត្ត ក្រុង ឬអភិបាលរងដែលទទួលបានសិទ្ធិប្រទាន ។ ប៉ុន្តែរាល់ការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ត្រូវធ្វើឡើង ជាលាយល័ក្ខណ៍អក្សរ ដោយមានការបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។[7]

## ផ្នែកទី២៖ វិមជ្ឈការនៃការគ្រប់គ្រងវិស័យសំណង់

នៅក្នុងក្របខណ្ឌនៃការគ្រប់គ្រងទៅលើវិស័យសំណង់នៅកម្ពុជា យើងសង្កេតឃើញពីរបៀបរបបនៃការគ្រប់គ្រងគឺបែងចែកទៅតាមលំដាប់ថ្នាក់ ។ ក្នុងន័យនេះដែលជាសញ្ញាណមួយដែលធ្វើឱ្យយើងអាចសន្និដ្ឋានបានថាការគ្រប់គ្រងគេអនុវត្តតាមរបៀបវិមជ្ឈការ ដែលមានន័យថាគឺជាការរំលែកនៃអំណាចពីថ្នាក់លើទៅថ្នាក់ក្រោម ។

---

[6] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា៥

[7] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា៤

ជាក់ស្តែងយើងក្រឡេកទៅមើលរបបនៃការផ្តល់នូវលិខិតអនុញ្ញាតសាងសង់ គឺមានការបែងចែកតួនាទីនៃការផ្តល់ជូនលិខិត ពោលគឺពុំមែនស្ថិតនៅក្នុងកណ្តាប់ដៃរបស់ក្រសួងទាំងអស់ទេ គឺគេផ្តល់អំណាចទៅកាន់អាជ្ញាធរមូលដ្ឋាន ទៅតាមទំហំដែលបានកំណត់ដោយច្បាប់ ។ ជាងនេះទៅទៀត អំណាចនៃការគ្រប់គ្រងក៏ដូច្នេះដែរ ស្ថាប័នវិលែកនៃសិទ្ធិអំណាចប្រគល់ទៅឱ្យថ្នាក់ក្រោមដើម្បីធ្វើការគ្រប់គ្រង ក្នុងគោលបំណងធានាបាននូវប្រសិទ្ធិភាពនៃការគ្រប់គ្រងមួយមានភាពល្អប្រសើរ និងមានភាពសុខដុមនីយកម្មនៃការសាងសង់ ។

## កថាខណ្ឌទី១៖ ការគ្រប់គ្រងការងារសាងសង់

### វាក្យខណ្ឌទី១៖ ការគ្រប់គ្រងអាជ្ញាប័ណ្ណសាងសង់

#### ក. ការផ្តល់អាជ្ញាប័ណ្ណសាងសង់

រាល់ការសាងសង់ ការកែប្រែទិដ្ឋភាព ឬការកែប្រែការប្រើប្រាស់សំណង់ណាមួយត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ត្រូវមានឯកសារ និងប្លង់ចាំបាច់ ។[8] ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ត្រូវយកមកដាក់ដោយម្ចាស់កម្មសិទ្ធិដី ឬអ្នកបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ។ នីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនេះផងដែរ ត្រូវបានកំណត់ដោយអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ ។

#### ក.១ នីតិវិធីស្នើសុំលិខិតអនុញ្ញាតសាងសង់[9]

ដោយយោងតាមអនុក្រឹត្យលេខ៨៦ ស្តីពីលិខិតអនុញ្ញាតសាងសង់ ម្ចាស់កម្មសិទ្ធិ ឬអ្នកដែលទទួលបានការផ្ទេរកម្មសិទ្ធិដោយកម្មសិទ្ធិករ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ទៅកាន់ការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ នៃមន្ទីររៀបចំក្រុង និងសំណង់ (ចំពោះក្រុងភ្នំពេញ និងក្រុងដទៃទៀត) រីឯចំពោះខេត្តត្រូវដាក់ស្នើសុំទៅមន្ទីរសំណង់ នៅសាលាខេត្ត ឬសាលាស្រុក ។ កាលណាសំណុំលិខិតពាក្យសុំគ្រប់គ្រាន់ហើយ អ្នកស្នើសុំទទួលបានបង្កាន់ដៃទទួលពាក្យសុំលិខិតអនុញ្ញាតសាងសង់មួយ ។

ឯកសារនៃពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ចាំបាច់ត្រូវមាននោះរួមមាន៖

- ពាក្យសុំលិខិតអនុញ្ញាតសាងសង់ក្នុងទម្រង់ជាលិខិតផ្លូវការ ព្រមទាំងភ្ជាប់នូវបណ្តាប្លង់ខាងក្រោម ជាចំនួន១០ច្បាប់ បត់ទំហំ២១X២៩,៧ ស.ម
- វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ អចលនវត្ថុ ឬលិខិតកាន់កាប់ដីជាបណ្តោះអាសន្ន
- សលាកប័ត្រដីឡូត៍ ដែលធ្វើឡើងដោយភ្នាក់ងារមន្ទីរសុរិយោដី ឬដោយលេខាគណិតឯកជន ព្រមទាំង

[8] មាត្រា១៤ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

[9] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧,ជំពូក៣

ចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយអ្នកធ្វើ និងអនុម័តដោយមន្ទីរសុរិយោដី ។ នៅលើប្លង់មានបញ្ជាក់ពីៈ

- ទីតាំងនៃដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ
- ឈ្មោះ ឬលេខផ្លូវធំ និងតូច
- ផ្ទៃក្រឡាដីឡូត៍
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ (ទីតាំង និងកម្ពស់)
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ជាប់គ្នា ផ្ទៃបាត និងកម្ពស់
- មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ
- ចំណុចនឹងថ្កល់សម្រាប់ជាគោលសំគាល់កម្ពស់ ដែលបោះនៅលើដីឡូត៍
- បន្ទាប់ជួរតម្រង់ផ្លូវសាធារណៈ

- ប្លង់ទីតាំងអគារក្នុងដីឡូត៍ មាត្រដ្ឋាន ១/២០០ ឬ ១/៥០០ ក្រោយទទួលការយល់ព្រមពីបណ្តាមន្ទីរទទួលបន្ទុកដីឡូត៍ធំៗ
- ប្លង់អគារគ្រប់ជាន់ មាត្រដ្ឋាន ១/១០០
- ប្លង់ផ្នែកបណ្តាញក្រោមដីនានា និងអាងបង្គន់អនាម័យ មាត្រដ្ឋាន ១/១០០
- ប្លង់មុខភាពនៃអគារ មាត្រដ្ឋាន ១/១០០
- ប្លង់ពុះពីរយ៉ាងតិច មាត្រដ្ឋាន ១/១០០
- តារាងផ្ទៃក្រឡាមួយសម្រាប់ជាន់នីមួយៗ
- សលាកប័ត្រគណនាផ្ទៃបាតផ្ទាល់ដី និងសន្ទទស្សន៍នៃការប្រើប្រាស់
- ប្លង់លំអិតគ្រឿងផ្គុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារណការ និងដឹកជញ្ជូនមុនបើកការដ្ឋានសាងសង់ (ក្រោយពេលទទួលបានលិខិតអនុញ្ញាតសាងសង់រួចរាល់) ។

សំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ត្រូវធ្វើឡើងជាភាសាខ្មែរ ។ អត្ថបទជាភាសាអង់គ្លេស ឬបារាំងអាចផ្តល់ភ្ជាប់ជាមួយនឹងលិខិតនេះបាន ។ ពាក្យសុំ និងបណ្តាប្លង់ ត្រូវចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគម្រោង ។ ក្នុងករណីអ្នកស្នើសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកដែលស្នើសុំដែទទួលបានសិទ្ធិពីម្ចាស់កម្មសិទ្ធិក៏ត្រូវចុះហត្ថលេខាលើសំណុំលិខិតពាក្យស្នើសុំលិខិតអនុញ្ញាតនេះផងដែរ ។

ក្នុងករណីដែលសំណង់មានទំហំលើសពី ៥០០ ម៉ែត្រទ្វេគុណ គម្រោងអាចធ្វើបានដោយស្ថាបត្យករតែប៉ុណ្ណោះ ។

កាលបរិច្ឆេទជាផ្លូវការនៃការដាក់ពាក្យស្នើសុំ ត្រូវចារក្នុងសំណុំលិខិត ហើយជូនដំណឹងដល់អ្នកសុំ ។ ចំពោះអគារ និងបណ្តាការ្យធំៗ ឬដែលមានប្រភេទអាចធ្វើឱ្យរំខានដល់សុវត្ថិភាព សុខមាលភាពសាធារណៈ

នោះ ត្រូវផ្សព្វផ្សាយដល់សាធារណជន ពីការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ដោយវិធីណាមួយផ្សេងទៀត ដែលគេយល់ឃើញថាមានប្រសិទ្ធិភាពជាង ដោយផ្អែកលើមធ្យោបាយផ្សាយព័ត៌មាននៅតាមមូលដ្ឋាន ។

រាល់បុគ្គលពាក់ព័ន្ធអាចសាកសួរសុំមើលសំណុំលិខិត នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ នៃមន្ទីររៀបចំក្រុង និងសំណង់ និងមន្ទីរសំណង់ នៃសាលាស្រុក ឬសាលាខេត្ត ក្នុងរយៈពេល២៥ថ្ងៃ និងអាចធ្វើការតវ៉ា ឬទាមទារទៅអាជ្ញាធរមានសមត្ថកិច្ច ។ អាជ្ញាធរមូលដ្ឋានពិនិត្យមើលការជំទាស់ ដោយអង្កេត និងធ្វើរបាយការណ៍ជូនសាលាខេត្ត សាលាក្រុង ក្នុងរយៈពេល៥ថ្ងៃ ។ សាលាខេត្ត សាលាក្រុង ឬគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់(ប្រសិនបើមាន) គណៈកម្មការនេះត្រូវសំរេចអំពីសុពលភាពនៃបណ្តឹងតវ៉ា ។

រយៈពេលសម្រាប់ពិនិត្យសំណុំលិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ត្រឹម ៤៥ថ្ងៃធ្វើការ ។ រយៈពេលនេះគិតចាប់ពីថ្ងៃ ដែលបានបំពេញសព្វគ្រប់នៃលិខិតស្នើសុំ នៅចុងពេលកំណត់នេះ អ្នកស្នើសុំត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច ជាលាយលក្ខណ៍អក្សរ ស្តីពីការអនុញ្ញាត ឬការមិនអនុញ្ញាត ឬមួយការអនុញ្ញាតដែលតែស្នើសុំឱ្យមានការកែសម្រួលបន្ថែម ។

### ក.២. សុពលភាពនៃលិខិតអនុញ្ញាតសាងសង់

លិខិតអនុញ្ញាតសាងសង់ ត្រូវបានប្រគល់ឱ្យអ្នកដែលបានដាក់ពាក្យស្នើសុំដោយអាជ្ញាធរ ដែលបានអនុញ្ញាតឱ្យ ។ លិខិតអនុញ្ញាតសាងសង់មួយច្បាប់ អមដោយសំណុំលិខិតគ្រប់សព្វ (ប្លង់ លិខិតស្នាមដែលជាឧបសម្ព័ន្ធយោបល់...) ត្រូវបានរក្សាទុកជាឯកសារដាច់ខាត ដោយសាលារាជធានី ខេត្ត ។[10]

លិខិតអនុញ្ញាតសាងសង់ដែលបានស្នើសុំរួចរាល់នោះអស់សុពលភាពកាលណា ការងារពុំដំណើរការក្នុងរយៈពេលមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតសាងសង់ ។ ជាមួយគ្នានេះដែរលិខិតអនុញ្ញាតសាងសង់នេះ អនុញ្ញាតឱ្យមានការពន្យាសុពលភាពបានមួយដង ។[11]

### ខ. ប្រភេទសំណង់ដែលចាំបាច់ត្រូវសុំលិខិតអនុញ្ញាតសាងសង់[12]

គ្រប់ការសាងសង់ សំណង់ថ្មី ឬការសាងសង់ឡើងវិញជាថ្មី ពង្រីក និងការសាងសង់បន្ថែមទៅលើសំណង់ដែលមានស្រាប់នៅក្នុងទីក្រុង ទីប្រជុំជន ចាំបាច់ត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់ ។ រីឯការសាងសង់ ឬការផ្លាស់ប្តូរទ្រង់ទ្រាយឋបនភណ្ឌផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យ(ការដាក់ស៊ីទែនកន្លែងស្តុកប្រេងឥន្ធនៈ រោងជាងដែលមានផលិតផលគ្រឿងឆេះ...) អគារឧស្សាហកម្ម ការដាក់ប៉ាណូ ផ្សាយពាណិជ្ជកម្ម អង់តែនទូរទស្សន៍ ទូរគមនាគមន៍ ប៉ាណូស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជាឧបករណ៍ដទៃទៀតដែល

[10] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា ១៥

[11] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា ១៦

[12] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា ២

បំពាក់ទៅនឹងសំណង់អគារ ហើយស្ថិតនៅជិតផ្លូវ ឬទីតាំងចំទិសដែលគេអាចមើលឃើញ និងអគារដែលមានស្រាប់ ក៏ត្រូវមានលិខិតអនុញ្ញាតសាងសង់ដែរ បើការងារកែប្រែទៅលើផ្នែកមួយចំនួនដូចជាៈ

- ការប្រើប្រាស់របស់ផ្នែកអគារ ឬ ទិដ្ឋភាពនៃអគារ ឬ បង្កើនផ្ទៃក្រលាកម្រាលសំណង់
- ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ ឬការធ្វើបង្គន់អនាម័យ និងការបន្តភ្ជាប់ទៅបំពង់លូ
- កន្លែងទទួលសាធារណៈជន
- ទំរង់ដី (ចាក់បំពេញ ជីកយកចេញ ប្តូរប្រភេទដីស្រែចំការ ជាដីសាងសង់) ឬការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ទីដ្ឋានដូចជា លប់បំបាត់បឹង ប្រលាយ ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹក និងការកាប់ព្រៃឈើជាដើម ...។

### គ. ប្រភេទសំណង់ដែលពុំចំណុះលិខិតអនុញ្ញាត

ដើម្បីជួយសម្រួលដល់ជីវភាព និងបន្ទុកនៃការចំណាយពេលវេលា ការសាងសង់មួយចំនួនមិនចាំបាច់តម្រូវឱ្យមានការស្នើសុំលិខិតអនុញ្ញាតសាងសង់ឡើយ ។ ជាក់ស្តែងដោយសារសំណង់ទាំងនោះស្ថិតនៅទីជនបទ ឬតំបន់ដាច់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក ឬឆ្ងាយពីតំបន់រមណីយដ្ឋាន តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការពារ ដោយមិនគិតពីទំហំ ឬសម្ភារសំណង់ប្រើប្រាស់ឡើយ ។ ម៉្យាងវិញទៀតរាល់ការសាងសង់នូវបណ្តាសំណង់ដែលរដ្ឋជាម្ចាស់សំណង់ ឬការសាងសង់នូវបណ្តាការឫសិល្បៈរបស់រដ្ឋសម្រាប់សេវាសាធារណៈ សាលាសំណាក់សាធារណៈ ក៏ដូចជាទីសក្ការៈផ្សេងៗ សម្រាប់សាសនិកជាដើម...ដែលជាប្រភេទសំណង់ដែលសម្រាប់ជាឧត្តមប្រយោជន៍សាធារណៈនោះ គ្រាន់តែផ្តល់ដំណឹងជូនអាជ្ញាធរមូលដ្ឋានអំពីគម្រោងនោះជាការស្រេចទៅហើយ ។ ចំពោះការជួសជុល ឬការថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ ក៏ពុំតម្រូវឱ្យមានលិខិតអនុញ្ញាតផងដែរ លើកលែងតែការជួសជុលនោះអាចបណ្តាលឱ្យមានការប៉ះពាល់ដល់អ្នកជិតខាង ។

## វាក្យខណ្ឌទី២៖ ការគ្រប់គ្រងការដ្ឋានសំណង់

### ក. លិខិតបើកការដ្ឋានសំណង់

ការដ្ឋាននីមួយៗ អាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន[13] ហើយសហគ្រាស ក្រុមហ៊ុន ឬក្រុមជាងម៉ៅការសាងសង់ មានលិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ដែលចេញដោយក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ខេត្ត ក្រុង ។[14]

លិខិតអនុញ្ញាតបើកការដ្ឋានត្រូវបានផ្តល់ឱ្យក្នុងរយៈពេលមួយខែយ៉ាងយូរ បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ។ ដើម្បីស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់បានចាំបាច់ត្រូវមាននូវសំណុំឯកសារ

[13] ប្រកាសលេខ៣២ ប្រ.ក/ស.ណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់, ប្រការ៣

[14] ប្រកាសលេខ៣២ ប្រ.ក/ស.ណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់, ប្រការ២

មួយចំនួនរួមមាន៖[15]

- ពាក្យសុំរបស់ម្ចាស់សំណង់
- លិខិតអនុញ្ញាតសាងសង់
- កិច្ចសន្យារវាងម្ចាស់សំណង់ និងសហគ្រាស ក្រុមហ៊ុន ឬក្រុមជាងម៉ៅការសាងសង់
- លិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ របស់សហគ្រាស ក្រុមហ៊ុន ឬក្រុមជាងម៉ៅការសាងសង់ ដែលទទួលសំណង់នោះ ។

នៅពេលសុំបើកការដ្ឋាន ម្ចាស់សំណង់ ត្រូវបង្ហាញឯកសារធានារ៉ាប់រងថាបានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ។[16] ការដ្ឋានកំពុងដំណើការ ក្រសួង ឬមន្ទីរ និងអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន មានភារកិច្ចត្រួតពិនិត្យផ្ទាល់ដល់ការដ្ឋាន និងសួររកវិញ្ញាបនបត្រធានារ៉ាប់រង ។ ក្នុងករណីគ្មានវិញ្ញាបនបត្រធានារ៉ាប់រងដែលតម្រូវទេ ក្រុមត្រួតពិនិត្យនៅការដ្ឋាននៅមូលដ្ឋាននោះ ត្រូវបញ្ឈប់សកម្មភាពការដ្ឋានជាបណ្ដោះអាសន្ន ហើយតម្រូវឱ្យទិញធានារ៉ាប់រង ។[17]

### ខ. ការទទួលខុសត្រូវការដ្ឋានសំណង់

គ្រប់ការដ្ឋានសាងសង់ ជួសជុល តម្លើងទាំងអស់ ដែលទទួលខុសត្រូវដោយសហគ្រិន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត ចាំបាច់ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន ។

ប្រភេទការដ្ឋានដែលត្រូវបានលើកលែងមិនចាំបាច់មានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវរួមមាន៖

- ការដ្ឋានដែលដំណើរការដោយស្ថាប័នរដ្ឋាភិបាល
- ការដ្ឋានសាងសង់ ជួសជុល តម្លើង ដែលទទួលបន្ទុកដោយនីតិបុគ្គលនៃនីតិសាធារណៈ ដើម្បីផលប្រយោជន៍សាធារណៈ ដែលមានលទ្ធភាពជួសជុលសងបានឆាប់រហ័ស និងគ្រប់គ្រាន់នូវការខូចខាតទាំងឡាយ ។
- ការដ្ឋានសាងសង់ជួសជុលកែលំអរតូចតាច ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ។[18]

ការដ្ឋានសំណង់ដែលប្រើប្រាស់ថវិកាឯកជន នៅពេលផ្តល់លិខិតអនុញ្ញាតសាងសង់រួច ម្ចាស់សំណង់ត្រូវចុះកិច្ចសន្យាជាមួយសហគ្រិន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្តណាដែលមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន ទើបការដ្ឋានសាងសង់អាចដំណើរការបាន ។

---

[15] ប្រកាសលេខ៣២ ប្រ.ក/ស.ណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់, ប្រការ៣

[16] ប្រកាសលេខ ៦៥៥ ប្រក. សហវ-ដនស-មជ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន, ប្រការ ៦

[17] ប្រកាសលេខ ៦៥៥ ប្រក. សហវ-ដនស-មជ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន, ប្រការ ៧

[18] ប្រកាសលេខ ៦៥៥ ប្រក. សហវ-ដនស-មជ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន, ប្រការ ២

ការដ្ឋានសំណង់នីមួយៗត្រូវហ៊ុមព័ទ្ធដោយរបងកម្ពស់២ម៉ែត្រ យ៉ាងទាបបំផុត ហើយមិនអនុញ្ញាតឱ្យធ្វើលើចិញ្ចើមថ្នល់ ។ ក្នុងករណីទីតាំងការដ្ឋានចង្អៀត ការធ្វើរបងបិទបាំងបណ្តោះអាសន្នលើចិញ្ចើមថ្នល់សាធារណៈត្រូវរក្សាឱ្យមានចន្លោះផ្លូវដើរ និងធ្វើរបាំងការពារតាមទំហំដែលអនុញ្ញាត ឬកំណត់ដោយអាជ្ញាធរ ។ ចំពោះសំណង់ដែលមានកម្ពស់ចាប់ពី៥ម៉ែត្រឡើងទៅ ត្រូវហ៊ុំព័ទ្ធដោយក្រណាត់កៅស៊ូ ឬសំណាញ់សុវត្ថិភាព ។[19] ត្រូវតំកល់ជាប្រចាំនូវលិខិតបើកការដ្ឋាន គំនូរប្លង់តាមមុខជំនាញការងារសំណង់ ផែនការអនុវត្តការងារ និងឯកសារពាក់ព័ន្ធក្នុងដំណាក់កាលនីមួយៗនៃការងារសំណង់សម្រាប់ភ្នាក់ងារសំណង់ត្រួតពិនិត្យ និងមានអ្នកបច្ចេកទេសដែលមានកាតព្វកិច្ចឆ្លើយបំភ្លឺ និងទទួលខុសត្រូវក្នុងការងារសំណង់ ។ នៅក្នុងការដ្ឋានត្រូវមានភ្លើងដើម្បីបំភ្លឺ បំពង់ពន្លត់អគ្គិភ័យ ផ្ទាំងគំនូរសំណង់ដែលមានឈ្មោះសំណង់ ក្រុមហ៊ុនសាងសង់ ម្ចាស់សំណង់ វិស្វករ ស្ថាបត្យករ ផ្ទៃក្រលា កន្លែងសំណង់តាំងនៅ និងលេខទំនាក់ទំនង ។

ការដ្ឋានត្រូវមានអនាម័យ សណ្តាប់ធ្នាប់ជាប្រចាំ រៀបចំការទុកដាក់សម្ភារៈ ឬកាកសំណល់ ចៀសវាងការប៉ះពាល់ដល់ផ្លូវសាធារណៈ ឬហូរធ្លាក់ចូលក្នុងលូ និងប្រឡាយទឹក ។ ក្នុងករណីប្រើគ្រឿងចក្របរិក្ខារលើកស្ទូច ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរដែនដី ដើម្បីបិទផ្លូវ ត្រូវធ្វើផ្លូវវាងបណ្តោះអាសន្ន និងបំពាក់ភ្លើងសញ្ញាសម្គាល់ដើម្បីសុវត្ថិភាពសាធារណៈ ព្រមទាំងរក្សាសណ្តាប់ធ្នាប់សាធារណៈនៅពេលយប់ ។

ក្នុងករណីការសាងសង់មានបុកសសរគ្រឹះ ម្ចាស់សំណង់ និងអ្នកម៉ៅការសាងសង់ត្រូវៈ[20]

- មានកាតព្វកិច្ចអនុញ្ញាតឱ្យមន្ត្រីបច្ចេកទេស ដែលមានសមត្ថកិច្ចចូលពិនិត្យក្នុងការដ្ឋាន
- ចៀសវាងការប៉ះពាល់ដល់គ្រឿងផ្គុំផ្នែកក្រោមដី
- ធានាសុវត្ថិភាពអគារដែលស្ថិតនៅជុំវិញបរិវេណការដ្ឋាន
- រៀបចំសណ្តាប់ធ្នាប់ការងារតាមលក្ខណៈបច្ចេកទេស ។

ក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលបញ្ចប់គម្រោង សម្ភារៈ កាកសំណល់ និងការដ្ឋានត្រូវប្រមូលយកចេញ និងរុះរើ ។ ក្នុងករណីពុំបានរុះរើ យកសម្ភារៈ កាកសំណល់ចេញពីកន្លែងតាំងការដ្ឋាន សាលាខណ្ឌ ឬសាលាស្រុក មានកាតព្វកិច្ច ចាត់ចែងដឹកជញ្ជូនចេញដោយស្វ័យប្រវត្តិ ហើយបន្ទុកចំណាយជារបស់ម្ចាស់សំណង់ ។[21]

កម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាភារៈទទួលខុសត្រូវការដ្ឋានត្រូវកំណត់ដូចខាងក្រោមៈ

- ៥ 000 ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់របួសរាងកាយ ឬ

---

[19] ប្រកាសលេខ៣២ ប្រ.ក/ ស.ណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់, ប្រការ៥

[20] ប្រកាសលេខ ៦៥៥ ប្រក. សហវ-ដនស-មផ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន, ប្រការ ៩

[21] មាត្រា ១៩ នៃអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់

ស្លាប់ក្នុងមនុស្សម្នាក់

- ២៥ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់របួសរាងកាយ ឬស្លាប់ ក្នុងគ្រោះថ្នាក់មួយករណី

- ១០ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់ការខូចខាតទ្រព្យសម្បត្តិ ។[22]

### គ. លិខិតបិទការដ្ឋានសំណង់

ពេលសាងសង់រួចរាល់ជាស្ថាពរ ម្ចាស់សំណង់ត្រូវធ្វើការណ៍ស្តីពីដំណើរការសាងសង់របស់ខ្លួន និងសុំលិខិតបិទការដ្ឋាន ដោយភ្ជាប់ជាមួយនូវពាក្យសុំបិទការដ្ឋាន លិខិតអនុញ្ញាតបើកការដ្ឋាន និងរបាយការណ៍អំពីដំណើការសាងសង់ ។[23] ពេលទទួលបានលិខិតបិទការដ្ឋានរួចហើយ ម្ចាស់សំណង់ត្រូវដាក់ពាក្យសុំវិញ្ញាបនបត្របញ្ជាក់ពីភាពត្រឹមត្រូវ នៃសំណង់មុនពេលប្រើប្រាស់ វិញ្ញាបនបត្របញ្ជាក់ពីភាពត្រឹមត្រូវដែលចេញដោយអាជ្ញាធរក្រុង ឬខេត្ត ត្រូវបានផ្តល់ជូនក្រោយពិនិត្យ និងបញ្ជាក់ពីភាពត្រឹមត្រូវរបស់សំណង់ អគាររួចរាល់ ។

ពេលបញ្ចប់ការដ្ឋានសាងសង់ជាស្ថាពរ ម្ចាស់សំណង់ត្រូវរុះរើ របងហ៊ុំព័ទ្ធការដ្ឋាន និងដឹកជញ្ជូនកាកសំណល់ឱ្យបានស្អាត ។

### វាក្យខណ្ឌទី៣៖ ការគ្រប់គ្រងក្រុមជាងសំណង់

ក្រុមជាងសំណង់ គឺជាមនុស្សមួយក្រុម ដែលប្រកបអាជីវកម្ម សាងសង់តាមទ្រង់ទ្រាយអាជីវកម្មខ្នាតតូច ។ អនុលោមតាម សារាចរណែនាំលេខ ០០១ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រងក្រុមជាងសំណង់ ដើម្បីទទួលបានភាពស្របច្បាប់ បុគ្គលដែលមានបំណងប្រកបអាជីវកម្មប្រភេទនេះ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មពី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត-ក្រុង ដោយត្រូវបំពេញនូវលក្ខខណ្ឌសុំប្រកបអាជីវកម្មដូចខាងក្រោម៖[24]

១. ប្រធានក្រុមជាងសំណង់ ដែលជាមេជាងសំណង់ត្រូវមានសញ្ជាតិខ្មែរ

២. ប្រធានក្រុមជាងសំណង់ត្រូវមកដាក់ពាក្យសុំប្រកបអាជីវកម្មដោយខ្លួនឯងផ្ទាល់

៣. នាមករណ៍របស់ក្រុមជាងសំណង់មិនអនុញ្ញាតឲ្យប្រើពាក្យថា សហគ្រាស ឬ ក្រុមហ៊ុនឡើយ

៤. ក្រុមជាងសំណង់ ត្រូវបង់ពន្ធអាករផ្សេងៗ ស្របតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

---

[22] ប្រកាសលេខ ៦៥៥ ប្រក. សហវ-ដនស-មផ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន, ប្រការ ៣

[23] ប្រកាសលេខ៣២ ប្រ.ក/ ស.ណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់, ប្រការ ១១

[24] សារាចរណែនាំលេខ០០១ ដ.ន.ស/អ.ស.ណ ស្តីពី ការគ្រប់គ្រងក្រុមជាងសំណង់

៥. ក្រុមជាងសំណង់ ត្រូវតម្កល់ទុករបាយការណ៍ សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួននៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត-ក្រុង តាមការណែនាំរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត-ក្រុង

៦. ក្នុងករណីមានការផ្លាស់ប្តូរអាសយដ្ឋាន ឬ ប្រធានក្រុមជាងសំណង់ ត្រូវជូនដំណឹងមកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត-ក្រុង យ៉ាងយូរពីរសប្តាហ៍ក្រោយការផ្លាស់ប្តូរ ។

ស្របជាមួយគ្នាផងដែរ ការប្រកបអាជីវកម្មរបស់ក្រុមជាងសំណង់ ត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តការងារតាមការកំណត់ និងមុខជំនាញដូចខាងក្រោម ហើយដែលមានទំហំបច្ចេកទេសមិនលើសពីកម្រិតកំណត់ដូចតទៅ:

- ផ្ទៃក្រឡាសំណង់សរុប ៨០ ម៉ែត្រទ្វេគុណ
- ផ្ទៃក្រឡាសំណង់ ដែលត្រូវសង់ថ្មីបន្ត ឬ ពង្រីកបន្ថែម ត្រូវបូកបញ្ចូលនឹងផ្ទៃក្រឡាសំណង់មានស្រាប់
- ផ្ទៃក្រឡាសំណង់ត្រូវគិតបញ្ចូលគ្នា ចំពោះសំណង់ដែលមានគ្រឿងផ្គុំជាប់គ្នា ទោះបីមានកម្មសិទ្ធិដោយ ឡែកពីគ្នា ឬពេលវេលានៃការអនុញ្ញាតឱ្យសាងសង់ខុសគ្នាក៏ដោយ
- កំពស់អគារមួយជាន់ (ជាន់ផ្ទាល់ដី)
- អគារពុំមានគ្រៀមលក្ខណៈសង់បន្ថែមច្រើនជាន់
- សំណង់អគារពុំស្ថិតនៅតំបន់ដី បាក់ស្រុត តំបន់ដីមានកម្រិតទ្រខ្សោយ
- ធ្នឹមកម្រាល ធ្នឹមទ្រផ្សេងៗ មានប្រវែង ៤ ម៉ែត្រ ហ្វ្រែមគ្រោងដំបូលមានប្រវែង ៨ ម៉ែត្រ ធ្នឹមលយមានប្រវែង ១,៥០ ម៉ែត្រ
- អាងកប់ដី ដែលមានចំណុះ ១០ ម៉ែត្រត្រីគុណ អាងទឹកខ្ពស់ពីដី ៤ ម៉ែត្រ ដែលមានចំណុះ ៨ ម៉ែត្រត្រីគុណ
- របងកំពស់ ២,៥ ម៉ែត្រ គិតពីនីវ៉ូ ដីត្រង់ជើងរបង
- សំណង់ជាលំនៅឋានរបស់ប្រជាពលរដ្ឋធ្វើពីឈើ (ដោយមិនគិតពីផ្ទៃក្រឡា និង កំពស់នៃសំណង់)
- ម៉ៅការបន្ត ការងារជុសជុល និង សាងសង់ ពីសហគ្រាស ក្រុមហ៊ុនសាងសង់នានា ដែលមានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយមានការទទួលខុសត្រូវ លើលក្ខណៈបច្ចេកទេសពីសហគ្រាស ឬ ក្រុមហ៊ុនសាងសង់នោះ។

ក្រុមជាងសំណង់ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី ខេត្ត[25] ហើយសុពលភាពនៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម មានសុពលភាពបីឆ្នាំ គិតចាប់ពីថ្ងៃ

[25] ប្រកាសលេខ៧៥ ប្រ.ក/ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់, កថាខណ្ឌទី២, ប្រការ៥

ចេញលិខិតអនុញ្ញាត ។ បែបបទនៃការសុំលិខិតប្រកបអាជីវកម្ម ត្រូវមានៈ

- ពាក្យសុំប្រកបអាជីវកម្ម (៤ច្បាប់)
- ជីវប្រវត្តិសង្ខេប របស់ប្រធានក្រុមជាងសំណង់ដោយមានបិទរូបថតទំហំ ៤x៦ (៤ច្បាប់)
- ជីវប្រវត្តិសង្ខេបរបស់ជាង តាមមុខជំនាញ មានបិទរូបថត ៤x៦ (៤ច្បាប់)
- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណរបស់ប្រធានក្រុមជាងសំណង់ ដែលមានបានបញ្ជាក់នៅសាលាស្រុក/ខណ្ឌ (៤ច្បាប់)
- សេចក្តីប្រកាសពីភាពគ្មានទោសពៃរ៍ របស់ប្រធានក្រុមជាងសំណង់ (៤ច្បាប់)
- លក្ខន្តិកៈរបស់ក្រុមជាងសំណង់ (៤ច្បាប់)
- កិច្ចសន្យារវាងក្រុមសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ដែលចេញលិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម (៤ច្បាប់)
- បញ្ជីរាយឈ្មោះជាងសំណង់តាមផ្នែកជំនាញ និងអង្គការលេខ របស់ក្រុមជាងសំណង់ (៤ច្បាប់)
- ឯកសារស្នាដៃ (២ច្បាប់) បើមាន
- បញ្ជីគ្រឿងចក្រសំណង់ និងសម្ភារៈបរិក្ខារ (៤ច្បាប់) បើមាន
- ឯកសារធនាគារ (១ច្បាប់) បើមាន
- បង្កាន់ដៃបង់ពន្ធ (បណ្ណប៉ាតង់) ១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (១ច្បាប់) បើមាន

ក្នុងរយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាពក្រុមជាងសំណង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតជាថ្មីពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតចាស់ និងបង្កាន់ដៃបង់ពន្ធអាករជាថ្មី ។

**កថាខណ្ឌទី២៖ ការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់នៃសំណង់**

**វាក្យខណ្ឌទី១៖ ប្រភេទនៃសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់**

សហគ្រាស ក្រុមហ៊ុនគម្រោងប្លង់ និងសាងសង់ទាំងអស់ដែលធ្វើសកម្មភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ច គ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។[26]

**សហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ មាន៤ប្រភេទ៖**[27]

- **ប្រភេទទី១ ប្រភេទធំ គឺសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមាន៖**

---

[26] ប្រកាសលេខ៧៥ ប្រ.ក/ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់, ប្រការ១

[27] ប្រកាសលេខ៧៥ ប្រ.ក/ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់, ប្រការ២

  - ស្ថាបត្យករយ៉ាងតិច៣នាក់ មានបទពិសោធន៍ការងារយ៉ាងតិច៥ឆ្នាំ
  - មានវិស្វករយ៉ាងតិច៥នាក់ មានបទពិសោធន៍ការងរយ៉ាងតិច៥ឆ្នាំ
  - នាយកបច្ចេកទេស មានបទពិសោធន៍យ៉ាងតិច៧ឆ្នាំ
  - មានបទ លើគម្រោងមានតម្លៃសរុបយ៉ាងតិច ៨០០លានរៀល
  - មានដើមទុនយ៉ាងតិច ២០០លានរៀលទទួលស្គាល់ដោយធនាគារស្របច្បាប់ ។
- **ប្រភេទទី២ ប្រភេទមធ្យម គឺសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានៈ**
  - ស្ថាបត្យករយ៉ាងតិច២នាក់ មានបទពិសោធន៍ការងារយ៉ាងតិច៤ឆ្នាំ
  - មានវិស្វករយ៉ាងតិច៤នាក់ មានបទពិសោធន៍ការងរយ៉ាងតិច៤ឆ្នាំ
  - នាយកបច្ចេកទេស មានបទពិសោធន៍យ៉ាងតិច៦ឆ្នាំ
  - មានបទ លើគម្រោងមានតម្លៃសរុបយ៉ាងតិច ២០០លានរៀល
  - មានដើមទុនយ៉ាងតិច ៨០លានរៀលទទួលស្គាល់ដោយធនាគារស្របច្បាប់ ។
- **ប្រភេទទី៣ ប្រភេទតូច គឺសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានៈ**
  - ស្ថាបត្យករយ៉ាងតិច២នាក់ មានបទពិសោធន៍ការងារយ៉ាងតិច៣ឆ្នាំ
  - មានវិស្វករយ៉ាងតិច៣នាក់ មានបទពិសោធន៍ការងរយ៉ាងតិច៣ឆ្នាំ
  - នាយកបច្ចេកទេស មានបទពិសោធន៍យ៉ាងតិច៥ឆ្នាំ
  - មានដើមទុនយ៉ាងតិច ២០លានរៀលទទួលស្គាល់ដោយធនាគារស្របច្បាប់ ។
- **ប្រភេទទី៤ ជារូបវន្តបុគ្គល**
  - ស្ថាបត្យករ មានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ឆ្នាំ ដោយមានការទទួលស្គាល់ពីរដ្ឋាភិបាល
  - ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេងៗ យ៉ាងតិច ៥ឆ្នាំ
  - ស្ថាបត្យករ ដែលមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច ៣ឆ្នាំ
  - វិស្វករផ្នែកសំណង់អគារ ឬសំណង់ស៊ីវិល ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ឆ្នាំ
  - វិស្វករផ្នែកសំណង់អគារ ឬសំណង់ស៊ីវិល ដែលមានបទពិសោធន៍យ៉ាងតិច ៣ឆ្នាំ
  - វិស្វករស្ថិតនៅខេត្តក្រុង ដែលគ្មានស្ថាបត្យករ និងអ្នកបច្ចេកទេសសំណង់អគារ ឬសំណង់ស៊ីវិល
  - អ្នកបច្ចេកទេសថ្នាក់មធ្យមសំណង់អគារ ឬសំណង់ស៊ីវិលស្ថិតនៅខេត្ត ក្រុង ដែលគ្មានស្ថាបត្យករ និងវិស្វករផ្នែកសំណង់អគារ ឬសំណង់ស៊ីវិល ។

សហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ អាចសុំតម្លើងឋានៈរបស់ខ្លួននៅពេលដែលសហគ្រាស និងក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ដោយអនុក្រឹត្យ និងមានលិខិតបញ្ជាក់ពីការបង់ពន្ធទៀងទាត់ជូនរដ្ឋ ។

**សហគ្រាស និងក្រុមហ៊ុន សាងសង់ មាន៤ប្រភេទៈ**[28]

- **ប្រភេទទី១ ប្រភេទធំ គឺសហគ្រាស និងក្រុមហ៊ុនសាងសង់ ដែលមានៈ**
    - ស្ថាបត្យករយ៉ាងតិច ២នាក់ មានបទពិសោធន៍ការងារយ៉ាងតិច ១០ឆ្នាំ
    - វិស្វករយ៉ាងតិច២នាក់ និងមានបទពិសោធន៍យ៉ាងតិច ១០ឆ្នាំ
    - នាយកបច្ចេកទេស និងគម្រោង មានបទពិសោធន៍១០ឆ្នាំ
    - មានវិស្វករតាមជំនាញ ៦នាក់
    - បទពិសោធន៍លើតម្លៃគម្រោងសរុប ២០,០០០លានរៀល
    - មានដើមទុនយ៉ាងតិច ៤០០លានរៀល ។
- **ប្រភេទទី២ ប្រភេទមធ្យម គឺសហគ្រាស និងក្រុមហ៊ុនសាងសង់ ដែលមានៈ**
    - ស្ថាបត្យករយ៉ាងតិច ១នាក់ មានបទពិសោធន៍ការងារយ៉ាងតិច ៨ឆ្នាំ
    - វិស្វករយ៉ាងតិច ១នាក់ និងមានបទពិសោធន៍យ៉ាងតិច ៨ឆ្នាំ
    - នាយកបច្ចេកទេស និងគម្រោង មានបទពិសោធន៍ ៨ឆ្នាំ
    - មានវិស្វករតាមជំនាញ ៤នាក់
    - បទពិសោធន៍លើតម្លៃគម្រោងសរុប ៤,០០០លានរៀល
    - មានដើមទុនយ៉ាងតិច ១២០លានរៀល ។
- **ប្រភេទទី៣ ប្រភេទតូច គឺសហគ្រាស និងក្រុមហ៊ុនសាងសង់ ដែលមានៈ**
    - វិស្វករ១នាក់ មានបទពិសោធន៍យ៉ាងតិច ៥ឆ្នាំធ្វើជានាយកបច្ចេកទេស
    - មានវិស្វករតាមជំនាញ ២នាក់
    - មានដើមទុនយ៉ាងតិច ២០លានរៀល ។
- **ប្រភេទទី៤ ក្រុមជាងសំណង់**
    - មានស្នាដៃ និងបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច ១០ឆ្នាំ
    - ជាងសំណង់មួយចំនួនសមស្រប ។

---

[28] ប្រកាសលេខ៧៥ ប្រ.ក/ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់, ប្រការ៣

សហគ្រាស និងក្រុមហ៊ុនសាងសង់អាចស្នើសុំតម្លើងឋានៈប្រភេទរបស់ខ្លួន នៅពេលណាដែលសហគ្រាស និងក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ខាងលើ និងមានលិខិតបញ្ជាក់ពីការបង់ពន្ធទៀងទាត់ជូនរដ្ឋ ។

**រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ចែកជា២ផ្នែក៖**[29]

- **រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ផ្នែកស្ថាបត្យកម្ម មានបីកំរិតៈ**
  - កំរិតទី១ ស្ថាបត្យករ មានបទពិសោធន៍លើការងារសិក្សាគម្រោងប្លង់ស្ថាបត្យកម្មយ៉ាងតិច ៧ឆ្នាំ
  - កំរិតទី២ ស្ថាបត្យករ មានបទពិសោធន៍លើការងារសិក្សាគម្រោងប្លង់ស្ថាបត្យកម្មយ៉ាងតិច ៤ឆ្នាំ
  - កំរិតទី៣ ស្ថាបត្យករ មានបទពិសោធន៍លើការងារសិក្សាគម្រោងប្លង់ស្ថាបត្យកម្មយ៉ាងតិច១ឆ្នាំ
- **រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ផ្នែកគ្រឿងផ្គុំសំណង់ មានបីកំរិតៈ**
  - កំរិតទី១ វិស្វករ មានបទពិសោធន៍លើការងារសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់យ៉ាងតិច ៧ឆ្នាំ
  - កំរិតទី២ វិស្វករ មានបទពិសោធន៍លើការងារសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់យ៉ាងតិច ៤ឆ្នាំ
  - កំរិតទី៣ វិស្វករ មានបទពិសោធន៍លើការងារសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់យ៉ាងតិច ១ឆ្នាំ

## វាក្យខណ្ឌទី២៖ បែបបទនៃការស្នើសុំប្រកបអាជីវកម្ម និងការចុះបញ្ជី

ដើម្បីរក្សានូវ សណ្តាប់ធ្នាប់របៀបរៀបរយលើការសាងសង់ ធានានូវគុណភាពនៃសំណង់ និងការអនុវត្តនៃរាល់សហគ្រាស ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ការសាងសង់ និងក្រុមជាងសាងសង់ឱ្យមានភាពស្របច្បាប់ ក្រសួងបានចេញប្រកាសលេខ៧៥ ប្រក ដ.ន.ស ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រង សហគ្រាស និងក្រុមហ៊ុន សិក្សាគម្រោងប្លង់ និងសាងសង់ បានកំណត់ឱ្យសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ទាំងអស់ អាចដំណើរការការងាររបស់ខ្លួនបាន លុះត្រាតែមានវិញ្ញាបនបត្រប្រកបអាជីវកម្មដែលផ្តល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

### ក. ការស្នើសុំប្រកបអាជីវកម្ម

នៅពេលដែលខ្លួនទទួលបាននូវ កិច្ចការសិក្សាគម្រោងប្លង់ និងសាងសង់ពីសំណាក់ដៃគូអាជីវកម្មរបស់ពួកគេ លើគម្រោងលំនៅឋាន សំណង់អគារស្នាក់នៅ ការិយាល័យ លំនៅឋានសហគមន៍ជាបុរី ឬសិក្សាទៅលើគម្រោងប្លង់ និងសាងសង់នានា សហគ្រាស និងក្រុមហ៊ុន សិក្សាគម្រោងប្លង់ និងសាងសង់ទាំងអស់ត្រូវស្នើសុំធ្វើការប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ជាមុនសិន ដែលតម្រូវឱ្យប្រធានសហគ្រាស និងក្រុមហ៊ុនត្រូវតែមកដាក់ពាក្យសុំដោយខ្លួនឯងផ្ទាល់ ហើយនាយកបច្ចេកទេសនៃសហគ្រាស និងក្រុមហ៊ុន ត្រូវតែមាន

[29] ប្រកាសលេខ ១៩២ ប្រក.ដនស/អសណ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់, ប្រការ ៦

សញ្ជាតិខ្មែរ ។ ទម្រង់បែបបទសុំប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ត្រូវមានលក្ខខណ្ឌដូចជា៖[30]

- ពាក្យសុំប្រកបអាជីវកម្ម ចំនួន ៣ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់ប្រធានសហគ្រាស និងក្រុមហ៊ុនដោយមានបិទរូបថតទំហំ ៤x៦ ចំនួន ៣ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន របស់ប្រធានសហគ្រាស និងក្រុមហ៊ុន ចំនួន ៣ច្បាប់
- លិខិតបញ្ជាក់អំពីទីលំនៅរបស់ប្រធានសហគ្រាស និងក្រុមហ៊ុន ពីសាលឃុំ សង្កាត់ ចំនួន ១ច្បាប់
- ជីវប្រវត្តិរបស់នាយកបច្ចេកទេសដោយមិនបិទរូបថត ចំនួន៣ច្បាប់
- លក្ខន្តិកៈរបស់សហគ្រាស និងក្រុមហ៊ុនដែល មានការបញ្ជាក់ពីនៅសាលាខេត្ត ក្រុងចំនួន ៣ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាស និងក្រុមហ៊ុន និងសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម ចំនួន ៣ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាស ក្រុមហ៊ុន និងអ្នកបច្ចេកទេស ដែលជានាយកបច្ចេកទេស ឬនាយកគម្រោង ចំនួន ៣ច្បាប់
- ច្បាប់ចម្លងសញ្ញាបត្ររបស់អ្នកបច្ចេកទេស ដែលបានធ្វើនីត្យានុកូលកម្ម នៅសាលាខេត្តក្រុង ចំនួន ៣ច្បាប់
- បញ្ជីរាយនាមអ្នកបច្ចេកទេស និងអង្គការលេខរបស់សហគ្រាស និងក្រុមហ៊ុន ចំនួន ៣ច្បាប់
- បញ្ជីសម្ភារៈបរិក្ខាសិក្សាគម្រោងប្លង់សម្រាប់សហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោង ប្លង់ ចំនួន ៣ច្បាប់
- ឯកសារបញ្ជាក់ដើមទុនពីធនាគារ សម្រាប់សហគ្រាស និងក្រុមហ៊ុនចុះបញ្ជីលើកដំបូង ចំនួន ១ច្បាប់
- បង្កាន់ដៃបង់ពន្ធអាករ ឬប័ណ្ណប៉ាតង់ សម្រាប់សហគ្រាស និងក្រុមហ៊ុនសុំបន្តសុពលភាព ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម សម្រាប់សហគ្រាស និងក្រុមហ៊ុនចុះបញ្ជីលើកដំបូង ចំនួន ១ច្បាប់
- ឯកសារបង្កាន់ដៃ សម្រាប់សហគ្រាស និងក្រុមហ៊ុនប្រទេសទី១ ទី២ ចំនួន ៣ច្បាប់ ។

ក្រោយពេលទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មរួចហើយ សហគ្រាស ក្រុមហ៊ុន សិក្សាគម្រោងប្លង់ និងសាងសង់ អាចយកទៅប្រើប្រាស់តាមតម្រូវការ និងភាពចាំបាច់របស់ខ្លួន ឱ្យស្របទៅតាមព្រំដែនកម្រិតនៃច្បាប់ដែលកំណត់ ។ រីឯសុពលភាព[31]នៃលិខិតអនុញ្ញាតប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់នោះមានសុពលភាពរយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម ។

### ខ. ការចុះបញ្ជីពាណិជ្ជកម្ម

រាល់បុគ្គលដែលមានបំណងចង់រកស៊ី ឬវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា គឺត្រូវឆ្លងកាត់ការចុះ

[30] ប្រកាសលេខ៧៥ ប្រ.ក/ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់, ប្រការ៧ ថ្មី

[31] ប្រកាសលេខ៧៥ ប្រ.ក/ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់, ប្រការ១០ថ្មី

បញ្ជីពាណិជ្ជកម្មជាមុនសិន ទើបអាចស្នើសុំនូវអាជ្ញាប័ណ្ណជាបន្តបន្ទាប់ទៀត រហូតដល់អាចបើកការសាងសង់ទៅលើគម្រោងវិនិយោគរបស់ខ្លួន ។ ការចុះបញ្ជីពាណិជ្ជកម្មដើម្បីធានាឱ្យបាននូវភាពស្របច្បាប់របស់ក្រុមហ៊ុនអ្នកវិនិយោគរួមមានឈ្មោះក្រុមហ៊ុន ប្រភេទក្រុមហ៊ុន(ឯកកម្មសិទ្ធ, សហកម្មសិទ្ធ, ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនបរទេសជាដើម...) ផលិតផលនិងសេវាកម្មរបស់ក្រុមហ៊ុន ។[32] លក្ខខណ្ឌនៃការចុះបញ្ជីពាណិជ្ជកម្មអ្នកវិនិយោគត្រូវបំពេញនូវសំណុំឯកសារតាមបែបបទដែលក្រសួងបានកំណត់ បន្ទាប់ពីបំពេញរួចរាល់តម្រូវឱ្យបង់ថ្លៃសេវាក្នុងការសិក្សាសំណុំឯកសារចុះបញ្ជី នៅពេលដែលការចុះបញ្ជីពាណិជ្ជកម្មបានសម្រេចនោះ នឹងទទួលបានលិខិតបញ្ជាក់ពីការចុះបញ្ជី ។[33]

[32] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៥

[33] ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩

# ជំពូក ២
# របបគតិយុត្តនៃការគ្រប់គ្រង
# សំណល់នៅកម្ពុជា
# ២០០៨-បច្ចុប្បន្ន

# ជំពូក ២
# របបគតិយុត្តនៃការគ្រប់គ្រងសំណង់
# (សិក្សាពីឆ្នាំ២០០៨-បច្ចុប្បន្ន)

## ផ្នែកទី១៖ វិធាន ឬបទដ្ឋានគតិ និងទទួលបន្ទុកគ្រប់គ្រងសំណង់នៅកម្ពុជា

### កថាខណ្ឌទី១៖ ខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្ត គ្រប់គ្រងលើវិស័យសំណង់

ដោយសារខឿនសេដ្ឋកិច្ចមានការរីកចម្រើនជាលំដាប់ ជាកត្តាមួយជំរុញឱ្យមានការវិវត្តន៍នៃវិស័យសំណង់បានរីកដុះដាលឥតស្រាកស្រាន្តពីមួយថ្ងៃទៅមួយថ្ងៃ ។ ទន្ទឹមនឹងកំណើននៃការរីកដុះដាលនេះផងដែរ រដ្ឋាភិបាលកម្ពុជាក៏បានសម្លឹងឃើញពីភាពលំបាក និងផលប៉ះពាល់ដែលជះឥទ្ធិពលនាពេលអនាគតបណ្តាលមកពីកង្វះនៃបទដ្ឋានគតិយុត្ត ការណ៍នេះជាមូលហេតុចាំបាច់តម្រូវឱ្យមានវិធានច្បាប់ដើម្បីសម្រួលដល់ដំណើរការនៃការសាង-សង់ ពិសេសធានានូវភាពស្របច្បាប់នូវសំណង់ ។ ច្បាប់នេះបង្កើតមានគោលបំណង៖

- រៀបចំឱ្យមានសណ្តាប់ធ្នាប់ សុវត្ថិភាពសំណង់ប្រកបដោយគុណភាព
- សោភណ្ឌភាព និងបរិស្ថានប្រកបដោយចីរភាព
- លើកកម្ពស់សុខុមាលភាពសំណង់សាធារណៈ
- ប្រសិទ្ធភាពការងារប្រកបដោយអ្នកជំនាញវិជ្ជាជីវៈ
- បង្កើនការទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់
- ជម្រុញផ្នែកទីផ្សារអចលន និងជម្រុញផ្នែកទីផ្សារសេដ្ឋកិច្ច
- គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធសំណង់អគារប្រកបដោយគុណភាព និងស្របតាមច្បាប់។

ការបង្កើតច្បាប់នេះមានគោលការណ៍ បទប្បញ្ញត្តិ វិធាន និងនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជានិងមានវិសាលភាពក្នុងការអនុវត្តចំពោះសំណង់គ្រប់ប្រភេទលើកលែងសំណងបទដ្ឋានគតិយុត្តដោយឡែក ។ ច្បាប់ស្តីពីសំណង់នេះបានបែកចែកជា ២២ជំពូក និង ១១១មាត្រា ហើយជំពូកនីមួយៗចែកជាច្រើនផ្នែកដែលបង្ហាញពីបទប្បញ្ញត្តិ នីតិវិធី និងវិធានផ្សេងៗដែលច្បាប់បានកំណត់ដែលពាក់ព័ន្ធដូចជា៖

- បទប្បញ្ញត្តិទូទៅ គោលការណ៍
- សមត្ថកិច្ចគ្រប់គ្រង
- បទប្បញ្ញត្តិបច្ចេកទេសសំណង់ និងការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់
- ការគ្រប់គ្រងអ្នកវិជ្ជាជីវៈ និងការប្រកបអាជីវកម្មក្នុងវិស័យសំណង់
- ការប្រើសម្ភារៈ គ្រឿងបរិក្ខារសំណង់ ផលិតផល និងមន្ទីរពិសោធន៍
- លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ និងការគ្រប់គ្រងគម្រោងប្លង់
- ការគ្រប់គ្រងការងារសាងសង់ឬរុះរើ និងការប្រើប្រាស់សំណង់
- សំណង់ដែលមានសភាពគ្រោះថ្នាក់
- សំណង់ដែលសាងសង់ ឬរុះរើដោយគ្មានលិខិតអនុញ្ញាត
- អធិការកិច្ចសំណង់ និង វិសមិតភាព
- កិច្ចសន្យាម៉ៅការសាងសង់ ឬរុះរើ

- ការធានារ៉ាប់រង និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់
- ពាក់ព័ន្ធនិងការដោះស្រាយវិវាទ និងបណ្ដឹងតវ៉ា
- ការដោះស្រាយវិវាទពាក់ព័ន្ធ និងការអនុវត្តសិទ្ធបុគ្គលក្នុងវិស័យសំណង់ និងកិច្ចសន្យាម៉ៅការសាងសង់ រ៉ុះរើ។

## កថាខណ្ឌទី២៖ ស្ថាប័នគ្រប់គ្រងលើវិស័យសំណង់

### វាក្យខណ្ឌទី១៖ ក្រសួងដែនដីនគរូបនីយកម្ម និង សំណង់

ក្រសួងដែនដីនគរូបនីយកម្ម និង សំណង់ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៩ ក្នុងបេសកម្មឱ្យដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដីនគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ។ ក្នុងបេសកម្មការងារនគរូបនីយកម្ម និងសំណង់ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ត្រូវធ្វើការស្រាវជ្រាវ វិភាគ និងចងក្រងស្ថិតិទាំងឡាយទាក់ទងការងារនគរូបនីយកម្ម និងសំណង់ ។ សំណើនយោបាយ ផែនការ និងសកម្មភាព និងវិធានការសម្រាប់ការដោះស្រាយសំណង់អនាធិបតេយ្យ និងការសាងសង់លំនៅស្ថានដោយរក្សាទេសភាព និងការពារបរិស្ថាន ។ កំណត់វិធានទាំងឡាយ ហើយចេញលិខិតអនុញ្ញាត និងការយល់ព្រមដែលទាក់ទង ។ ជំរុញការសាងសង់ដោយមានការយកចិត្តទុកដាក់ និងថែទាំអគារសាធារណៈរួមជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីការពារបេតិកភណ្ឌ ដើម្បីការពារបេតិកភណ្ឌ និងរមណីយដ្ឋានប្រវត្តិ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរចនាសម្ព័ន្ធដូចតទៅ:[34]

១. ថ្នាក់កណ្ដាល

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អធិការដ្ឋាន
- អគ្គនាយកដ្ឋានរដ្ឋបាលរួមមាន៖
    - នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
    - នាយកដ្ឋានបុគ្គលិក
    - នាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច
    - នាយកដ្ឋាននីតិកម្ម
    - នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ
- អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម រួមមាន៖
    - នាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិ

[34] អនុក្រឹត្យលេខ ៦២ អនក្រ/បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, មាត្រា៤

- នាយកដ្ឋាន រៀបចំដែនដី
- នាយកដ្ឋាន នគរូបនីយកម្ម

- អគ្គនាយកដ្ឋានសំណង់ រួមមាន៖

- នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់
- នាយកដ្ឋាន សិក្សាគម្រោងប្លង់
- នាយកដ្ឋាន សំណង់

- អគ្គនាយកដ្ឋាន សុរិយោដី និងភូមិសាស្ត្រ រួមមាន៖

- នាយកដ្ឋានគ្រប់គ្រងដី
- នាយកដ្ឋានអធិការកិច្ចភូមិបាល
- នាយកដ្ឋានបច្ចេកទេស
- នាយកដ្ឋានអភិរក្សសុរិយោដី
- នាយកដ្ឋានភូមិសាស្ត្រ

- មន្ទីរពិសោធន៍

- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

- គ្រឹះស្ថាន និងសហគ្រាសក្រោមឱវាទ

- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

២. អង្គភាពមូលដ្ឋានៈ

- មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង

- ការិយាល័យរៀបចំដែនដីនគរូបនីយម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ

**ក. អគ្គនាយកដ្ឋានសំណង់**

អគ្គនាយកដ្ឋានសំណង់ មានភារកិច្ចជាសេនាធិការឱ្យក្រសួង លើការងារទាំងឡាយពាក់ព័ន្ធនឹងវិស័យសំណង់ ។ តាមរយៈការត្រួតពិនិត្យលក្ខណៈវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសផ្នែកសំណង់ និងស្ថាបត្យកម្ម រួមទាំងស្តង់ដារសម្ភារៈបរិក្ខារសំណង់ដោយធ្វើការតម្រង់ទិស ណែនាំ តាមដាន ត្រួតពិនិត្យការសាងសង់ ការជួសជុល ការថែទាំ ការរុះរើ រាល់បណ្តាគម្រោងសំណង់អគាររបស់រដ្ឋ ឯកជន អង្គការនានា រួមទាំងសំណង់បេតិកភ័ណ្ឌ និងសំណង់ផ្សេងៗទៀត ។ ការតម្រង់ទិស ណែនាំ តាមដាន ត្រួតពិនិត្យការសាងសង់ ខាងលើនេះ ត្រូវបានគ្រប់គ្រង ពិនិត្យ និងកំណត់សមត្ថភាពបច្ចេកទេសវិជ្ជាជីវៈ តាមរយៈការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលធ្វើអាជីវកម្មទាក់ទងនឹងការសាងសង់ និងការសិក្សា

គម្រោងប្លង់ ។ ដោយឡែកការត្រួតពិនិត្យ និងដាក់ឱ្យធ្វើការពិសោធន៍ សម្ភារៈសំណង់ ដោយកំណត់នូវស្តង់ដារគុណភាព សម្ភារៈ បរិក្ខារសំណង់ ដែលនាំចូលមកពីបរទេស និងផលិតក្នុងប្រទេស ត្រូវធ្វើតាមរយៈការលើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងស្ថាបត្យកម្ម ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីត្រួតពិនិត្យបណ្តាលគម្រោងវិនិយោគសំណង់ ។

អគ្គនាយកដ្ឋានសំណង់ត្រូវបានដឹកនាំដោយ អគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការតាមការចាំបាច់ ព្រមទាំងបែងចែកជា ៣នាយកដ្ឋានដែលមានតួនាទីដូចខាងក្រោម៖[35]

**១. នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់**

នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសំណង់មានតួនាទីធ្វើការស្រាវជ្រាវ កសាង បទបញ្ញត្តិ ទម្រង់ក្បួនខ្នាតលក្ខណៈវិនិច្ឆ័យបច្ចេកទេស បទដ្ឋានបច្ចេកទេសផ្នែកសំណង់ ដោយកំណត់នូវស្តង់ដារ សម្ភារៈ បរិក្ខារសំណង់ ដោយចូលរួមធ្វើការផ្តល់យោបល់ពីគុណភាព តម្រូវការ សំណង់ និងសម្ភារៈបរិក្ខារគ្រឿងចក្រ ដែលនាំចូលពីបរទេស និងក្នុងស្រុកតាមរយៈការផ្លាស់ប្តូរពាណិជ្ជកម្ម ព្រមទាំងចងក្រងបណ្តាបញ្ជីតម្លៃសម្ភារៈ គ្រឿងចក្រ និងពលកម្ម និងតាមដានជាប្រចាំនូវការប្រែប្រួលថ្លៃតាមទីផ្សារផងដែរ ។ម្យ៉ាងវិញទៀត នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ត្រួតពិនិត្យ និងធ្វើការពិសោធន៍សម្ភារៈ គ្រឿងផ្គុំសំណង់ ព្រមទាំងស្រាវជ្រាវ បង្កើតមុខសម្ភារៈសំណង់ថ្មីៗ និងស្រាវជ្រាវជាប្រចាំនូវមុខសម្ភារៈផលិតចេញថ្មីៗ គ្រឿងចក្រ ដែលបម្រើឱ្យការសាងសង់ ។ នាយកដ្ឋាននេះក៏ត្រូវសហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងបណ្តាមន្ទីរខេត្ត-ក្រុង ដោយធ្វើការអប់រំផ្សព្វផ្សាយឯកសារបច្ចេកទេសសំណង់ ក្នុងគោលបំណងលើកស្ទួយប្រសិទ្ធភាពសេដ្ឋកិច្ច សុវត្ថិភាព សុខុមាលភាពសាធារណៈ និងណែនាំដល់បណ្តាគ្រឹះស្ថានបណ្តុះបណ្តាលមុខវិជ្ជាសំណង់ និងស្ថាបត្យកម្ម ។ នាយកដ្ឋាននេះដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**២. នាយកដ្ឋានសិក្សាគម្រោងប្លង់**

នាយកដ្ឋាននេះមានតួនាទីសិក្សាគម្រោងប្លង់សាងសង់ថ្មី ជួសជុល កែលំអពង្រីកអគាររបស់បណ្តាក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីខេត្ត ក្រុង ដែលប្រើប្រាស់ថវិការបស់រដ្ឋ ឯកជន អ្នកវិនិយោគទុនក្នុងប្រទេស ឬ ក្រៅប្រទេស និងអង្គការនានាទាំងជាតិ និងអន្តរជាតិ ។ ការសិក្សា ស្រាវជ្រាវ ធ្វើគម្រោងប្លង់ ដែលចែកចេញជាផ្នែក ឯកសារបច្ចេកទេស ស្ថាបត្យកម្ម និងផ្នែកគំនូរប្លង់ សិក្សាស្រាវជ្រាវគម្រោងប្លង់ និងធ្វើបញ្ជីប៉ាន់ស្មាន

[35] អនុក្រឹត្យលេខ ៦២ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, មាត្រា១៧, មាត្រា១៨, មាត្រា១៩, មាត្រា២០

សម្ភារៈនៃគម្រោងសំណង់សាធារណៈត្រួតពិនិត្យគម្រោងប្លង់ស្ថាបត្យកម្ម និងបច្ចេកទេសសំណង់អគារត្រួតពិនិត្យសៀវភៅបន្ទុកនៃការដ្ឋានសាងសង់ត្រួតពិនិត្យបណ្ដាគម្រោងប្លង់អ្នកវិនិយោគនានា អំពីតម្រូវការពិតនៃសម្ភារៈសំណង់នាំចូលជារូបិយប័ណ្ណគ្រប់គ្រង ត្រួតពិនិត្យ និងកំណត់សមត្ថភាពបច្ចេកទេស និងចេញលិខិតអនុញ្ញាតបើកអាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលធ្វើអាជីវកម្មទាក់ទងនឹងការសិក្សាធ្វើគម្រោងប្លង់ និងការសាងសង់ ។ នាយកដ្ឋាននេះដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**៣. នាយកដ្ឋានសំណង់ មានតួនាទី និងភារកិច្ច ដូចតទៅ៖**

នាយកដ្ឋានសំណង់ណែនាំ តាមដាន និងត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការសាងសង់ រុះរើ តាមតំណាក់កាលនីមួយៗដើម្បីធានាសុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈ គុណភាពសំណង់ចេញលិខិតអនុញ្ញាតបើកនិងបិទការដ្ឋានរបស់បណ្ដាសហគ្រាស ក្រុមហ៊ុន អង្គភាពសាងសង់នានាចូលរួមធ្វើកោសល្យវិច័យនានាផ្ដល់សំណុំឯកសារបច្ចេកទេសដល់ស្ថាប័នមានសមត្ថកិច្ចក្នុងករណីវិវាទបញ្ហាសាងសង់ រុះរើ បាក់ស្រុត និងករណីបទល្មើសផ្សេងទៀត ដែលផ្ទុយនឹងបទដ្ឋានបច្ចេកទេសសិក្សាលើបច្ចេកទេសសាងសង់ទំនើប រឹងមាំ មានប្រសិទ្ធភាព ជាសកល និងឆាប់រហ័សដែលកំពុងត្រូវប្រើប្រាស់នៅប្រទេសនានា ពិសេសបណ្ដាប្រទេសអាស៊ានរៀបរៀងបទប្បញ្ញត្តិ សេចក្ដីណែនាំក្នុងការជួសជុលថែទាំ ប្រើប្រាស់ សំណង់អគារសាធារណៈ និងបេតិកភ័ណ្ឌតាក់តែងកម្មវិធី និងកសាងគម្រោងថវិកាជួសជុល ថែទាំធំៗ ព្រមទាំងធានាអំពីលក្ខណៈបច្ចេកទេសសំណង់តាមកិច្ចសន្យាស្រង់ស្ថិតិ វិភាគទិន្នន័យសេដ្ឋកិច្ច តម្លៃវប្បធម៌ ក្នុងការប្រើប្រាស់អគារសាធារណៈ និងបេតិកភ័ណ្ឌណែនាំត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការជួសជុល កែសម្រួល ដើម្បីធានាសុវត្ថិភាពសណ្ដាប់ធ្នាប់សាធារណៈ ប្រសិទ្ធភាពសេដ្ឋកិច្ច សោភ័ណភាព គុណភាពសំណង់នៃគ្រប់បណ្ដាសំណង់សាធារណៈ និងគ្រប់បណ្ដាសំណង់បេតិកភ័ណ្ឌ ។ នាយកដ្ឋាននេះដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ខ. មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានី ខេត្ត

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ត្រូវបានបង្កើតឡើងដើម្បីធានានូវប្រសិទ្ធិភាពការងារ នៅថ្នាក់ក្រោមជាតិ ដែលមានតួនាទី និងមានភារកិច្ចដូចជា៖

- អនុវត្តគោលនយោបាយ និងទិសដៅការងាររបស់ក្រសួងរួមមាន ការងាររៀបចំដែនដី ការងាររបស់ក្រសួងរួមមាន ការងារនគរូបនីយកម្ម ការងារសំណង់ ការងារភូមិសាស្ត្រ រក្សានូវតុល្យភាពនិងស្ថេរភាពសំដៅដល់ការការពារផលប្រយោជន៍ និងសណ្ដាប់ធ្នាប់សាធារណៈ លើកកម្ពស់សោភណភាព សម្បត្តិធម្មជាតិ និងវប្បធម៌។ ចងក្រងឯកសារទិន្នន័យពាក់ព័ន្ធ អនុវត្តបទប្បញ្ញត្តិ លខិតបទដ្ឋានបច្ចេកទេសនានា ក៏ដូចជាផ្ដល់យោបល់ និងពិនិត្យលើការស្នើសុំទីតាំងសាងសង់ដែលសហការជាមួយអាជ្ញាធរ

ដែនដី អង្គការជាតិ និងអន្តរជាតិ ព្រមទាំងចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ និងគ្រឿងបរិក្ខារ សម្ភារ និងគ្រឿងផ្សំសំណង់។

- គ្រប់គ្រង ត្រួតពិនិត្យការសិក្សាស្រាវជ្រាវគម្រោងប្លង់ និសំណង់ក្នុងសមត្ថកិច្ចរបស់ខ្លួន និងតាមការប្រគល់ភារកិច្ចពីក្រសួងដោយចេញលិខិតអនុញ្ញាតបើក ផ្អាក និងបឹទអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ដល់រូបវន្តបុគ្គល និងក្រុមជាង ព្រមទាំងលើកផែនការបណ្តុះបណ្តាលមន្ត្រី និងណែនាំការងាររៀបចំបើក បិទការដ្ឋាន និងចេញលិខិតអនុញ្ញាតសាងសង់។
- តាមដានអនុវត្តបទប្បញ្ញត្តិ សេចក្តីណែនាំរបស់ក្រសួងក្នុងការថែទាំ ជួសជុល ប្រើប្រាស់សំណង់អាគារ សំណង់ការ្យ និងបេតិកភណ្ឌដោយគ្រប់គ្រងលើដីធ្លីគ្រប់ប្រភេទ វាស់វែង គណនាឋានលេខា ស្ថានភាពដី ក្បាលដីក្នុងក្របខណ្ឌសមត្ថកិច្ច និងទំនួលខុសត្រូវរដ្ឋបាល និងកសាងប្លង់ដីគ្រប់ប្រភេទ ព្រមទាំងចូលរួមសិក្សា និងកសាងឯកសារពន្ធអាករដី និងគម្រោងចំណូលពន្ធអាករដីប្រចាំឆ្នាំទូទាំងរាជធានីខេត្តក្នុងសមត្ថកិច្ចរបស់ខ្លួន។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្តមានការិយាល័យក្រោមឱវាទដូចជាៈ

- ការិយាល័យរដ្ឋបាល
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ការិយាល័យសុរិយោដី និងភូមិសាស្ត្រ ។

**គ. ការិយាល័យរៀបចំដែនដី គនរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក ខណ្ឌ**

ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក/ខណ្ឌ មានតួនាទី និងភារកិច្ច ៖

- ជាសេនាធិការឱ្យមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ ក្នុងការអនុវត្តផ្ទាស់ និង ជាក់ស្តែងលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ
- ពិនិត្យជាក់ស្តែងរាល់សំណើសុំសាងសង់ និងជួសជុលសំណង់ ដើម្បីធ្វើរបាយការណ៍បច្ចេក-ទេស
- តាមដាន ត្រួតពិនិត្យការអនុវត្តលិខិតសាងសង់ រុះរើ និងជួសជុល
- ពិនិត្យធ្វើរបាយការណ៍បច្ចេកទេសលើបណ្តាវិវាទផ្ទះសំបែង
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអង្កេតវាស់វែង ប្រមូលផ្តុំឯកសារក្នុងក្របខណ្ឌស្រុក/ខណ្ឌក្នុងដែនសមត្ថកិច្ចដែលបានកំណត់
- ចុះបញ្ជីអចលនវត្ថុតាម ស្រុក ខណ្ឌ ឃុំ សង្កាត់
- គ្រប់គ្រងក្រុមការងារលិខិតចេញចូល បញ្ជូនឯកសារ សរុបរបាយការណ៍តាមរបបកំណត់ ។

ការិយាល័យនេះចាំបាច់ត្រូវមានប្រធានមួយរូប និងអនុប្រធានជាជំនួយការជាចាំបាច់ ។

**វាក្យខណ្ឌទី២៖ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត**

ការសាងសង់នូវសំណង់មួយពុំមែនមានពាក់ព័ន្ធតែនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អាជ្ញាធរដែនដី ប៉ុណ្ណឹងនោះទេ គឺចាំបាច់ត្រូវតែមានការចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធដទៃដោយខានមិនបាន ដើម្បីពិនិត្យ និងធ្វើការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយក្នុងគោលបំណងបញ្ចៀសនូវហានិភ័យ និងផលវិបាកផ្សេងៗ ។

ក្នុងន័យខាងលើនេះ មានន័យថាដើម្បីសាងសង់នូវសំណង់មួយបានចាំបាច់ត្រូវសហការជាមួយក្រសួងបរិស្ថានដើម្បីពិនិត្យនូវបញ្ហាដែលអាចកើតមានពីសំណង់ដែលនឹងត្រូវបានសាងសង់នោះមានផលប៉ះពាល់ដល់បរិស្ថានដែលឬយ៉ាងណា? ។ មួយវិញទៀត គម្រោងសាងសង់មួយចៀសមិនផុតពីមានផ្លូវក្នុងការធ្វើដំណើរដោយខានមិនបានឡើយ ជាកត្តាមួយដែលចាំបាច់ត្រូវតែធ្វើការសហការជាមួយនឹងក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងការពិនិត្យពីលទ្ធភាពនៃការប្រើប្រាស់ផ្លូវ និងគម្លាតនៃការសាងសង់ចាំបាច់ត្រូវប្រើចម្ងាយណាពីផ្លូវជាដើម ។-ល-។

### ក. ក្រសួងបរិស្ថាន

រាល់ការសាងសង់នូវសំណង់ទាំងអស់ ចាំបាច់ត្រូវតែមានការវាយតម្លៃពីផលប៉ះពាល់ដល់បរិស្ថាន ។ ក្រសួងបរិស្ថានត្រូវតែធ្វើការត្រួតពិនិត្យ និងផ្តល់ការវាយតម្លៃលើបញ្ហាបរិស្ថាន ទៅអង្គភាពមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។ រាល់ពាក្យសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថាន មុនពេលដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចសម្រេច ។[36]

ការវាយតម្លៃហេតុបរិស្ថាននេះដែរ ក៏ត្រូវអនុវត្តចំពោះសំណង់ដែលមានស្រាប់ និងកំពុងដំណើរការសាងសង់ដែលមិនទាន់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ ប្រភេទ និងទំហំគម្រោង និងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។[37]

ដោយឡែក ប្រព័ន្ធលូ និងការបញ្ចេញនូវទឹកកង្វក់ក៏ជាបញ្ហាមួយដែលមិនគួរមើលរំលងផងដែរ ព្រោះតែគ្រប់គម្រោងសំណង់ទាំងអស់ គឺសុទ្ធសឹងតែមានការរៀបចំឱ្យប្រព័ន្ធលូ និងប្រព័ន្ធទឹកកខ្វក់ ក្រសួងបរិស្ថានមានភារកិច្ចរៀបចំគោលនយោបាយ ឬផែនការយុទ្ធសាស្ត្រ ស្តង់ដារបញ្ចេញទឹកកខ្វក់ និងស្តង់ដារទឹកសម្អាត សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ឬដៃគូរអភិវឌ្ឍន៍ និងវិស័យឯកជនលើការងារវិនិយោគ ផ្សព្វផ្សាយ និងអប់រំដល់សាធារណជនអំពីសេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ក្នុងគោលដៅការពារគុណភាពបរិស្ថាន ។[38] មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវចុះពិនិត្យវាយតម្លៃ និងផ្តល់យោបល់លើការបំពាក់បរិក្ខារ ដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម និងតាមទីតាំងផ្ទាល់ ព្រមទាំងយកសំណាកទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តកម្មរួចមកធ្វើវិភាគជាប្រចាំ ។[39]

ជាមួយគ្នាផងដែរ មន្ទីរបរិស្ថាន រាជធានី ខេត្ត ត្រូវតែមានកិច្ចសហការនឹងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង

[36] មាត្រា ៧ នៃច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

[37] មាត្រា ៦ នៃច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

[38] អនុក្រឹត្យលេខ២៣៥ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, មាត្រា៦

[39] អនុក្រឹត្យលេខ២៣៥ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, មាត្រា៣៣

ត្រូវចុះទៅធ្វើអធិការកិច្ចដោយផ្ទាល់ទៅកន្លែងដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងករណី៖[40]

- ការលួចបញ្ចេញទឹកកខ្វក់ពីទីតាំងចូលក្នុងតំបន់ទឹកសាធារណៈ ទោះផ្ទាល់ ឬប្រយោល ដោយមិនមានលិខិតអនុញ្ញាត និងការលួចបញ្ចេញពីទីតាំងដោយពុំឆ្លងកាត់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- បណ្ដឹង ឬការទទួលបានព័ត៌មានពីការបំពុលតំបន់ទឹកសាធារណៈពីការបញ្ចេញទឹកកខ្វក់ ។

### ខ. ក្រសួងសាធារណការ និងដឹកជញ្ជូន

ដោយឡែកយោងតាមស្មារតីនៃមាត្រា១១ និងមាត្រា៥ មាត្រា៦ នៃអនុក្រឹត្យលេខ១៩៧ អនក្រ.បក ស្ដីពីការគ្រប់គ្រងដីចំណីតាមបណ្ដោញផ្លូវជាតិ និងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសាធារណៈការ និងដឹកជញ្ជូន ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មានសមត្ថកិច្ចគ្រប់គ្រង និងប្រើប្រាស់ដីចំណីផ្លូវជាតិ និងផ្លូវរថភ្លើង ដើម្បីបម្រើផលប្រយោជន៍ដល់អ្នកប្រើប្រាស់ឱ្យមានប្រសិទ្ធិភាព និងគុណភាពល្អនោះ គឺមិនអនុញ្ញាតឱ្យសាងសង់នូវសំណង់ ឬការដាំដំណាំផ្សេងៗនៅតាមចំណីផ្លូវជាតិ និងផ្លូវរថភ្លើងឡើយ ។ ដោយផ្អែកតាមច្បាប់ស្ដីពីផ្លូវថ្នល់ឆ្នាំ២០១៤ ការសាងសង់នូវប្រភេទដូចជា ស្ថានីយប្រេងឥន្ធនៈ ស្ថានីយហ្គាស កន្លែងលាងយានយន្ត ឬសំណង់ប្រហាក់ប្រហែលផ្សេងៗទៀត ដែលមានមនុស្សជួបជុំគ្នាមធ្យម ត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិច ១៥ (ដប់ប្រាំ)ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវ ។ ឯចំពោះសំណង់មជ្ឈមណ្ឌលពាណិជ្ជកម្ម ពហុកីឡដ្ឋាន ទីលានប្រកួត រោងមហោស្រព មន្ទីរពេទ្យ គ្រឹះស្ថានសិក្សា ការរៀបចំផ្សារ ផ្សារណាត់ ពិព័រណ៍ទំនិញ ឬកិច្ចការផ្សេងទៀតដែលមានមនុស្សជួបជុំគ្នាច្រើន ត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិចបំផុត៥០ (ហាសិប)ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវថ្នល់ ។ ប៉ុន្តែការកំណត់ខាងលើនេះមិនអនុវត្តចំពោះរាល់សំណង់ដែលបានសាងសង់ពីមុនពេលបទប្បញ្ញត្តិចូលធរមានឡើយ ហើយអនុវត្តចំពោះតែផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ចំណែកផ្លូវជនបទត្រូវបានកំណត់ដោយអនុក្រឹត្យដោយឡែក ។[41] លិខិតអនុញ្ញាតសាងសង់នឹងមិនផ្ដល់ជូនឡើយចំពោះដីទាំងឡាយដែលពុំមានផ្លូវចេញ-ចូល ដូចជាៈ ផ្លូវសាធារណៈ ផ្លូវឯកជន ច្រកផ្លូវ ឬផ្លូវឆ្លងកាត់ ដែលមានសមាមាត្រមិនសមស្របទៅនឹងទំហំ និងការប្រើប្រាស់នៃអគារ ។ រាល់ផ្លូវ ផ្លូវឆ្លងកាត់ ច្រកផ្លូវ សម្រាប់ប្រើប្រាស់ចំពោះសំណង់មួយ ឬច្រើន ពុំអាចមានទទឹងតិចជាង ៣,៥០ម៉ែត្រ ដែលជាទំហំចាំបាច់សម្រាប់ឱ្យរថយន្តពន្លត់អគ្គិភ័យចូលបាន ។[42] មួយវិញទៀតក្រសួងសាធារណៈការ និងដឹកជញ្ជូនមានតួនាទីត្រួតពិនិត្យប្លង់លំអិតគ្រឿងផ្គុំសំណង់របស់ម្ចាស់សំណង់ដែលទទួលបានលិខិតអនុញ្ញាតសាងសង់មុនពេលបើកការដ្ឋានសាងសង់ ។[43]

### គ. អាជ្ញាធរដែនដី៖ សាលារាជធានីភ្នំពេញ

ដោយសាររាជធានីភ្នំពេញជាមជ្ឈមណ្ឌលនៃក្បាលម៉ាស៊ីនដឹកនាំនយោបាយ ដែលមានប្រព័ន្ធគមនាគមន៍ធំៗសំខាន់ៗ និងមានបរិក្ខារសាធារណៈច្រើន ធ្វើឱ្យរាជធានីភ្នំពេញមានភាពទាក់ទាញ និងចំណាប់អារម្មណ៍ដល់វិនិយោគិនជាច្រើន រហូតមកដល់បច្ចុប្បន្នរាជធានីភ្នំពេញមានការរីកដុះដាលយ៉ាងខ្លាំងនូវវិស័យហេដ្ឋារចនាសម្ព័ន្ធ ដោយសង្កេតឃើញមានវត្តមាននូវស្ថាបត្យកម្មសម័យទំនើប ក៏ដូចជាអគារប្រណិត (ខុនដូ អាផាតមិន...)

[40] អនុក្រឹត្យលេខ២៣៥ អនក្រ.បក ស្ដីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, មាត្រា៣៤

[41] មាត្រា៣០ នៃច្បាប់ស្ដីពីផ្លូវថ្នល់ ឆ្នាំ២០១៤

[42] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា ២៩

[43] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា ៩, ចំណុច ៩.១០

សំណង់លំនៅឋានប្រភេទបុរី ផ្ទះល្វែង ភូមិគ្រឹះ...រីកស្គុសស្គាយពាសពេញរាជធានី ។ យោងតាមសេចក្តីប្រកាសព័ត៌មានរបស់សាលារាជធានីភ្នំពេញដែលចុះផ្សាយកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០នេះ តាមរយៈគេហទំព័រផ្លូវការរបស់សាលារាជធានីភ្នំពេញ (www.phnompenh.gov.kh) បានឱ្យដឹងថារយៈពេល៥ខែដើមឆ្នាំ២០២០ រាជធានីភ្នំពេញបានការវិនិយោគលើវិស័យសំណង់ មានចំនួន៥៨៣គម្រោង ក្នុងនោះផ្ទៃក្រឡាសំណង់សរុប ២,៨២១,៣១៧ ម៉ែត្រក្រឡា ដែលមានទុនវិនិយោគសរុប ១,៣៧៥,៦២៨,០៥០ ដុល្លារអាមេរិក ។ សញ្ញាណនេះសបង្ហាញពីការរីកចម្រើនលូតលាស់របស់វិស័យសំណង់នៅរាជធានីភ្នំពេញ ដើម្បីឆ្លើយតបនឹងការរីកចម្រើនឥតស្រាក់ស្រាន្តនេះ អាជ្ញាធរដែនដី ជាពិសេសសាលារាជធានីភ្នំពេញ ដែលទទួលបានការប្រទានសិទ្ធិពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងសស្រាក់សស្រាំក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើវិស័យសំណង់នេះឱ្យមានប្រសិទ្ធិភាព និងប្រសិទ្ធផល តាមការភារកិច្ច និងសមត្ថកិច្ចដែលប្រទានសិទ្ធិដោយក្រសួង និងការកំណត់ដោយច្បាប់ដោយៈ

- ផ្តល់ជូននូវលិខិតអនុញ្ញាតសាងសង់ជូនដល់ម្ចាស់សំណង់ ឬអ្នកតំណាងស្របច្បាប់ដែលទទួលបានការប្រទានសិទ្ធិដោយចុះហត្ថលេខាលើលិខិតអនុញ្ញាតសាងសង់ដែលក្រោមការទទួលខុសត្រូវរបស់ខ្លួន[44]
- ពិនិត្យមើលការដ្ឋានគ្រប់ពេលវេលា និងពិនិត្យប្លង់ដែលបានអនុម័តរួច ក្នុងករណីរកឃើញមានភាពមិនប្រក្រតីអាជ្ញាធរធ្វើការជម្រាបជូនទៅម្ចាស់សំណង់ជាលាយលក្សណ៍អក្សរឱ្យធ្វើការកែតម្រូវក្នុងរយៈពេលកំណត់ ។ ក្នុងករណីពុំអនុវត្ត ឬពុំអនុវត្តត្រឹមត្រូវ អាជ្ញាធរត្រូវធ្វើការផ្អាកការងារ ឬចេញបញ្ជាជាបន្ទាន់ ឬ ប្ដឹងទៅតុលាការមានសមត្ថកិច្ចឱ្យចេញដីកា ប្រញាប់ ដោយផ្អាកការសាងសង់ ឬផ្លាស់ប្ដូរទ្រង់ទ្រាយសំណង់នោះពុំត្រឹមត្រូវ ឬគ្មានច្បាប់អនុញ្ញាត ហើយរាល់បន្ទុកចំណាយជារបស់ម្ចាស់សំណង់ ។ ចំពោះភាពខុសឆ្គងនោះធ្ងន់ធ្ងរ បណ្ដាសម្ភារៈ និងទព្វសម្ភារៈរបស់ការដ្ឋាន អាចត្រូវរឹបអូសតាមបង្គាប់តុលាការ ។[45]
- ពេលបើក និងបិទបញ្ចប់ការដ្ឋាន អាជ្ញាធរមានតួនាទីផ្តល់ជូនលិខិតបើក និងបិទការដ្ឋាន ។ នៅពេលបញ្ចប់ការដ្ឋាន សាលាខណ្ឌ ជាមួយនឹងការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និងសំណង់) អាចត្រួតពិនិត្យភាពត្រឹមត្រូវស្របគ្នារវាងសំណង់ ដែលធ្វើរួចហើយ និងលិខិតអនុញ្ញាតសាងសង់ ដែលបានចេញឱ្យនោះ ។ ក្នុងករណីដែលពុំត្រឹមត្រូវទេ អាជ្ញាធររាជធានី ឬខេត្តអាចបង្ខំម្ចាស់សំណង់ឱ្យកែតម្រូវអគារឱ្យបានត្រឹមត្រូវ ស្របគ្នានឹងលិខិតអនុញ្ញាតសាងសង់ដែលបានចេញឱ្យ បើមិនគោរពតាមទេ សាលារាជធានី ឬខេត្ត ត្រូវប្ដឹងទៅតុលាការមានសមត្ថកិច្ចឱ្យចេញសាលក្រម ឬសាលដីកា ។
- អាជ្ញាធរដែនដី មានកាតព្វកិច្ចចេញវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ មួយជាការចាំបាច់ដោយខានមិនបាន មុនពេលបើកការប្រើប្រាស់ចំពោះបណ្តាអគារដែលសាងសង់នៅក្នុងរមណីយដ្ឋាន

[44] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា ៤

[45] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា ២០

និងទេសភាពធម្មជាតិ ឬក្រុង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ បុរាណសាស្ត្រ បេតិកភណ្ឌ ឬនៅកន្លែងមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រមួយ ។វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនេះផងដែរ ត្រូវបានផ្តល់ចំពោះបណ្តាអគារសម្រាប់ទទួលសាធារណៈជន សណ្ឋាគារ ការិយាល័យ ក៏ដូចជាបណ្តាកន្លែងធ្វើការរបស់អ្នកមានបៀវត្ស ហើយវិញ្ញាបនបត្រនេះដែលត្រូវទទួលបានមុនពេលបើកការប្រើប្រាស់កន្លែងធ្វើការនោះ ។[46]

សេវាសាធារណៈរបស់សាលារាជធានីភ្នំពេញ តាមរយៈគេហទំព័រផ្លូវការរបស់សាលារាជធានីភ្នំពេញដែលទាក់ទងនឹងវិស័យសំណង់រួមមាន៖

- លិខិតអនុញ្ញាតសាងសង់ សំណង់លំនៅឋានប្រភេទ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ ទំហំចាប់ពី៥០០ម៉ែត្រការេ ដល់៣,០០០ម៉ែត្រការេ បង់កម្រៃចន្លោះពី ២២០,០០០រៀល ដល់១,៨០០,០០០រៀល ចំណាយរយៈពេល២៥ថ្ងៃ មានសុពលភាព១ឆ្នាំ ។
- សំណង់ចម្រុះដែលមានឧបនិស្ស័យ លំនៅឋាន ការិយាល័យ ពាណិជ្ជកម្ម រោងចក្រ សាលារៀន មន្ទីរពេទ្យ...ដែលមានទំហំចាប់ទី១០០ម៉ែត្រការេ ដល់៥,០០ម៉ែត្រការេ បង់កម្រៃសេវាចន្លោះពី១លានរៀល ដល់៥លានរៀល ចំពោះសំណង់ដែលមានទំហំលើសពី៥០០ម៉ែត្រការេ ដល់៣,០០០ម៉ែត្រការេ ត្រូវបូកបន្ថែមក្នុង១ម៉ែត្រការេ ២,៨០០រៀល ចំណាយរយៈពេល២៥ថ្ងៃ មានសុពលភាព១ឆ្នាំ ។
- រាល់ប្រភេទសំណង់ដែលមានឧបនិស្ស័យខាងឧស្សាហកម្ម សេវាកម្ម និងសំណង់វិនិយោគ ចាប់ពី ១០០ម៉ែត្រការេចុះក្រោមរហូតដល់៥០០ម៉ែត្រការេ ចំណាយបន្ទុកសេវាចន្លោះពី៨០០,០០០រៀល ដល់ ៤,៨០០,០០០រៀល និងចាប់ពី៥០០ម៉ែត្រការេ រហូតដល់៣,០០០ម៉ែត្រការេត្រូវបូកបន្ថែមក្នុង១ម៉ែត្រការេ ២,៤០០រៀល ចំណាយរយៈពេល ២៥ថ្ងៃ មានសុពលភាព១ឆ្នាំ ។
- ចំពោះសំណង់ដែលមានឧបនិស្ស័យខាងអប់រំ វប្បធម៌ និងសុខាភិបាល ដែលមានផ្ទៃក្រឡាចាប់ពី ១០០ម៉ែត្រការេចុះក្រោម រហូតដល់៥០០ ម៉ែត្រការេ ត្រូវបង់សេវាចន្លោះពី៤០០,០០រៀល ដល់ ២,៤០០,០០០រៀល ហើយចាប់ពី៥០០ម៉ែត្រការេ រហូតដល់៣,០០០ម៉ែត្រការេ ត្រូវបូកបន្ថែមក្នុង១ម៉ែត្រការេ ២,០០០រៀល មានរយៈពេល២៥ថ្ងៃ និងមានសុពលភាព១ឆ្នាំ ។
- ប្រភេទសំណង់ដែលមានឧបនិស្ស័យខាងកសិកម្ម ដែលមានដែលមានផ្ទៃក្រឡាចាប់ពី១០០ម៉ែត្រការេចុះក្រោម រហូតដល់៥០០ ម៉ែត្រការេ ត្រូវបង់សេវាចន្លោះពី១៤០,០០០រៀល ដល់២២០,០០០រៀល ហើយចាប់ពី៥០០ម៉ែត្រការេ រហូតដល់៣,០០០ម៉ែត្រការេ ត្រូវបូកបន្ថែមក្នុង១ម៉ែត្រការេ២,០០០រៀល មានរយៈពេល២៥ថ្ងៃ និងមានសុពលភាព១ឆ្នាំ ។
- រីឯប្រភេទសំណង់ដែលមានឧបនិស្ស័យខាងជំនឿ សាសនា ទីសក្ការៈបូជា វត្តអារាម និងអគារដែលបម្រើសេវាសាធារណៈរបស់រដ្ឋ សំណង់រដ្ឋ សំណង់សម្បទានសង្គមកិច្ច សប្បុរសជន អង្គការមនុស្សធម៌ អំណោយជូនសហគមន៍ ឬជនក្រីក្រ សមាគមន៍អង្គការ វេសនដ្ឋានសង្គម... មិនគិតថ្លៃទាំងសុំលិខិតអនុញ្ញាត លិខិតបើក និងបិទការដ្ឋាន ទាំងវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ ។

[46] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា ២១

ការគ្រប់គ្រងវិស័យសំណង់ និងការសាងសង់ និងការវិនិយោគលើវិស័យសំណង់នៅរាជធានីភ្នំពេញត្រូវគោរពតាមប្លង់គោលនៃការប្រើប្រាស់ដីនៅរាជធានីភ្នំពេញ ។

## ផ្នែកទី២៖ បច្ចុប្បន្នភាពនៃការគ្រប់គ្រងវិស័យសំណង់

### កថាខណ្ឌទី១៖ ការគ្រប់គ្រងលក្ខណៈបច្ចេកទេសសំណង់

#### វាក្យខណ្ឌទី១៖ ការគ្រប់គ្រងអ្នកវិជ្ជាជីវៈ និងអ្នកផ្គត់ផ្គង់សម្ភារៈសំណង់

រាល់ការប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវមានអាជ្ញាប័ណ្ណដែលផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតរបស់រដ្ឋបាលរាជធានី ខេត្ត តាមប្រភេទអាជីវកម្ម ។ រីឯអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ដែលបំពេញមុខងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មិនតម្រូវឱ្យមានអាជ្ញាប័ណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើយ និងត្រូវបំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

បុគ្គលដែលមានអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានវិញ្ញាបនបត្រធានារ៉ាប់រងដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈ និងអាជីវកម្មខ្លួន ។ ហើយកិច្ចសន្យាធានារ៉ាប់រងសំដៅលើកបំពេញកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យារវាងអ្នកប្រកបវិជ្ជាជីវៈ និងអតិថិជន ។ ចំនួនទឹកប្រាក់អប្បបរមាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបានកំណត់ដោយអនុក្រឹត្យ។[47]

រាល់បណ្តាសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវមានការបញ្ជាក់ទទួលស្គាល់ពីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ឬតាមស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិ និងត្រូវមានអាជ្ញាប័ណ្ណស្តង់ដាកម្ពុជា ។ បែបបទគុណភាពនិងសុវត្ថិភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ជាងនេះទៅទៀតគ្រប់ការផលិត ចែកចាយ នាំចូល និងការប្រើប្រាស់សម្ភារៈ បរិក្ខារ និងផលិតផលសំណង់ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់ ហើយបែបបទនិងនីតិវិធីនៃការត្រួតពិនិត្យអនុលោមភាពត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[48]

ក្នុងករណីក្រុមហ៊ុនប្រកបអាជីកម្មក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មនោះ អាជ្ញាប័ណ្ណត្រូវបានផ្អាកជាបណ្តោះអាសន្នក្នុងរយៈពេលមិនលើសពី ១ឆ្នាំគិតចាប់ពីថ្ងៃផ្អាកអាជ្ញាប័ណ្ណ ដោយសារកត្តាមួយចំនួនរួមមាន៖

- លែងបំពេញលក្ខខណ្ឌណាមួយដែលត្រូវអនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ
- ត្រូវលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយ ឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធន ឬជម្រះបញ្ជីតាមផ្លូវតុលាការ

---

[47] ព្រះរាជក្រមលេខ នស/រកម/១១១៩/០៣៩ ស្តីពីច្បាប់សំណង់, មាត្រា១៩

[48] ព្រះរាជក្រមលេខ នស/រកម/១១១៩/០៣៩ ស្តីពីច្បាប់សំណង់, មាត្រា២២

- មានអភិបាល ឬនាយកបច្ចេកទេសដែលទទួលបានការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ឬការប្រកាសហិតូបត្ថម្ភដោយតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាស
- មានអភិបាល ឬនាយកបច្ចេកទេសដែលបានប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ លើកលែងតែអភិបាល ឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាល ឬនាយកបច្ចេកទេសដែលត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រទេសដទៃដែលធ្លាប់ស្នាក់នៅលើកលែងតែអភិបាល ឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃមានសាលក្រមឬដីការស្ថាពរ ។

ឯនីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចត្រូវបានផ្ដល់ឡើងវិញក្រោយរយៈពេល ៥ឆ្នាំ គិតចាប់ពីថ្ងៃដកហូត ។ ចំណែកឯបុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសដទៃដែលបានស្នាក់នៅអាចទទួលបាននីតិសម្បទាធ្វើជាអភិបាល ឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីកម្មក្នុងវិស័យសំណង់ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។[49]

អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់មិនត្រូវបានផ្អាកលើសពី៦ខែ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ និងនីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់អាចត្រូវបានផ្ដល់ឱ្យវិញក្រោយរយៈពេល៥ឆ្នាំ គិតចាប់ពីថ្ងៃដកអាជ្ញាបណ្ណ ។ ក្នុងករណីដែលអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដោយសារកត្តាណាមួយដូចខាងក្រោម៖[50]

- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- បានប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំឱ្យមានការផ្អាក ឬដកហូតអាជ្ញាបណ្ណ
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់វិជ្ជាជីវៈ ដែលមានលិខិតបញ្ជាក់ពីគ្រូពេទ្យជំនាញ ឬបានទទួលការប្រកាសការចាប់ផ្ដើមពីអាណាព្យាបាល ឬការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភដោយតុលាការ
- ទទួលបានការប្រកាសក្ស័យធនដោយតុលាការ ឬ ត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រទេសណាមួយដែលធ្លាប់ស្នាក់នៅ។

ករណីបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដោយមូលហេតុត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនីតិសម្បទាអាចត្រូវបានទទួលឡើងវិញ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការព្យួរ និងការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈនិងអាជ្ញាបណ្ណផ្សេងៗ

---

[49] ព្រះរាជក្រមលេខ នស/រកម/១១១៩/០៣៩ ស្ដីពីច្បាប់សំណង់, មាត្រា១៨

[50] ព្រះរាជក្រមលេខ នស/រកម/១១១៩/០៣៩ ស្ដីពីច្បាប់សំណង់, មាត្រា១៦

ក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ ។ ការស្នើសុំអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងៗទៀតក្នុងវិស័យសំណង់ត្រូវបង់កម្រៃសេវា ។ កម្រៃសេវាអាជ្ញាបណ្ណ និងការអនុញ្ញាតផ្សេងៗក្នុងវិស័យសំណង់ត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយកម្រៃសេវាអាជ្ញាបណ្ណ និងការអនុញ្ញាតផ្សេងៗត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិ និងថវិកាថ្នាក់ក្រោមជាតិ ។[51]

### វាក្យខណ្ឌទី២៖ ការគ្រប់គ្រងការប្រើប្រាស់សំណង់

#### ក. សំណង់បេតិកភណ្ឌ

ដោយសារបរិបទសង្គមមានការវិវត្ត គួបផ្សំជាមួយកត្តាប្រវត្តិសាស្ត្រផង យើងសង្កេតមានសំណង់ចាស់បុរាណជាច្រើនដែលបានបន្សល់ទុកមកដល់សព្វថ្ងៃ ។ ជាក់ស្តែងមានអគារជាច្រើនដែលមានតាំងពីសម័យបុរាណមក អាណានិគមនិយមបារាំងនៅក្នុងទីក្រុងភ្នំពេញ ក៏ដូចជាបណ្តាខេត្តនានផ្សេងទៀត ដែលគេរក្សា និងស្តារឡើងវិញ ប៉ុន្តែអគារជាច្រើនត្រូវបានបំផ្លាញ ឬមានភាពទ្រុឌទ្រោម ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់ការការពារយ៉ាងពេញទំហឹងលើសម្បត្តវប្បធម៌ និងបេតិក-ភណ្ឌជាតិគ្រប់ប្រភេទ ។ ការការពារ ថែរក្សា និងពង្រីកវប្បធម៌ជាតិ ការការពារប្រាសាទ បុរាណវត្ថុ សិល្បៈបុរាណ សំណង់បុរាណ និងការកែលម្អរមណីយដ្ឋានប្រវត្តិសាស្ត្រឡើង ជាកាតព្វកិច្ចរបស់រដ្ឋ ហើយរាល់បទល្មើសទាំងឡាយណាដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌសិល្បៈ ត្រូវផ្តន្ទាទោសជាទម្ងន់ ។[52]

យោងតាមច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ (១៩៩៦) ការថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ និងវប្បធម៌ទូទៅ ប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការកែប្រែ ការប្តូររូបរាង ការជីកកុំកក ការផ្ទេរកម្មសិទ្ធិ ការនាំចេញនាំចូលដោយខុសច្បាប់ ។ រាល់ការដំណើរការការងារផ្សេងៗ ឬសកម្មភាពផ្សេងទៀត ដែលបានជួបប្រទះសម្បត្តិវប្បធម៌ ដូចជាប្រាសាទ វត្ថុបុរាណ សំណង់ផ្ទះសម្បែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹក ឬសម្បត្តិវប្បធម៌ដែលទាក់ទងសល់បុធប្រវត្តិសាស្ត្រ បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬក៏សាខាដទៃទៀតនៃវិទ្យាសាស្ត្រ ដែលសិក្សាពីអតីតកាល ឬមនុស្សសាស្ត្រ អ្នកដែលបានប្រទះឃើញសម្បត្តិទាំងនេះ និងម្ចាស់អចលនវត្ថុត្រូវតែបញ្ឈប់ការងារ ឬសកម្មភាពនោះ រួចរាយការណ៍ជាបន្ទាន់ ។

#### ខ. ការកែប្រែសំណង់ចាស់

រាល់សំណង់អគារចាស់ដែលអាចបង្កគ្រោះថ្នាក់ដោយប្រការណាមួយ ដែលបានទទួលវាយតម្លៃច្បាស់លាស់ពីស្ថាប័នជំនាញ ឬអាជ្ញាធរមានសមត្ថកិច្ចតាមសំណើរបស់ស្ថាប័នជំនាញ ត្រូវផ្តល់ដំណឹងជូនដល់ម្ចាស់សំណង់ ឬកម្មសិទ្ធិករដែលស្នាក់នៅក្នុងអគារនោះ ដោយបង្ខំឱ្យធ្វើការរុះរើ ឬជួសជុលជាបន្ទាន់ ដើម្បីធានាសុវត្ថិភាព និងជៀសវាងគ្រោះថ្នាក់ជាយថាហេតុ ។ ហើយការជួសជុលទាំងអស់ត្រូវអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ ។ ប្រសិនបើករណីដែលដែលម្ចាស់សំណង់មិនព្រមធ្វើការជួសជុលតាមសេចក្តីជូនដំណឹងរបស់អាជ្ញាធរមានសមត្ថកិច្ច ឬស្ថាប័នជំនាញ ចំនួនពីរដង នោះម្ចាស់សំណង់ត្រូវទទួលខុសត្រូវចំពោះការខូចខាត ឬគ្រោះថ្នាក់ទាំងឡាយដែលកើតមានឡើងដែលបណ្តាលមកពីការមិនព្រមជួសជុលសំណង់របស់ខ្លួន ជាពិសេស

[51] ព្រះរាជក្រមលេខ នស/រកម/១១១៩/០៣៩ ស្តីពីច្បាប់សំណង់, មាត្រា២១

[52] មាត្រា ៦៩, មាត្រា ៧០ នៃ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៤

ម្ចាស់សំណង់ក៏ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមានផងដែរ ។[53]

**គ. សំណង់ដែលចាស់ទ្រុឌទ្រោម**

ដើម្បីធានាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុខដុមរមនីយកម្មសង្គម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចក្នុងការត្រួតពិនិត្យ តាមដាននូវរាល់បណ្តាសំណង់ អគារទាំងឡាយណាដែលមានសភាពទ្រុឌទ្រោម និងងាយបង្កឱ្យមានភាពគ្រោះថ្នាក់ ។ ជាងនេះទៅទៀត ម្ចាស់សំណង់ ឬអ្នកគ្រប់គ្រងមានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច និងអនុវត្តតាមវិធានការនានា ដើម្បីបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលអាចនឹងកើតមានឡើងជាយថាហេតុ ដោយការកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ ក្នុងករណីចាំបាច់អាជ្ញាធរមានសមត្ថកិច្ចត្រូវហ៊ុំព័ទ្ធហាមចូល និងប្រើប្រាស់ ព្រមទាំងតម្រូវឱ្យរុះរើ ហើយរាល់បន្ទុកចំណាយជារបស់ម្ចាស់សំណង់ ។[54]

**កថាខណ្ឌទី២៖ ការគ្រប់គ្រងទៅតាមប្រភេទផ្សេងៗនៃសំណង់**

ដោយសារតែកំណើនប្រជាជននៅរាជធានី ទើបបណ្តាលឱ្យមានការពង្រីកទៅក្រុងបន្ថែមដើម្បីសម្រួលដល់ការរស់នៅ និងផ្គត់ផ្គង់លំនៅឋានដើម្បីបំពេញតម្រូវការជូនប្រជាជន ។ ហេតុនេះទើបសំណង់ចេះតែកើតមានយើងសង្កេតឃើញថាសំណង់គ្រប់ប្រភេទកំពុងស្ទុះយ៉ាងរហ័សពិសេសប្រភេទជាលំនៅស្ថាន ការបង្កើតទីក្រុងថ្មីនិងពង្រីកទីក្រុងជាដើម ។ ក្នុងនោះផងដែរអាជ្ញាធរដែលមានសមត្ថកិច្ច បានបង្កើតច្បាប់ដែលពាក់ព័ន្ធ ក៏ដូចជាគ្រប់គ្រងផ្សេងៗទៅតាមប្រភេទសំណង់ដើម្បីការពារសិទ្ធ សុវត្ថិភាព សណ្តាប់ធ្នាប់ គុណភាព និងចៀសវាងវិវាទផ្សេងៗដែលអាចបង្កផលប៉ះពាល់ដល់សង្គម ។

**វាក្យខណ្ឌទី១៖ ការគ្រប់គ្រងប្រភេទលំនៅឋាន ផ្ទះល្វែង ភូមិគ្រឹះ**

លំនៅឋានមានសារសំខាន់ណាស់សម្រាប់ប្រជាជនគ្រប់រូប គឺជាជម្រកដ៏កក់ក្តៅ ។ ដើម្បីធ្វើការសាងសង់នៅលំនៅឋានមួយដែលត្រឹមត្រូវតាមច្បាប់សាងសង់បាន ម្ចាស់សំណង់ ឬអ្នកតំណាងចាំបាច់ត្រូវតែធ្វើការស្នើសុំលិខិតអនុញ្ញាតសាងសង់ជាមុនសិន ហើយលិខិតអនុញ្ញាតសាងសង់នេះទៀតសោត ក៏ត្រូវធ្វើឡើងទៅតាមទំហំនៃប្រភេទសំណង់ផងដែរ ។ ប៉ុន្តែការស្នើសុំលិខិតអនុញ្ញាតសាងសង់នេះដែរ ដើម្បីជាប្រយោជន៍ដល់សាធារណជន និងសម្រួលដល់ជីវភាពរបស់ប្រជាពលរដ្ឋឱ្យមានលទ្ធភាពពេញលេញ ក្នុងការសាងសង់នូវសំណង់របស់ខ្លួន អាជ្ញាធរមានសមត្ថកិច្ចបានធ្វើការលើកលែងចំពោះប្រភេទសំណង់លំនៅដ្ឋានដែលស្ថិតនៅទីជនបទ ឬតំបន់ដាច់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និងឆ្ងាយពីតំបន់ទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬសម្ភារៈសំណង់ប្រើប្រាស់ឡើយ ។ ចំណែកឯការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ លើកលែងតែការជួសជុលនោះធ្វើឱ្យប៉ះពាល់ដល់អ្នកជិតខាង ។[55]

ដើម្បីទទួលបានភាពស្របច្បាប់ និងការអនុញ្ញាតឱ្យការសាងសង់លំនៅឋានបាន ម្ចាស់គម្រោង ឬអ្នកតំណាងស្របច្បាប់របស់ម្ចាស់គម្រោងត្រូវដាក់ពាក្យស្នើសុំសិទ្ធិសាងសង់ ឬលិខិតអនុញ្ញាតសាងសង់ដែលការ

---

[53] ប្រកាសលេខ ០៧៤ ប្រក/អសណ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ, ប្រការ ២០

[54] ព្រះរាជក្រមលេខ នស/រកម/១១១៩/០៣៩ ស្តីពីច្បាប់សំណង់, មាត្រា៥២

[55] អនុក្រឹត្យលេខ ៨៦ អនក្រ/បក ស្តីពីលិខិតអនុញ្ញាតសាងសង់ , មាត្រា៣

ស្នើសុំលិខិតអនុញ្ញាតនេះដែលគឺត្រូវធ្វើទៅតាមទំហំនៃសំណង់ ពីអាជ្ញាធរមូលដ្ឋាន ឬក្រសួងពាក់ព័ន្ធ ប៉ុន្តែការពាក្យស្នើសុំនេះក៏ត្រូវបានលើកលែងចំពោះសំណង់ដូចដែលមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យលេខ៨៦ ស្តីពីលិខិតអនុញ្ញាតសាងសង់ ។ លិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ជា ៣ថ្នាក់ គឺទៅតាមប្រភេទទំហំនៃការសាងសង់គម្រោងនីមួយៗ គឺ៖

- ថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចក្នុងការផ្តល់ជូននូវលិខិតអនុញ្ញាតសាងសង់ចំពោះតែសំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតូចជាង ឬស្មើ ៥០០ម៉ែត្រការេ ។
- រីឯថ្នាក់រាជធានី ខេត្តវិញ ធ្វើការផ្តល់ជូនលិខិតអនុញ្ញាតសាងសង់ចំពោះតែសំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់ធំជាង ៥០០ម៉ែត្រការេ ដល់ ៣,០០០ម៉ែត្រការេ ។
- ដោយឡែកចំពោះសំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់ធំជាង ៣,០០០ម៉ែត្រការេ[56] នោះការស្នើសុំលិខិតអនុញ្ញាតសាងសង់គឺត្រូវធ្វើឡើងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តែម្តង ។

ដោយឡែកចំពោះកម្រៃនៃការស្នើសុំគឺគិតទៅតាមទំហំផ្ទៃក្រឡា និងប្រភេទគម្រោងនៃការសាងសង់នោះពោលគឺ សម្រាប់គម្រោងលំនៅដ្ឋានដែលមានផ្ទះក្រឡាសាងសង់ទំហំ ៥០០ម៉ែត្រការេ តម្លៃសោហ៊ុយសេវា គឺប្រែប្រួលទៅតាមប្រភេទផ្ទះដូចជា ភូមិគ្រឹះត្រូវបង់សេវាចន្លោះពី ៦សែនរៀល ទៅ១,៨លានរៀល ហើយចំពោះសំណង់លំនៅដ្ឋានប្រភេទផ្ទះល្វែងគឺត្រូវបង់កម្រៃសេវាចន្លោះពី ៥សែនរៀល ទៅ១,២លានរៀល រីឯសម្រាប់លំនៅឋានថ្មក្រោមឈើលើតម្លៃចន្លោះពី ១៤ម៉ឺនរៀល ទៅ ២២ម៉ឺនរៀល ។[57]

ចំពោះសំណង់លំនៅឋាន៖ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ ដែលមានផ្ទៃក្រឡាសំណង់លើសពី៣,០០០ម៉ែត្រការេ ដល់លើសពី១០០,០០០ម៉ែត្រការេ ដើម្បីស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវបង់កម្រៃសេវាចន្លោះពី ៩,៨០០,០០០ រៀល រហូតដល់១២,០០០,០០០រៀល ។[58] ហើយចំណាយរយៈពេល៤៥ថ្ងៃ ដើម្បីទទួលបានលិខិតអនុញ្ញាត និងមានសុពលភាពរយៈពេល១ឆ្នាំ ។

### វាក្យខណ្ឌទី២៖ ការគ្រប់គ្រងបុរី និងទីក្រុងរណប

តើអ្វីទៅជាការគ្រប់គ្រងបុរី និងទីក្រុងរណបនៅកម្ពុជា? ជាទូទៅយោងតាមឯកសារស្រាវជ្រាវ យើងសង្កេតឃើញថាដោយសារតែកំណើនប្រជាជន តម្រូវការនៃលំនៅដ្ឋាន ក៏ដូចជាការសម្រួលនៃសកម្មភាពវិនិយោគបរទេសនៅកម្ពុជាចំពោះការអភិវឌ្ឍដី និងសុវត្ថិភាពកិច្ចការជំនួញលើវិស័យដីធ្លីនៅកម្ពុជា រដ្ឋាភិបាលបានបង្កើតច្បាប់ស្តីពីការគ្រប់គ្រងបុរី និងកំណត់អំពីទីតាំងក្នុងការអភិវឌ្ឍទីក្រុងរណបតាមគម្រោងទិសដៅអភិវឌ្ឍដីរបស់រដ្ឋ ក្នុងគោលដៅដើម្បីធ្វើការគ្រប់គ្រងសម្របសម្រួលសកម្មភាពនៃការអភិវឌ្ឍដី ធានានិរន្តរ៍ភាពនៃការអភិវឌ្ឍដីយ៉ាងណាកុំឲ្យមានភាពអនាធិបតេយ្យ និងការពារផលប្រយោជន៍ប្រជាជនខ្លួនឯងចំពោះអាជីវកម្មលើវិស័យដីធ្លីនៅកម្ពុជា។ បន្ថែមពីនេះយើងសង្កេតឃើញថាការគ្រប់គ្រងបុរី និងទីក្រុងរណប គឺមានកំណត់បែងចែកទៅតាមប្រភេទនៃការអភិវឌ្ឍដី រួមមានប្រភេទការអភិវឌ្ឍដីទៅជាសំណង់លំនៅឋាន ផ្ទះល្វែង និងភូមិគ្រឹះ ហេដ្ឋារចនា

---

[56] អនុក្រឹត្យលេខ ៨៦ អនក្រ/បក ស្តីពីលិខិតអនុញ្ញាតសាងសង់ , មាត្រា៥

[57] ប្រកាសអន្តរក្រសួងលេខ ៦៧៤៥ ប្រក ស្តីពីការប្រែកម្រងសេវារដ្ឋបាលនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ

[58] ប្រកាសអន្តរក្រសួងលេខ ៣៥៦ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្ព័ន្ធជាច្រើនដោយផ្តោតសំខាន់ទៅលើគុណភាព សោភ័ណ្ឌភាពស្របតាមលក្ខណៈបច្ចេកទេស ស្របតាម មូលដ្ឋានច្បាប់និងបទប្បញ្ញត្តិ ។

**ក. ការគ្រប់គ្រងបុរី**

បុរី សំដៅដល់ទីតាំងដែលបានរៀបចំ ជាដីឡូត៍ ជាសំណង់លំនៅឋាន សំណង់ផ្សេងៗ លម្ហសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅលើក្បាលដីតែមួយ ស្របតាមគម្រោងប្លង់សរុបរបស់បុរី ដែលបានទទួលការ អនុញ្ញាតជាផ្លូវការ ។[59] ដើម្បីធ្វើការគ្រប់គ្រងទៅលើបុរីឱ្យមានប្រសិទ្ធិភាព ចាំបាច់ត្រូវអនុវត្តតាមគោលការណ៍ ច្បាប់ និងការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងអ្នកអភិវឌ្ឍ និងកម្មសិទ្ធិករ ។

អនុលោមតាមអនុក្រឹត្យលេខ ៣៩ អនក្រ/បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ដែលមានគោលដៅ កំណត់ពីការរៀបចំ និងគ្រប់គ្រងបុរី គោលការណ៍ យន្តការ និងនីតិវិធីនៃការចុះបញ្ជី ព្រមទាំងសិទ្ធិ និងកាតព្វកិច្ច របស់អ្នកអភិវឌ្ឍ និងកម្មសិទ្ធិករបុរី ។

មុននឹងបង្កើតបុរី អ្នកអភិវឌ្ឍបុរីត្រូវធ្វើការស្នើសុំអាជ្ញាប័ណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាប័ណ្ណអភិវឌ្ឍលំនៅឋាន ត្រូវបានផ្តល់ជូនតាមប្រភេទ ឬទំហំចាប់ពី ០៤ល្វែង ឬ ០៣ភូមិគ្រឹះ ឬ ០៤យូនីត នៃលំនៅឋានឡើងទៅ ហើយទម្រង់អាជ្ញាប័ណ្ណដែលត្រូវផ្តល់ជូនត្រូវបានកំណត់ដោយក្រុមការងារ អន្តក្រសួង ។[60] បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណហើយ អ្នកអភិវឌ្ឍបុរី អាចធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មដើម្បីអូស ទាញអតិថិជនមកទិញបុរីរបស់ខ្លួន ហើយដំណាក់កាលនៃការលក់បុរី អ្នកអភិវឌ្ឍបុរី ត្រូវរៀបចំកិច្ចសន្យាទិញ-លក់ជាមួយអ្នកទិញលំនៅឋាន ។ ជាងនេះទៅទៀតទោះបីអ្នកអភិវឌ្ឍមានអាជ្ញាប័ណ្ណសាងសង់ក៏ដោយ ដើម្បី សាងសង់បុរីបាន អ្នកអភិវឌ្ឍត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់ផងដែរ ដើម្បីធានាភាពស្របច្បាប់ដែលការពារ និងទទួលស្គាល់ដោយអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាង់សង់ ។

លក្ខខណ្ឌចាំបាច់មួយទៀត មុននឹងប្រកាសដាក់លក់សំណង់ក្នុងបុរី ម្ចាស់បុរីត្រូវតែធ្វើការរៀបចំបទ បញ្ជាផ្ទៃក្នុងនៃការគ្រប់គ្រងបុរីដោយអនុលោមតាមមាត្រា១២ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបុរី ម្យ៉ាងវិញទៀត ដើម្បីឆ្លើយតបទៅតាមលក្ខខណ្ឌរៀបចំបទបញ្ជាផ្ទៃក្នុងនៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបុរី កម្មសិទ្ធិករក៏គប្បីបង្កើត ក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងបុរីតាមរយៈការព្រមព្រៀងរវាងកម្មសិទ្ធិករដូចមានចែងក្នុងបញ្ជាផ្ទៃក្នុង ស្រាប់ ។[61] ការបង្កើតក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងបុរី បង្កើតឡើងដោយកម្មសិទ្ធិករនៃដីឡូត៍ ឬដី លំនៅឋាន ឬដីនៃសំណង់ផ្សេងទៀតនៃបុរី ដើម្បីទទួលបន្ទុកលើកិច្ចការផ្សេងៗ ដែលពាក់ព័ន្ធ និងបុរីនោះផងដែរ ។ ការបង្កើតក្រុមប្រឹក្សាភិបាលគ្រប់គ្រងបុរី ឬគណៈកម្មការគ្រប់គ្រង ត្រូវធ្វើឡើងក្រោមការរៀបចំមហាសន្និបាត ជ្រើសរើសពីកម្មសិទ្ធិករទាំងអស់ ដើម្បីកំណត់ពីការផ្តល់សិទ្ធិនានា ។[62] នីតិវិធីនៃការចុះបញ្ជី កាតព្វកិច្ច និងសិទ្ធិ របស់អ្នកអភិវឌ្ឍ និងកម្មសិទ្ធិករ ត្រូវបានកំណត់ដោយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងបុរី ។

---

[59] អនុក្រឹត្យលេខ ៣៩ អនក្រ/បក ស្តីពីការគ្រប់គ្រងបុរី , ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១, មាត្រា៤ ចំណុច១

[60] ប្រកាសលេខ ៩៦៥សហវ/ប្រក ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន,ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦,ប្រការ៦

[61] អនុក្រឹត្យលេខ ៣៩ អនក្រ/បក ស្តីពីការគ្រប់គ្រងបុរី , ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១, មាត្រា១២

[62] ឧបសម្ព័ន្ធអនុក្រឹត្យលេខ ៣៩ អនក្រ/បក ស្តីពីការគ្រប់គ្រងបុរី , ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១, ចំណុខ ៦.៤

**ខ. ទីក្រុងរណប**

ទីក្រុងរណប ប្រសិនបើយើងហៅតាមភាសាអង់គ្លេសគឺ Satellite City ឬ Satellite Town គឺជាតំបន់អភិវឌ្ឍស្នូលរបស់ទីក្រុងមួយ ។ ទីក្រុងរណប គឺជាគោលដៅអភិវឌ្ឍទីក្រុងថ្មីមួយដែលស្ថិតនៅក្នុង ឬនៅក្បែរទីក្រុងគោលដៅ មានហេដ្ឋារចនាសម្ព័ន្ធស្អាត ឬកំពុងអភិវឌ្ឍន៍យ៉ាងរលូន ដើម្បីភ្ជាប់មកកាន់ទីក្រុងគោល ហើយជាតំបន់ដែលមានការរីកចម្រើនផ្នែកឧស្សាហកម្ម ឬពាណិជ្ជកម្មច្រើន និងអាចរស់នៅផ្តាច់ពីទីក្រុងគោលបាន ។

ការធ្វើនគរូបនីយកម្មត្រូវគោរពតាមគោលការណ៍ដូចជាៈ[63]

- មានការចូលរួមពីអ្នកពាក់ព័ន្ធ
- ស្របតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ
- គោរពតាមឋានានុក្រម និងលក្ខណៈទ្វេទិសនៃរាល់ការសម្រេចចិត្ត
- មានកិច្ចសហការជាមួយគ្រប់សមត្ថកិច្ចជំនាញ និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- យកផែនការរូបវន្តទីក្រុងជាមូលដ្ឋានបង្អែក សម្រាប់ការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់គ្រប់ប្រភេទ ព្រមទាំងការធ្វើសមាហរណកម្ម ដើម្បីធ្វើឱ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព មានចីរភាព មានតុល្យភាព និងមានសមធម៌ ។

គម្រោងអភិវឌ្ឍទីក្រុងត្រូវគោរពឱ្យបាននូវលក្ខខណ្ឌអប្បបរមានៃបទបញ្ញត្តិប្រើប្រាស់ដី ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលំហសាធារណៈ ដូចមានចែងក្នុងជំពូកទី៥ និងជំពូកទី៦ នៃអនុក្រឹត្យ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ។ រាល់ការងារពាក់ព័ន្ធនឹងផ្នែកបច្ចេកទេសនគរូបនីយកម្ម និងសំណង់ គម្រោងអភិវឌ្ឍទីក្រុង ត្រូវទទួលបានការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ គម្រោងអភិវឌ្ឍក្នុងទីក្រុង ចាំបាច់ត្រូវមានគោលការណ៍ពីរាជរដ្ឋាភិបាលជាមុនសិន ចំពោះគម្រោងអភិវឌ្ឍនោះពាក់ព័ន្ធនឹងដីរដ្ឋ ។

រាល់ការអភិវឌ្ឍក្នុងក្រុងដែលពាក់ព័ន្ធនឹងដីឯកជន ត្រូវទទួលបានការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។[64]

ក្នុងការអនុវត្តគម្រោងអភិវឌ្ឍក្នុងទីក្រុង ម្ចាស់គម្រោងត្រូវទទួលបន្ទុកលើការចំណាយទាំងអស់ក្នុងការអភិវឌ្ឍ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលំហសាធារណៈ ។ ដោយឡែកចំពោះគម្រោងដែលស្ថិតនៅក្នុងប្រភេទដីដែលអាចសាងសង់បាន អាជ្ញាធរសាធារណៈ ត្រូវទទួលខុសត្រូវលើបន្ទុកចំណាយសម្រាប់ការអភិវឌ្ឍ និងការសាងសង់ចាប់ពីមហាវិថី និងសួនច្បារទីក្រុងឡើងទៅ ។ ចំណែករាល់ការចំណាយផ្លូវថ្នល់ និងសួនច្បារផ្សេងៗទៀតដែលស្ថិតក្នុងគម្រោងអភិវឌ្ឍក្នុងក្រុងជាបន្ទុករបស់ម្ចាស់គម្រោង ។ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលំហសាធារណៈទាំងអស់នៃគម្រោងអភិវឌ្ឍក្នុងទីក្រុង ត្រូវចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ លើកលែងតែផ្លូវច្រកចេញចូល លំហសាធារណៈ សួនច្បារ លំហនៃសេវារួម របងបុរី និងតំបន់ផ្សេងៗដែលមានលក្ខណៈជាបុរី ទោះជាមានឈ្មោះអ្វីក៏ដោយ ត្រូវចុះបញ្ជីជាទ្រព្យអវិភាគរបស់កម្មសិទ្ធិករ

[63] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា ៥

[64] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា ៥៣

ដោយយោងតាមស្មារតីនៃអនុក្រឹត្យលេខ៣៩ ស្តីពីការគ្រប់គ្រងបុរី ។[65]

ដើម្បីជាគ្រឹះនៃភាពស្របច្បាប់ការអភិវឌ្ឍអចលនវត្ថុគ្រប់ប្រភេទ ត្រូវមានការស្នើសុំលិខិតអនុញ្ញាតជាមុនពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង/ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច ។ ការអភិវឌ្ឍអចលនវត្ថុដែលត្រូវមានលិខិតអនុញ្ញាតរួមមាន៖[66]

១. ការសាងសង់សំណង់ថ្មី ការសាងសង់ឡើងវិញ ការពង្រីកអគារ និងការសាងសង់បន្ថែមពីលើអគារដែលមានស្រាប់...

២. ការសាងសង់ ឬការប្តូរទម្រង់ទ្រាយអគារដែលអាចបង្កឱ្យមានគ្រោះថ្នាក់អគ្គិភ័យ ដូចជាការដាក់ស៊ីទែនកន្លែងស្តុកផលិតផលតេលសិលា រោងជាងផលិតគ្រឿងផេះ ។ល។

៣. ការដាក់ស្លាកសញ្ញាផ្សាយពាណិជ្ជកម្ម អង់តែនទូរទស្សន៍ និងទូរគមនាគមន៍ក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ឬការដាក់រចនាសម្ព័ន្ធនៅលើដី និងអគារ

៤. ការអភិវឌ្ឍដី (ការកែប្រែរចនាសម្ព័ន្ធដើមនៃដី ការចាក់បំពេញ ការជីកយកដីចេញ ការបង្រួមក្បាលដី ការបំបែកក្បាលដី ការប្តូរប្រភេទនៃការប្រើប្រាស់ដី និងការប្តូរមុខងារតំបន់ប្រើប្រាស់ដី។ល។

៥. គម្រោងអភិវឌ្ឍទីក្រុង ដូចមានចែងក្នុងជំពូកទី៧ នៃអនុក្រឹត្យស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

៦. ការផ្លាស់ប្តូរលក្ខណៈគតិយុត្តផ្សេងៗ មានជាអាទិ៍ ការពន្យាសុពលភាពនៃលិខិតអនុញ្ញាតសាងសង់ដែលហួសសុពលភាព ការផ្ទេរឈ្មោះក្នុងលិខិតអនុញ្ញាត។ល។

ប៉ុន្តែដើម្បីបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋ ការសាងសង់ថ្មី ឬការជួសជុលលំនៅឋានតូចតាច និងពុំមានលក្ខណៈជាការធ្វើពាណិជ្ជកម្មមិនតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតសាងសង់ បើកនិងបិទការដ្ឋានឡើយ ហើយត្រូវបានកំណត់ក្នុងអនុក្រឹត្យមួយដោយឡែក ។

លិខិតស្នើសុំការអភិវឌ្ឍអចលនវត្ថុ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេលកំណត់មួយមុនការផ្តល់ជូនលិខិតអនុញ្ញាត ដើម្បីទទួលបណ្តឹងតវ៉ា និងធានាការទប់ស្កាត់ទំនាស់នៃការប្រើប្រាសដី ។ លិខិតអនុញ្ញាតការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ត្រូវគោរពតាមផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ។ ក្នុងករណីពុំទាន់បានអនុម័តផ្លូវការ ការផ្តល់លិខិតអនុញ្ញាតការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ត្រូវគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងអនុក្រឹត្យ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសនគរូបនីយកម្ម និងសំណង់ពាក់ព័ន្ធ ដែលបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ។[67]

ចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មលើសេវាបច្ចេកទេស ពិគ្រោះយោបល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យគុណភាពសំណង់ និងការសាងសង់សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ នៅក្នុងព្រះ

---

[65] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា ៥៤

[66] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា ៥៧

[67] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា ៦០

រាជាណាចក្រកម្ពុជា ត្រូវតែចុះបញ្ជី និងការទទួលបានការអនុញ្ញាតពីក្រសួង ។ ហើយលក្ខខណ្ឌនៃការវាយតម្លៃ នីតិវិធី និងការចុះបញ្ជី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។[68]

**វាក្យខណ្ឌទី៣៖ ការគ្រប់គ្រងអគារសហកម្មសិទ្ធិ**

អគារសហកម្មសិទ្ធិ សំដៅដល់អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ ។ អគារសហកម្មសិទ្ធិមានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់មុខ របស់សហកម្មសិទ្ធិករនីមួយៗហៅថា "ចំណែកឯកជន" និងមានចំណែកខ្លះទៀតជាលំហររួមសម្រាប់ការប្រើប្រាស់រួម របស់សហកម្មសិទ្ធិករទាំងអស់ហៅថា "ចំណែករួម" ។ ប្រភេទនៃអគារសហកម្មសិទ្ធិទាំងនោះមានជាអាទិ៍ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែងដែលមានច្រើនល្វែង និងច្រើនជាន់ជាប់គ្នា ខុនដូ ប្រភេទផ្ទះផ្សេងទៀត ដែលមានរចនាសម្ព័ន្ធជាប់គ្នា ។[69]

ជាក់ស្តែងបច្ចុប្បន្ន ស្របគ្នាជាមួយនឹងទីផ្សារអចលនទ្រព្យកាន់តែរីកចម្រើន យើងសង្កេតឃើញវត្តមាននៃសំណង់អគារជាច្រើន កំពុងតែលូតលាស់ដុះដាលជាលំដាប់ ក្នុងនោះដែរ សំណង់អគារលំនៅដ្ឋានក៏កាន់តែប្រណីត ៗ ជាពិសេសសំណង់អគារប្រភេទជាអគារស្នាក់នៅរួម ដែលហៅជាភាសាអង់គ្លេសថាខុនដូរ ។ អគារស្នាក់នៅរួម ខុនដូ ឬហៅតាមផ្លូវច្បាប់ថាអគារសហកម្មសិទ្ធិនេះ ជាគំរូនៃការរស់នៅមួយបែបស៊ីវិល័យ និងមានភាពទាន់សម័យ ដែលប្រជាជនភាគច្រើនមិនទាន់យល់ និងស្គាល់ច្បាស់ ។

ការសាងសង់នៃអគារសហកម្មសិទ្ធិត្រូវជាធ្វើឡើងលើក្បាលដីតែមួយ ដែលបានចុះបញ្ជីរួចរាល់នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។ ហើយករណីដែលសំណង់អគារសហកម្មសិទ្ធិមានច្រើនប្រភេទស្ថិតនៅក្បាលដីតែមួយ តម្រូវឱ្យអ្នកអភិវឌ្ឍស្នើសុំទៅរដ្ឋបាលសុរិយោដីដើម្បីបំបែកក្បាលដី ទៅតាមប្រភេទ និងចំនួននៃអគារសហកម្មសិទ្ធិនីមួយៗ ក្បាលដីសហកម្មសិទ្ធិ ដែលអគារសហកម្មសិទ្ធិស្ថិតនៅត្រូវតែជាទ្រព្យរួមរបស់សហកម្មសិទ្ធិករទាំងអស់ ។ សំណង់អគារសហកម្មសិទ្ធិ ដែលបាន ឬកំពុងសាងសង់ អ្នកវិនិយោគ ឬបុគ្គលដែលមានសមត្ថកិច្ចត្រូវផ្លាស់ប្តូរប្រភេទក្បាលដីទៅជាក្បាលដីសហកម្មសិទ្ធិ នៅរដ្ឋបាលសុរិយោដី លើកលែងតែអគារសហកម្មសិទ្ធិដែលបានសង់នៅលើដីជួលអចិន្ត្រៃយ៍ ហើយត្រូវប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៃក្បាលដីឱ្យទៅរដ្ឋបាលសុរិយោដីដើម្បីចុះហត្ថលេខា និងរក្សាទុក ហើយត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនជំនួសវិញ ។ ទម្រង់បែបបទ និងការផ្លាស់ប្តូរប្រភេទក្បាលដី អាចត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។[70]

មុនពេលប្រកាសលក់ ឬជួលនូវចំណែកឯកជន នៃអគារសហកម្មសិទ្ធិអ្នកអភិវឌ្ឍអចលនវត្ថុត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងមួយដែលត្រូវស្របតាមគោលការណ៍ និងលក្ខខណ្ឌអប្បបរមានៃបទបញ្ជាផ្ទៃក្នុងគំរូដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ១២៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់អគាសហកម្មសិទ្ធិ ដែលបទបញ្ជាផ្ទៃក្នុងនេះដែរ ត្រូវតែជាការព្រមព្រៀងពីសហកម្មសិទ្ធិករ និងមិនផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ជាធរមាន ។ ហើយកម្មសិទ្ធិករក៏អាចបង្កើតក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិ តាមការ

---

[68] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា ៥៩

[69] អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគាសហកម្មសិទ្ធិ, មាត្រា ៤ ចំណុច១

[70] អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគាសហកម្មសិទ្ធិ, មាត្រា ៧

ព្រមព្រៀងរវាងសហកម្មសិទ្ធិករដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។[71]

- ចំណែករួម សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិដែលត្រូវជាកម្មវត្ថុសម្រាប់ការប្រើប្រាស់ជាប្រយោជន៍រួមនៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ដី ទីធ្លា ជណ្ដើរ ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញ-ចូល ជញ្ជាំងអឌ្ឍសិទ្ធិ ទីកន្លែងនៃសេវាកម្មរួម ។[72] បន្ថែមលើនេះរាល់ចំណែកអគារ ឬដីសម្រាប់ការប្រើប្រាស់រួម ឬសម្រាប់ជាប្រយោជន៍នៃសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិបង្កើតបានជាចំណែករួម មានជាអាទិ៍៖
  - ដី ទីធ្លា ឧទ្យាន សួនច្បារ ផ្លូវ ឬច្រកចេញចូល
  - ជញ្ជាំង សសរសំខាន់ៗដែលទ្រទ្រង់អគារ ឧបករណ៍រួម បញ្ចូលចំណែកនៃបណ្ដាញទឹក ភ្លើង ឧស្ម័ន ប្រព័ន្ធលូទឹកស្អុយ ដែលឆ្លងកាត់ចំណែកឯកជន
  - ទូរួម បំពង់ និងក្បាលបំពង់ផ្សែង និងដំបូល
  - ទីកន្លែងសេវារួមផ្សេងៗដែលបានកំណត់ដោយឡែក ឬមានចែងក្នុងបទបញ្ជាផ្ទៃក្នុង
  - សិទ្ធិបន្ទាប់បន្សំទៀតដែលបានចែងក្នុងមាត្រា១៧៩ នៃច្បាប់ភូមិបាល រួមមាន៖
    - សិទ្ធិជីករុករកវត្ថុធាតុដែលមានក្នុងដី
    - សិទ្ធិស្ថាបនាអគារថ្មីនៅក្នុងទីធ្លា ឧទ្យាន ឬសួនច្បារដែលជាចំណែករួម
    - សិទ្ធិជីករុករកក្នុងទីធ្លា ឧទ្យាន សួនច្បារទាំងនោះ
    - សិទ្ធិនៃអឌ្ឍសិទ្ធិភាពដែលជាប់នឹងចំណែករួមទាំងឡាយ
    - សិទ្ធិលើកបន្ដឱ្យខ្ពស់នូវអគារសម្រាប់ប្រើប្រាស់រួម ឬ ដែលមានកន្លែងច្រើន បង្កើតបានជាចំណែកឯកជនផ្សេងគ្នា ។

សហកម្មសិទ្ធិករនីមួយៗមានត្រឹមតែសិទ្ធិប្រើប្រាស់លើចំណែករួមប៉ុណ្ណោះ ព្រោះចំណែករួមជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិករ ។ ហើយសហកម្មសិទ្ធិករទាំងអស់ត្រូវធានាការថែទាំចំណែករួមនេះ បន្ទុកនៃការថែទាំត្រូវចែកគ្នាទៅតាមសមាមាត្រទៅនឹងតម្លៃនៃឡូត៍នីមួយៗ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ឬមានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង ។[73]

- ចំណែកឯកជន សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិ ដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់ជាឯកជនផ្ដាច់មុខ ចំណែកឯកជននេះ គឺមានតែសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិនោះទេដែលមានសិទ្ធិក្នុងការកាន់កាប់ ឬប្រើប្រាស់ផ្ដាច់មុខនូវចំណែកនេះ ។ មានតែរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ ទើបអាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ ។[74] កម្មសិទ្ធិករទាំងអស់នៃអគារសហកម្មសិទ្ធិត្រូវទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិតាមច្បាប់ដែលបញ្ជាក់ពីប្រភេទ និងទំហំ នៃចំណែកកម្មសិទ្ធិឯកជនរបស់ខ្លួន ពីរដ្ឋបាលសុរិយោដី ។ ដើម្បី

---

[71] អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្ដីពីការគ្រប់គ្រង និងប្រើប្រាស់អគាសហកម្មសិទ្ធិ, មាត្រា ៨

[72] អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្ដីពីការគ្រប់គ្រង និងប្រើប្រាស់អគាសហកម្មសិទ្ធិ, មាត្រា ៤ ចំណុច៣

[73] អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្ដីពីការគ្រប់គ្រង និងប្រើប្រាស់អគាសហកម្មសិទ្ធិ, មាត្រា១៤

[74] អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្ដីពីការគ្រប់គ្រង និងប្រើប្រាស់អគាសហកម្មសិទ្ធិ, មាត្រា៣

ទទួលបានវិញ្ញាបនបត្រសម្គាល់នូវម្ចាស់កម្មសិទ្ធិ កម្មសិទ្ធិករម្នាក់ៗ ត្រូវចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ដែលមានសមត្ថកិច្ចក្នុងការទទួលការចុះបញ្ជីសហកម្មសិទ្ធិ ។ សិទ្ធិ កាតព្វកិច្ច និងនីតិវិធីនៃការចុះបញ្ជីត្រូវបានកំណត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិ ។

ដោយឡែក ជនបរទេសមានសិទ្ធិកម្មសិទ្ធិនៃអគារសហកម្មសិទ្ធិ ចាប់ពីជាន់ទី១ ឡើងទៅ ហើយជាន់ទីផ្ទាល់ដី និងក្រោមដីពុំត្រូវអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិឡើយ ។ ការផ្តល់សិទ្ធិកម្មសិទ្ធិនេះធ្វើឡើងចំពោះតែអគារសហកម្មសិទ្ធិតែប៉ុណ្ណោះ ហើយអគារសហកម្មសិទ្ធិនោះត្រូវស្ថិតនៅក្នុងចំងាយ៣០ (សាមសិប) គីឡូម៉ែត្រ ពីព្រំដែនគោកឡើយ និងតំបន់ដែលកំណត់ដោយរាជរដ្ឋាភិបាល លើកលែងតែអគារសហកម្មសិទ្ធិដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ទីប្រជុំជនសំខាន់ៗ និងតំបន់ផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋភិបាល ។[75] ម្យ៉ាងវិញទៀតជនបរទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ អាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិមួយកន្លែងមិនលើសពី ៧០ (ចិតសិប) ភាគរយនៃទំហំផ្ទៃក្រឡានៃចំណែកឯកជនទាំងអស់នៃអគារសហកម្មសិទ្ធិ ។[76]

### កថាខណ្ឌទី៣៖ ការធ្វើអធិការកិច្ចសំណង់

#### វាក្យខណ្ឌទី១៖ នីតិវិធីនៃការធ្វើអធិការកិច្ច

ដើម្បីធានានូវការគ្រប់គ្រងសំណង់ឱ្យមានប្រសិទ្ធិភាព គុណភាព សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៃការរស់នៅឱ្យមានភាពសុខដុមរមនា និងដើម្បីបង្កា ចៀសវាង និងទប់ស្កាត់នូវបណ្តាបទល្មើស និងការគ្រោះថ្នាក់ដែលបណ្តាលមកពីការរំលោភ បំពាន និងការប្រព្រឹត្តប្រាស់ចាកពីបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តគ្រប់គ្រងវិស័យសំណង់នោះ អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងលើវិស័យនេះ បានបង្កើតឱ្យមានក្រុមអធិការកិច្ចសំណង់ ។ ដែលក្រុមអធិការកិច្ចសំណង់នេះដែរ ធ្វើអធិការកិច្ចទៅក្នុងការដ្ឋានសំណង់ដែលធ្វើដំណើរការ ព្រមទាំងមានការព្រមព្រៀងពីម្ចាស់ទីតាំងសំណង់ ។ មន្ត្រីធ្វើអធិការកិច្ចសំណង់ត្រូវមានលិខិតបញ្ជាបេសកម្ម ព្រមទាំងមានសម្លៀកបំពាក់ឯកសណ្ឋាន និងមានសញ្ញាសម្គាល់[77] ការចូលបំពេញការងារនៅក្នុងអគារ ឬសំណង់ដែលបានបើកចំហរដល់សាធារណជនតែក្នុងពេលម៉ោងការងារតែប៉ុណ្ណោះ ពោលគឺនៅក្រោយម៉ោង ៦ (ប្រាំមួយ) ព្រឹក និងមុនម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច ប៉ុន្តែក្នុងករណីចាំបាច់តម្រូវឱ្យមានការធ្វើអធិការកិច្ចសំណង់នៅក្រៅម៉ោងពេលដូចបានកំណត់ ដែលមានការអនុញ្ញាតពីព្រះរាជអាជ្ញា ។[78]

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីអធិការកិច្ចត្រូវអនុវត្តដូចខាងក្រោម:[79]

- ត្រួតពិនិត្យ និងអង្កេតអំពីអនុលោមភាពនៃការអភិវឌ្ឍដី សាងសង់ រុះរើសំណង់តាមលិខិតអនុញ្ញាត បទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន

[75] ព្រះរាជក្រមលេខ នស/រកម/ ០៥១០/០០៦ ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស,មាត្រា៦

[76] អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពីការកំណត់ចំនួនសមាមាត្រ និងរបៀបគិតគូរចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេសនៅក្នុងអគារសហកម្មសិទ្ធិ

[77] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ៩

[78] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ៨

[79] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ១០

- ត្រួតពិនិត្យការប្រកបអាជីវកម្មរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ និងក្រុមជាង
- ត្រួតពិនិត្យសុវត្ថិភាពការងារក្នុង និងបរិវេណជុំវិញការដ្ឋានសំណង់
- ពិនិត្យរាល់ឯកសារពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍដី សាងសង់ រុះរើ ដូចជាឯកសារបញ្ជាក់កម្មសិទ្ធ ឬកាន់កាប់ លិខិតអនុញ្ញាតបើក\បិទ គម្រោងប្លង់ កិច្ចសន្យាឬឯកសារពាក់ព័ន្ធផ្សេងទៀត
- ស្នើសុំឱ្យម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុផ្តល់ព័ត៌មានពាក់ព័ន្ធ និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ ជាងជំនាញ និងក្រុមជាងសំណង់ដែលពាក់ព័ន្ធ
- ណែនាំឱ្យម្ចាស់សំណង់កែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ
- ណែនាំអ្នកគ្រប់គ្រងការដ្ឋានឱ្យចាត់វិធានការបន្ទាន់ដើម្បីជៀសគ្រោះថ្នាក់ដោយយថាហេតុ ឬការប៉ះពាល់ដល់សណ្តាប់ធ្នាប់ក្នុងនិងក្រៅបរិវេណការដ្ឋាន
- ណែនាំរូបវន្តបុគ្គល ឬនីតិបុគ្គលសិក្សាគម្រោប្លង់ ឬក្រុមហ៊ុនសាងសង់ ឬក្រុមជាងសំណង់អំពីបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធ
- ធ្វើកំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់
- ប្រតិបត្តិការងារផ្សេងៗដែលអាជ្ញាធរមានសមត្ថកិច្ចផ្តល់ជូន ។

នៅពេលចុះធ្វើអធិការកិច្ចសំណង់ មន្ត្រីធ្វើអធិការកិច្ចសំណង់ចាំបាច់ត្រូវធ្វើកំណត់ហេតុ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចតាមរយៈប្រធានអង្គភាពមានសមត្ថកិច្ចដើម្បីពិនិត្យ និងសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចុះធ្វើអធិការកិច្ច ។ ហើយកំណត់ហេតុ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ របស់មន្ត្រីអធិការកិច្ចសំណង់ថ្នាក់ក្រោមជាតិនេះ ត្រូវចម្លងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផងដែរ ។[80]

កំណត់ហេតុ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវមានខ្លឹមសារសំខាន់ៗដូចខាងក្រោមៈ[81]

- អត្តសញ្ញាណម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់
- ព័ត៌មានអំពីគម្រោងដីអភិវឌ្ឍដី ឬគម្រោងសាងសង់ ឬរុះរើ
- លទ្ធផលនៃការផ្ទៀងផ្ទាត់ពីអនុលោមភាពចំពោះលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ
- ហត្ថលេខារបស់មន្ត្រីអធិការកិច្ចសំណង់ អ្នកគ្រប់គ្រងការដ្ឋាន និង/ឬម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

របាយការណ៍ស្តីពីការលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវបន្ថែមនូវៈ

- ការសន្និដ្ឋានចំពោះលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់

[80] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ១១

[81] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ១២,ប្រការ១៣

- លើកសំណើជាវិធានការ និង/ឬទណ្ឌកម្មជូនអាជ្ញាធរមានសមត្ថកិច្ចពិនិត្យ និងសម្រេច
- ត្រូវមានហត្ថលេខារបស់មន្ត្រីអធិការកិច្ចសំណង់ ហត្ថលេខា និងត្រា របស់ប្រធានអង្គភាពមានសមត្ថកិច្ច

ក្នុងករណីមន្ត្រីអធិការកិច្ចសំណង់លើកសំណើធ្វើការពិន័យអន្តរការណ៍ របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ត្រូវបន្ថែមនូវខ្លឹមសារដូចខាងក្រោម៖

- ប្រភេទអំពើល្មើសដោយមានបញ្ជាក់អំពីទំហំ រយៈពេល ផលប៉ះពាល់ និងព័ត៌មានចាំបាច់ផ្សេងទៀត
- អត្តសញ្ញាណម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ ដែលប្រព្រឹត្តអំពើល្មើស
- បទប្បញ្ញត្តិដែលកំណត់អំពីការពិន័យអន្តរការណ៍ និងចំនួនទឹកប្រាក់ដែលត្រូវពិន័យអន្តរការណ៍ ។

ក្នុងអំឡុងពេលនៃការធ្វើអធិការកិច្ចសំណង់ ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់ និង/ឬតំណាងមានកាតព្វកិច្ចផ្តល់កិច្ចសហការប្រកបដោយសុឆន្ទៈ ហើយមិនរារាំង ហាមឃាត់ ឬបង្កការលំបាកដល់ការធ្វើអធិការកិច្ចដោយអនុញ្ញាតឱ្យមន្ត្រីចូលត្រួតពិនិត្យគ្រប់ទីកន្លែងទាំងអស់ក្នុងការដ្ឋាន ឆ្លើយបំភ្លឺ ពន្យល់ ព្រមទាំងផ្តល់ព័ត៌មានទូទៅពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍអចលនវត្ថុ គ្រប់ភាគីពាក់ព័ន្ធនឹងការអនុវត្តគម្រោង ឯកសារ ឬសេចក្តីអះអាងពាក់ព័ន្ធនឹងការគោរព និងអនុវត្តច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធប្រកបដោយសីលធម៌ សុចរិតភាព និងទំនួលខុសត្រូវ ។ នាពេលមន្ត្រីអធិការកិច្ចកំពុងបំពេញការងារ ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់ និង/ឬតំណាងចាំបាច់ត្រូវចាត់វិធានការធានានូវសន្តិសុខ សុវត្ថិភាព នៅក្នុងទីតាំងគម្រោង ឬការដ្ឋានសាងសង់ ឬសំណង់របស់ខ្លួន ហើយផ្តល់នូវសំណាក់នៃសម្ភារ បរិក្ខារ ផលិតផលសំណង់ ឧបករណ៍ ឬគ្រឿងចក្រផ្សេងទៀត ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងវិភាគផ្ទៀងផ្ទាត់ ។[82] ប៉ុន្តែម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់ និង/ឬតំណាងមានសិទ្ធិស្នើសុំមន្ត្រីអធិការកិច្ចសំណង់បង្ហាញនូវលិខិតបញ្ជាក់បេសកកម្ម ហើយទទួលច្បាប់ចម្លងនៃកំណត់ហេតុអធិការកិច្ចសំណង់ ដែលមន្ត្រីអធិការកិច្ចកត់ត្រារាល់ការឆ្លើយតប ឬសេចក្តីអះអាងរបស់ខ្លួននៅក្នុងកំណត់ហេតុ ។[83]

មន្ត្រីអធិការកិច្ចសំណង់អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់សំណង់ ។ ក្នុងករណីបទល្មើសជាក់ស្តែង ឬមិនមានលិខិតអនុញ្ញាតសាងសង់ ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់ព័ត៌មានជាបន្ទាន់ ដល់មន្ត្រីអធិការកិច្ចសំណង់មានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់វិធានការតាមនីតិវិធី ហើយរាល់ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចក្នុងការពិនិត្យបទល្មើសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។[84]

[82] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ១៧
[83] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ១៨
[84] ព្រះរាជក្រមលេខ នស/រកម/១១១៩/០៣៩ ស្តីពីច្បាប់សំណង់, មាត្រា៦១

## វាក្យខណ្ឌទី២៖ មន្ត្រីអធិការកិច្ច និងសមត្ថកិច្ច

### ក. មន្ត្រីអធិការកិច្ច

មន្ត្រីអធិការកិច្ចសំណង់ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់ ហើយទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ឱ្យត្រួតពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់សំណង់ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។[85] មន្ត្រីអធិការកិច្ចសំណង់ ត្រូវបានចូលរួមពី៖[86]

១. ថ្នាក់ដឹកនាំជាវិស្វករ ឬស្ថាបត្យកម្មនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

២. មន្ត្រីជំនាញជាវិស្វករ ឬស្ថាបត្យកម្មនៃអគ្គនាយកដ្ឋានសំណង់ និងអគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៣. មន្ត្រីជំនាញជាវិស្វកម្ម ឬស្ថាបត្យករនៃមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងសុរិយោដីរាជធានី ខេត្ត

៤. មន្ត្រីជំនាញជាវិស្វករ ឬស្ថាបត្យករនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ

សមាសភាពមន្ត្រីអធិការកិច្ចសំណង់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកចេញលិខិតបញ្ជាបេសកម្មចុះធ្វើអធិការកិច្ចសំណង់ ជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់ជាតិ ។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្តជាអ្នកចេញលិខិតបញ្ជាបេសកម្មចុះធ្វើអធិការកិច្ចសំណង់ថ្នាក់រាជធានីខេត្តតាមសំណើប្រធានមន្ទីរ និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាអ្នកចេញលិខិតបញ្ជាបេសកម្មចុះធ្វើអធិការកិច្ចជូនសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ តាមសំណើប្រធានការិយាល័យ ។ រាល់ការធ្វើអធិការកិច្ចសំណង់ត្រូវមានមន្ត្រីចូលរួមពីមន្ត្រីអធិការកិច្ច ៥នាក់យ៉ាងតិចសម្រាប់ធ្វើអធិការកិច្ចសំណង់ដែលសម្រេចដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៣នាក់យ៉ាងតិចសម្រាប់ធ្វើអធិការកិច្ចសំណង់ដែលសម្រេចដោយអភិបាលរាជធានី ខេត្ត និង ១នាក់នៃអភិបាលក្រុង ស្រុក ខណ្ឌ ។[87]

អាជ្ញាធរមានសមត្ថកិច្ច ជាអ្នកសម្រេចធ្វើអធិការកិច្ចមានដូចខាងក្រោម៖[88]

១. រដ្ឋមន្ត្រីក្រសួងរៀបចំដែនចំដី នគរូបនីយកម្ម និងសំណង់ ចំពោះអភិវឌ្ឍអចលនវត្ថុគ្រប់ប្រភេទ

២. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ចំពោះការអភិវឌ្ឍចលនវត្ថុដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត។

---

[85] ព្រះរាជក្រមលេខ នស/រកម/១១១៩/០៣៩ ស្តីពីច្បាប់សំណង់, មាត្រា៥៧

[86] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ៤

[87] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ៦, ប្រការ៧

[88] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ៥

៣. អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចំពោះការអភិវឌ្ឍអចលនាស្ថិតនៅក្រោមរដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

មានតែប្រធានអង្គភាពមានសមត្ថកិច្ចប៉ុណ្ណោះ ដែលអាចលើកសំណើធ្វើអធិការកិច្ចសំណង់នៅអាជ្ញាធរមានសមត្ថកិច្ច ។

### ខ. សមត្ថកិច្ច

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តែងតាំងមន្ត្រីអធិការកិច្ចដើម្បីតាមដាន ពិនិត្យប្រមូលភស្តុតាងនិងជម្រុញការអនុវត្តច្បាប់ ។ ដែលមន្ត្រីអធិការកិច្ចនេះផងដែរ មានភារកិច្ច និងសិទ្ធិដូចជា៖[89]

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានច្បាប់
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនោះល្មើសច្បាប់
- ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសសំណង់
- ចាត់វិធានការផ្សេងទៀតក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់ ។

ករណីដែលការសាងសង់មិនបានអនុលោមតាមលិខិតអនុញ្ញាត បទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តដែលបានពីរបាយការណ៍នៃការចុះធ្វើអធិការកិច្ច ត្រូវមានវិធានការ ឬការដាក់ទណ្ឌកម្មមួយ ឬច្រើនដូចជា៖[90]

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ផ្អាកការសាងសង់
- ព្យួរ ឬដកលិខិតអនុញ្ញាតអភិវឌ្ឍដី និង/ឬលិខិតអនុញ្ញាតសាងសង់ ឬរុះរើ លិខិតអនុញ្ញាតបើក ឬបិទការដ្ឋានសាងសង់ ឬវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់
- ហាមឃាត់ការប្រើប្រាស់ និងធ្វើអាជីវកម្មពាក់ព័ន្ធនឹងសំណង់
- ការឃាត់ទុកជាបណ្តោះអាសន្ននូវ សម្ភារ គ្រឿងបរិក្ខារ ផលិតផល ឬគ្រឿងចក្រ ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស
- បង្ខំឱ្យរុះរើ ឬស្តាបនាឡើងវិញឱ្យដូចសភាពដើម នូវអ្វីដែលប្រែប្រួល ឬបាត់បង់ដោយការល្មើស
- ការពិន័យអន្តរការណ៍ចំពោះបុគ្គលដែលប្រព្រឹត្តល្មើស
- ការចាត់វិធានការផ្សេងៗស្របតាមបទប្បញ្ញត្តិជាធរមាន ។

[89] ព្រះរាជក្រមលេខ នស/រកម/១១១៩/០៣៩ ស្តីពីច្បាប់សំណង់, មាត្រា៥៩

[90] ប្រកាសអន្តរក្រសួងលេខ ១១៨ ប្រ.ក/ដ.ន.ស.ក.យ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់,ប្រការ១៤

# ជំពូក ៣
# របបនៃការគ្រប់គ្រង
# ការដោះស្រាយ
# វិវាទលើវិស័យសំណង់

# ជំពូក៣

# របបនៃការគ្រប់គ្រងការដោះស្រាយវិវាទលើវិស័យសំណង់

## ផ្នែកទី១៖ នីតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការលើវិស័យសំណង់

ទីផ្សារអចលនទ្រព្យកាន់តែរីកចម្រើនឥតឈប់ឈរ ចំណែកឯអគារគ្រប់ប្រភេទ លំនៅឋានផ្សេងៗក៏កាន់តែរីកដុះដាលដូចគ្នាដែរហើយកិច្ចសន្យាលក់ទិញនូវអចលនទ្រព្យត្រូវបានបង្កើតឡើងស្ទើររាល់ថ្ងៃ ដើម្បីការពារនូវសិទ្ធិ ព្រមទាំងទប់ស្កាត់ពីការមិនបំពេញកាតព្វកិច្ចតាមកិច្ចសន្យា រួមទាំងការបំពានលើកិច្ចសន្យាមកលើភាគីណាមួយនៅការទិញលក់នូវអចលនទ្រព្យនោះ ។ ជាទូទៅ កិច្ចសន្យាទិញលក់នេះអាចត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែមានករណីបទប្បញ្ញត្តិពិសេសដែលមានចែងក្នុងច្បាប់។

វិស័យឧស្សាហកម្មសំណង់ចេះតែរីកចម្រើន បន្ថែមពីលើការរីកចម្រើននេះ គេត្រូវកត់សម្គាល់ថាឧស្សាហកម្មសំណង់តែងតែត្រូវបានចាត់ទុកថាជាឧស្សាហកម្មមួយដែលងាយមានវិវាទបំផុតដោយសារតែភាពស្មុគស្មាញ និងរយៈពេលដ៏វែងនៃគម្រោងសាងសង់ និងចំនួននៃភាគីពាក់ព័ន្ធ ។ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការសំដៅទៅលើវិធីដែលគូភាគីអាចដោះស្រាយជម្លោះរបស់ខ្លួននៅក្រៅប្រព័ន្ធ ។ យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានគេប្រើប្រាស់ក្នុងប្រវត្តិសាស្ត្រជុំវិញពិភពលោករួមទាំងប្រទេសជប៉ុន និងកម្ពុជាយើងផងដែរ ។ ការដោះស្រាយនោះក៏អាចទាក់នឹងច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្ម។ ការដោះស្រាយនោះសោតក៏អាចអនុវត្តយន្តការក្នុងស្រុក និងអន្តរជាតិ ជាទូទៅក្នុងនោះមានបីរួមមាន ការចរចារ សន្ធានកម្ម និងមជ្ឈត្តកម្ម តែដោយសារមជ្ឈត្តកម្មមានជាប្រភេទរឿងក្តីទាក់ទងនឹងអន្តរជាតិ ដូចនេះយើងសិក្សាតែ ការចរចារ និងសន្ធានប៉ុណ្ណោះ ។ ជាទូទៅជម្លោះដែលបានដោះស្រាយក្រៅប្រព័ន្ធតុលាការ មានភាពរហ័ស និងមានការចំណាយចិត្តជាងការដំណើរការនៅក្នុងប្រព័ន្ធតុលាការ ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការថ្នាក់ជាតិ និងក្រោមជាតិគឺមានភាពងាយស្រួល និងចំណាយតិចជាងដំណើរការនៅក្នុងប្រព័ន្ធតុលាការ ។ លើសពីនេះសន្ធានកម្មមានសិទ្ធិអំណាចអនុវត្តដូចគ្នាទៅនឹងសាលក្រមតុលាការបានដូចគ្នា។

ក្រៅពីដោះស្រាយជម្លោះតាមរយៈតុលាការ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ គឺជាវិធីសាស្ត្រមួយផ្សេងទៀត។ ការដោះស្រាយជម្លោះប្រភេទនេះ គឺជាយន្តការដែលប្រជាជនប្រើប្រាស់ជាជម្រើសដើម្បីដោះស្រាយជម្លោះនៅក្រៅប្រព័ន្ធយុត្តាធិការតុលាការ។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ត្រូវបានចាប់ផ្តើមក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ និងឆ្នាំ ១៩៨០ និងទទួលបាននូវប្រជាប្រិយភាពចាប់ពីពេលនោះមក។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ គឺត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយរឿងគ្រួសារ ជម្លោះជាមួយអ្នកជិតខាង ក៏ដូចជាជម្លោះពាក់ព័ន្ធនឹងបរិស្ថាន សំណង់ ដីធ្លីជាដើម។

បច្ចុប្បន្នដោយសារតែបាតុភូតសាកលភាវូបនីយកម្ម និងកំណើននៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទម្រង់ថ្មីមួយនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្ទាល់តាមប្រព័ន្ធអេឡិត្រូនិច(OADR) ដែលមានគោលបំណងជម្រុញគូភាគី ទំនាក់ទំនងគ្នាតាមរយៈប្រព័ន្ធអេឡិចត្រូនិចដើម្បីទទួលបានដំណោះស្រាយដ៏ល្អមួយ។

ក្នុងដំណើរការនេះក៏បានប្រទះបញ្ហាប្រឈមមួយចំនួនផងដែរដូចជា៖

- មានការលំបាកបន្តិចក្នុងការដែរឱ្យគូភាគីមានអំណាចគោរពនូវបទប្បញ្ញត្តិ

- ភាគីអាចយល់ថាបទបញ្ញត្តិននេះជាការបឹទសិទ្ធសេរីភាព
- ភាគីមិននមានគំនិតបង្កើតវិធានផ្ទៃក្នុងដោយខ្លួនឯងបាន
- អ្នកសម្របសម្រួលមិនសូវយល់ពីច្បាប់ និងដំណើរការដោះស្រាយតាមផ្លូវច្បាប់
- ភាគីមានអំណាចងាយនឹងធ្វើការបោះបង់ក្នុងដំណើរការសម្រុះសម្រួល
- មានការលំបាកក្នុងការរកភាគីទី៣(អ្នកសម្របសម្រួល) ដែលមានសមត្ថភាព និងអព្យាក្រឹត្យពិតប្រាកដ
- ការថែរក្សា និងរៀបចំឯកសារ ត្រូវការធនធានមនុស្ស និងពេលវេលាច្រើន
- ភាគីអាចមានការប្រែក្រឡាស់មិនអនុវត្តតាមកិច្ចព្រមព្រៀង

**កថាខណ្ឌទី១៖ ការចរចារ**

ការចរចារ ជាវិធីសាស្ត្រសាមញ្ញក្នុងការដោះស្រាយជម្លោះ រវាងគូភាគីដោយគ្មានការអន្តរាគមន៍ពីសំណាក់ភាគីទីបីណាឡើយ ភាគីនៃជម្លោះពិភាក្សាគ្នា ដើម្បីទទួលបានដំណោះស្រាយមួយដែលពួកគេចង់បានពីភាគីជម្លោះម្ខាងទៀត ។ ការចរចារ គឺជាយន្តការមូលដ្ឋានមួយដែលត្រូវបានប្រើនៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីនីមួយៗនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។ ការចរចារគឺជាការឆ្លើយឆ្លងគ្នាទៅវិញទៅមកដែលភាគីអាចដាក់សំណើរផ្សេងៗរហូតសំណើរត្រូវបានទទួលយក ។ យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជាក៏បានគាំទ្រ និងលើកទឹកចិត្តឱ្យគូភាគីស្រុះស្រួលគ្នាតាមរយៈការចរចារផងដែរ ។ ការចរចារធ្វើតាមវិធីជាច្រើនយ៉ាងដូចជាការចរចារផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរជាដើម ។ ចំណែកឯវិធីសាស្ត្រនៃការចរចាវិញមានពីរគឺ វិធីសាស្ត្រនៃការចរចារឈ្នះចាញ់ និងវិធីនៃការចរចារឈ្នះ-ឈ្នះ ។ វិធីសាស្ត្រនៃការចរចារឈ្នះចាញ់ មានន័យថាភាគីត្រូវធ្វើការបែកចែកមានឈ្នះមានចាញ់ ព្រោះថាគូភាគីមានធនធានដែលមានចំនួនកំណត់ ដូចនេះភាគីទាំងសងខាងមានគោលបំណងចង់បានកម្មវត្ថុ ឬទឹកប្រាក់ដែលខ្លួនទទួលបាន ។ រីឯវិធីសាស្ត្រចរចារឈ្នះ-ឈ្នះគឺជាវិធីសាស្ត្រមួយដែលភាគីមានការអត់ឱន និងមានការសហការគ្នា ព្រោះថាភាគីអាចបែងចែក ឬបំពេញផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកបាន។

**កថាខណ្ឌទី២៖ សន្ធានកម្ម**

សន្ធានកម្ម ឬការផ្សះផ្សា ជាការសម្រួលវិវាទ ដែលធ្វើឡើងដោយមានបុគ្គលម្នាក់ជាអ្នកសម្របសម្រួលគូភាគី ។ បុគ្គលដែលធ្វើការសម្រុះសម្រួល ឬសម្របសម្រួលនេះហៅថាសន្ធានការី ។ សន្ធានការី ជាបុគ្គលអព្យាក្រឹត្យ មិនលំអៀង ។ ការធ្វើសន្ធានកម្ម មានការចូលរួមពីភាគីទីបីដែលមានអព្យាក្រឹត្យ ដើម្បីសម្របសម្រួលដល់ការដោះស្រាយជម្លោះ និងជួយឱ្យភាគីគឺសម្រេចបានដំណោះស្រាយល្អបំផុត ។ ក្នុងកិច្ចដំណើរការនៃសន្ធានកម្ម សន្ធានការីគ្មានអំណាចដើម្បីសម្រេចទេ តែយ៉ាងណាសន្ធានការីស្តាប់ការពិភាក្សារបស់គូភាគី និងការព្យាយាមសម្របសម្រួលគូភាគី ។ ក្នុងសង្គមកម្ពុជា សន្ធានការីដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទ និងបានទទួលស្គាល់ដោយច្បាប់ ។ ជាទូទៅសន្ធានការី គឺជាមន្ត្រីមកពីជំនាញខុសគ្នាអាស្រ័យលើបញ្ហាវិវាទ ។ នៅក្នុងនីតិវិធីសន្ធានកម្ម ឬការផ្សះផ្សានេះ គឺសន្ធានការីមានតួនាទីស្តាប់នូវភាគីទាំងសងខាង ស្វែងរកដំណោះស្រាយដោយភាពឈ្លាសវៃ ក៏ដូចជាលើកទឹកចិត្តដើម្បីឱ្យភាគីពិចារណាក្នុងការត្រូវរ៉ូវគ្នា យល់ពីអង្គហេតុនៃដំណើររឿង និងអង្គច្បាប់ បង្កើតនូវចំណុចសមស្រប និងមានហេតុផល ដើម្បីសម្រុះសម្រួលវិវាទ។

## ផ្នែកទី២៖ នីតិវិធីដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការ

ជាទូទៅគូភាគីដាក់បញ្ចូលនូវប្បញ្ញត្តិស្តីពីការដោះស្រាយវិវាទនៅក្នុងកិច្ចសន្យាសាងសង់របស់ខ្លួន ស្របតាមអ្វីដែលគូភាគីបានកំណត់ជាយន្តការនៃការដោះស្រាយវិវាទរបស់ខ្លួន ។ ពួកគេមានសិទ្ធិជ្រើសរើសយករវាង (១) ការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការដែលអនុវត្តជាទូទៅ (២) ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែល រួមមាន មជ្ឍត្តកម្មក្នុងស្រុក ឬមជ្ឍត្តកម្មអន្តរជាតិ។

ទោះជាយ៉ាងណាក៏ដោយ ជម្លោះមួយចំនួននឹងមិនអាចបញ្ចប់ត្រឹមកិច្ចព្រមព្រៀងតាមរយៈការសម្រុបសម្រួលគ្នាឡើយ។ ជម្លោះមួយចំនួនត្រូវការអំណាចបង្ខិតបង្ខំរបស់រដ្ឋដើម្បីស្វែងរកនូវដំណោះស្រាយមួយដែលសមស្រប និងយុត្តិធម៌ ។ មនុស្សត្រូវការអ្នកមានជំនាញ មានវិជ្ជាជីវៈ ដើម្បីជួយដោះស្រាយពួកគេ ពេលដែលពួកគេជួបបញ្ហា ប្រសិនបើជម្លោះនោះទាក់ទងនឹងការរំលោភសិទ្ធិស្របច្បាប់ ការធ្វើខុសច្បាប់ឬការគំរាមកំហែងនៃការសកម្មភាពផ្លូវច្បាប់ ប្រឆាំងនឹងពួកគេ ។ អ្នកដែលដោះស្រាយដោយមិនលំអៀងគឺ ចៅក្រម និង / ឬ គណៈកម្មការវិនិច្ឆ័យ ដោយផ្អែកលើសំណួរអង្គហេតុនៃរឿងក្តីជាមួយនិងអង្គច្បាប់ ។ តុលាការ គឺជាអង្គជំនុំជម្រះដែលមានក្នុងការដោះស្រាយជម្លោះទាក់ទងនឹងច្បាប់ ដោយធ្វើការពិនិត្យភាពត្រឹមត្រូវនៃការអនុវត្ត និងបកស្រាយច្បាប់ ។ អំណាចតុលាការ គឺមិនត្រូវបានផ្តល់ទៅឱ្យអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិ ដែលមានន័យថា អំណាចតុលាការជាអំណាចដោយឡែកពីអំណាចទាំងពីរនោះ ។ អង្គការតុលាការនៅក្នុងប្រទេសកម្ពុជាមានបីថ្នាក់ដែលក្នុងនោះមាន៖

- តុលាការខេត្ត/ក្រុង (សាលាដំបូងរាជធានី-ខេត្ត)
- សាលាឧទ្ធរណ៍ (ជាតុលាការលំដាប់ទីពីបន្ទាប់ពីសាលាដំបូង)
- និងតុលាការកំពូល (ជាតុលាការដែលជាថ្នាក់ខ្ពស់បំផុត) ។

តុលាការទាំងបីថ្នាក់នេះ មានយុត្តាធិការក្នុងការសម្រេចនូវសំណុំរឿងក្តីគ្រប់ប្រភេទ រួមទាំងរឿងនីតិរដ្ឋបាលផងដែរ ។ ប៉ុន្តែមានតែសាលាដំបូងដែលមានលក្ខណៈជំនាញទៅតាមរឿងក្តីដែលអាចមានជាតុលាការពាណិជ្ជកម្ម តុលាការការងារ និងតុលាការព្រហ្មទណ្ឌ ។ យោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធប្តឹងបរិហារគេរ៉ា ឬប្តឹងតវ៉ា ឬប្តឹងទារសំណងផ្សេងៗដែល បណ្តឹងទាំងនេះស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ។

### កថាខណ្ឌទី១៖ បណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី ជារឿងដែលទាមទារសិទ្ធកម្មសិទ្ធ សំណង ការមហន្តរាយ និង ជំងឺផ្លូវចិត្តហើយជាប្រភេទវិវាទមួយ រវាងបុគ្គលនិងបុគ្គល ដែលមានបណ្តឹងជាច្រើនដែលតម្រូវឱ្យតុលាការធ្វើការដោះស្រាយរួមមាន៖ បណ្តឹងទាមទារសងជំងឺចិត្ត បណ្តឹងទាមទារកម្មសិទ្ធដីធ្លី បណ្តឹងទាមទារប្រាក់ជំពាក់...។ ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើទៅបានក្នុងនាមជនរងគ្រោះ ឬជាអ្នកតំណាងស្របច្បាប់របស់ខ្លួនកាលណា ជនរងគ្រោះជាអនិតិជន ឬជានីតិជននៅក្រោមរបបច្បាប់ការពារ ។ បណ្តឹងរដ្ឋប្បវេណី និង ព្យសនកម្ម ត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស ។ ដើម្បីទទួលបានការជួសជុលព្យសនកម្មបានត្រូវតែ ៖

- ជាផលវិបាកផ្ទាល់នៃបទល្មើស
- ជាព្យសនកម្មផ្ទាល់ខ្លួន បានកើតឡើង និង នៅក្នុងពេលបច្ចុប្បន្ន ។

ព្យសនកម្មអាចជា ព្យសនកម្មខាងសម្ភារៈ ខាងរូបរាងកាយ ផ្លូវចិត្ត ។ ការជួសជុលព្យសនកម្ម អាចធ្វើបានដោយការបង់ជម្ងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញ នៅទ្រព្យសម្បត្តិដែលបាត់បង់ ឬ ដោយការធ្វើឱ្យដូចសភាពដើមវិញនូវទ្រព្យសម្បត្តិគេបានបំផ្លិចបំផ្លាញ ឬ ធ្វើឲ្យខូចខាត ។ បណ្តឹងរដ្ឋប្បវេណីមានដូចជាៈ

- ការបៀតបៀនដោយចេតនាដល់អាយុជីវិតអ្នកដទៃ
- ការបៀតបៀនដោយបូរណភាពនៃបុគ្គល
- ការបៀតបៀនខាងផ្លូវចិត្ត
- ការរើសអើងអ្នកដទៃ ការបំផ្លិចបំផ្លាញ ឬ ការធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ
- ការជេរប្រមាថអ្នកដទៃ ។

និតិវិធីដោះស្រាយវិវាទរដ្ឋប្បវេណីរួមមានៈ

• **ដំណាក់កាលផ្សះផ្សា** ៖ នៅក្នុងដំណាក់កាលផ្សះផ្សារនេះ មានតែចៅក្រមម្នាក់និងក្រលាបញ្ជីម្នាក់ដែលជាអ្នកកត់ត្រាប៉ុណ្ណោះ ។ ចៅក្រមព្យាយាមប្រើនិតិវិធីនិយាយឱ្យគូភាគីទាំងសងខាងត្រូវរ៉ូវគ្នាវិញក្នុងគោលបំណងឲ្យមានសាមគ្គីភាព និង ការយោគយល់គ្នាទៅវិញទៅមក ដើម្បីឈានទៅរកការដកពាក្យបណ្តឹងទៅវិញ ។ ក្នុងការផ្សះផ្សានេះចៅក្រមពុំចាំបាច់មានភស្តុតាង ឬ សាក្សីអ្វីឡើយ ។

• **ដំណាក់កាលស៊ើបសួរ** ៖ ជាដំណាក់កាលដែលចៅក្រមអស់លទ្ធភាពផ្សះផ្សារគូរភាគីទាំងពីរឱ្យដកពាក្យឈប់ប្តឹងវិញ ហើយនិតិវិធីរបស់តុលាការពេលនេះគឺ បង្គាប់ឱ្យ គូរភាគីជូនភស្តុតាងតាមផ្លូវច្បាប់ហៅថា ដីការបង្គាប់ឱ្យជូនសម្អាង បន្ទាប់មកតុលាការចាប់ផ្តើមស៊ើបសួរតាមនិតិវិធីផ្សេងៗ ។ ក្នុងដំណាក់កាលស៊ើបសួរនេះគឺជាការតទល់ជាមួយសាក្សី ជាការសំខាន់ហើយមានប្រយោជន៍ដល់ខ្លួន ហើយអាចឲ្យចៅក្រមសួរចម្លើយតទល់រវាងសាក្សីនិងសាក្សី ឬ រវាងគូរភាគីនិងសាក្សី ។

• **ដំណាក់កាលជំនុំជម្រះ** ៖ ជាដំណាក់កាលចេញសេចក្តីសម្រេចបញ្ចប់រឿងក្តី ។ ក្រោយពីបានទទួលដីការចូលជំនុំជម្រះ ប្រធានតុលាការ ចាត់តាំងចៅក្រមណាម្នាក់ ដើម្បីចាត់ការរឿងក្តីនោះរហូតដល់មានការចេញសាលក្រម ៖

- **សាលក្រម** ជាសេចក្តីសម្រេចចុងក្រោយបង្អស់របស់សាលាជម្រះក្តីជាន់ទាបរួមមាន តុលាការរាជធានី-ខេត្ត និង តុលាការយោធា ។
- **សាលដីការ** គឺជាសេចក្តីសម្រេចចុងក្រោយរបស់តុលាការជាន់ខ្ពស់រួមមាន សាលាឧទ្ធរណ៍ និង តុលាការកំពូល ។
- **សាលក្រមរបៀប** គឺជាសេចក្តីសម្រេចរបស់តុលាការជាន់ទាប មុនអង្គសេចក្តីក្នុងពេលបើកសាវនាការ ហើយសេចក្តីសម្រេចមិនទាន់ចូលដល់ ឬ មិនប៉ះពាល់ដល់អង្គសេចក្តីនៃសំនុំរឿងទេ ឬ អាចហៅម្យ៉ាងទៀតថា សេចក្តីសម្រេចបណ្តោះអាសន្នរបស់តុលាការក្នុងពេលបើកសាវនា-ការ ។
- **សាលក្រមកំបាំងមុខ** គឺជាសាលក្រមដែលសម្រេចកំបាំងមុខគូភាគីណាមួយ ពោលគឺជាសាលក្រមដែលសម្រេចសេចក្តីដោយគ្មានមុខដើមចោទ ឬ ចុងចោទ ។

### កថាខណ្ឌទី២៖ បណ្ដឹងព្រហ្មទណ្ឌ

បណ្ដឹងព្រហ្មទណ្ឌ ជាបណ្ដឹងដែលទាក់ទងនឹងអំពើទាំងឡាយណាដែលបានធ្វើឱ្យខូចសណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ឬអំពើប្រឆាំងនឹងមនុស្ស អំពើដែលប៉ះពាល់នៃបូរណភាពនៃបុគ្គល ប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ សេរីភាព ឬ សិទ្ធរបស់មនុស្ស អំពើបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ... ។

និតិវិធីដោះស្រាយទំនាស់ព្រហ្មទណ្ឌ វិធីដោះស្រាយ ផ្លូវបណ្ដឹងរឿងព្រហ្មទណ្ឌមានបីដំណាក់កាល៖

- **ដំណាក់កាលអយ្យការ** ជាដំណាក់កាលស៊ើបអង្កេតបឋម ពេលទទួលសំនុំរឿងពីប្រជាជន ឬមន្ត្រីនគរបាលយុត្តិធម៌ អយ្យការចាត់ការសាកសួរភ្លាម ។ ការសាកសួរនេះ គឺធ្វើឡើងព្រះរាជអាជ្ញារង ពោលគឺអយ្យការបានបានកោះហៅដើមបណ្ដឹង ជនរងគ្រោះជាសាក្សី និងជនសង្ស័យមកសាកសួរ ។ ពេលសួរចប់ចៅក្រមស៊ើបអង្កេតហៅថា "ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ។
- **ដំណាក់កាលស៊ើបអង្កេត** ជាដំណាក់កាលស៊ើបអង្កេតរយៈពេលវែងចៅក្រមស៊ើបសួរអាចសាកសួរអ្នកដែលមានឈ្មោះ ទាក់ទិនក្នុងសំនុំរឿងវិញទាំងអស់ ។ ចៅក្រមស៊ើបអង្កេតរយៈពេលពី ១ ខែដល់ ៦ ខែទៅតាមរឿង និងជនជាប់ពិរុទ្ធ លើបទឧក្រិដ្ឋ ឬ បទមជ្ឈឹម ។
- **ដំណាក់កាលជំនុំជម្រះ** ជាដំណាក់កាលចុងក្រោយបំផុត គឺដំណាក់កាលជំនុំជម្រះនៅតុលាការក្នុងដំណាក់កាលចុងក្រោយនេះមានសេចក្ដីសម្រេចដូចជា៖
    - សេចក្ដីសម្រេចមុនអង្គសេចក្ដី ជាសេចក្ដីសម្រេចបណ្ដោះអាសន្នដូចជាជនជាប់ចោទសុំដាក់ធានាដើម្បី ឲ្យបាននៅក្រៅឃុំបណ្ដោះអាសន្ន ។
    - សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលសម្រេចកំបាំងមុខគូភាគីណាមួយ ពោលគឺជាសាលក្រមដែលសម្រេចសេចក្ដីដោយគ្មានមុខដើមចោទ ឬ ចុងចោទ។
    - សាលក្រមចំពោះមុខ គឺជាជនជាប់ចោទចូលបង្ហាញខ្លួន នៅពេលសវនាការ នោះសាលក្រមជាសាលក្រមចំពោះជនជាប់ចោទ ។ សាលក្រមចំពោះមុខជនជាប់ចោទ មិនត្រូវឱ្យ ដំណឹងដល់ជននោះទេ សាលក្រមចំពោះមុខអាចប្ដឹងឧទ្ធរណ៍បាន។ សាលក្រមនៅតែជាសាលក្រមសាលក្រមចំពោះមុខដដែល ទោះបីជាជនជាប់ចោទចាកចេញពីបន្ទប់សាវនាការក៏ដោយ ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីធ្វើការបកស្រាយរួចមក យើងអាចសន្និដ្ឋានបានថា ប្រធានបទ "**របបគតិយុត្តគ្រប់គ្រងលើវិស័យសំណង់នៅកម្ពុជា**" នេះពិតជាមានសារៈសំខាន់ណាស់សម្រាប់គ្រប់គ្រងទៅលើប្រភេទសំណង់ ដែលវិញទៀតនោះគឺប្រធានបទនេះ ស្របទៅនឹងបរិបទនៃកំណើនឥតស្រកស្រុតរបស់វិស័យសំណង់នៅកម្ពុជា ។ យោងតាមស្មារតីនៃមាត្រា ១៤ នៃច្បាប់រៀបចំទឹកដី នគរូបនីយ៍កម្ម និងសំណង់ *"រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាព ឬការកែប្រែការប្រើប្រាស់សំណង់ណាមួយ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច"* បន្ថែមលើនេះដែរ *"ពាក្យស្នើសុំអនុញ្ញាតសាងសង់ត្រូវមានឯកសារ និងបង់ជាចាំបាច់"* ក្នុងន័យនេះបង្ហាញថាដើម្បីធ្វើការសាងសង់នូវរាល់បណ្តាសំណង់គ្រប់ប្រភេទចាំបាច់ត្រូវតែមានលិខិតអនុញ្ញាតសាងសង់ ដែលលិខិតនេះត្រូវបានប្រគល់ជូនឱ្យម្ចាស់សាមីនៃសំណង់ ឬអ្នកតំណាងស្របច្បាប់ដែលទទួលបានការប្រទានសិទ្ធិ ក្រោមពីបានធ្វើការដាក់ពាក្យស្នើសុំ ។ ប៉ុន្តែទន្ទឹមនឹងនេះដែរ ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចទៅលើវិស័យនេះ ជាពិសេសផ្នែកលិខិតអនុញ្ញាតនៅតែសម្តែងនូវអត្តចរិតទន់ភ្លន់មកលើប្រជាពលរដ្ឋរបស់ខ្លួន ដោយយោងតាមមាត្រា៣ នៃអនុក្រឹត្យលេខ៨៦ ស្តីពីលិខិតអនុញ្ញាតសាងសង់ បានកំណត់ប្រភេទនៃបណ្តាសំណង់មួយចំនួនដែលពុំចាំបាច់តម្រូវឱ្យមានលិខិតអនុញ្ញាសាង់សង់ឡើយមានជាអាទិ៍៖ សំណង់ជាលំនៅឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ដាច់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក តំបន់ទេសចរណ៍ តំបន់បេតិកភណ្ឌជាតិ តំបន់រក្សាការពារដោយពុំគិតពីទំហំ ឬសម្ភារសំណង់ប្រើប្រាស់ រីឯការជួសជុលឬការថែរក្សាដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ក៏ដូចគ្នាដែរ លើកលែងតែការជួសជុលឬកែថែរក្សានោះអាចបណ្តាលឱ្យមានការប៉ះពាល់ដល់អ្នកជិតខាង ម្យ៉ាងវិញទៀតសំណង់ដែលមានលក្ខណៈជាទីសក្ការៈបូជា សាលាសំណាក់សាធារណៈ ឬបណ្តាការរសិល្បៈដែលបម្រើឱ្យប្រយោជន៍សាធារណៈដែលរដ្ឋជាម្ចាស់គម្រោង គឺគ្រាន់តែផ្តល់ការជូនដំណឹងបានហើយ ។ ដែលកាយវិការនេះគឺធ្វើឡើងក្នុងគោលបំណងដើម្បីសម្រួលកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ មួយវិញទៀតគឺធ្វើឡើងក្នុងគោលបំណងសម្រួលឱ្យប្រជាពលរដ្ឋដែលនៅទីជនបទដែលមានគម្រោងធ្វើការសាងសង់លំនៅឋានរបស់ខ្លួនមានលទ្ធភាពក្នុងការសាងសាងលំនៅឋានបានគ្រប់ៗគ្នា ។ មួយវិញទៀតនោះ ស្ថាប័នដែលទទួលបន្ទុកក្នុងការផ្តល់ជូននូវលិខិតអនុញ្ញាតសាងសង់ត្រូវបានបែងជាពីរថ្នាក់ គឺ៖ សមត្ថកិច្ចរបស់សាលារាជធានី/ខេត្ត ឬអាចហៅថាសមត្ថកិច្ចរបស់អាជ្ញាធរដែនដី និងមួយទៀតជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ឬក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដែលកាលពីឆ្នាំ១៩៩៤ នោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ពុំទាន់ត្រូវបានបង្កើតនៅឡើយទេ រហូតមកដល់ឆ្នាំ១៩៩៩ ទើបក្រសួងនេះត្រូវបានបង្កើតឡើង ។ សាលារាជធានី/ខេត្តមានសមត្ថកិច្ចផ្តល់ជូនលិខិតអនុញ្ញាតសាងសង់ចំពោះបណ្តាប្រភេទសំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់តិចជាង៣,០០០ម៉ែត្រការេ ចំណែកឯសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលវិញគឺមានតួនាទីផ្តល់ជូននូវលិខិតអនុញ្ញាត

សាងសង់ចំពោះបណ្តាសំណង់ទាំងសាធារណៈ និងឯកជនដែលមានផ្ទៃក្រឡាកម្រាលសំណង់លើសពី៣,០០០ ម៉ែត្រការេ ឬបណ្តាអគារសម្រាប់ការបង្កបង្កើនផលកសិកម្ម សម្រាប់ធ្វើអាជីវកម្មពី ៥០០ហិចតាឡើងទៅ ។[91] ដោយឡែក ដើម្បីការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតគឺត្រូវដាក់ដោយ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលបានសិទ្ធិពីម្ចាស់កម្មសិទ្ធិ[92] ហើយត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនរួមមាន៖[93]

- ពាក្យសុំលិខិតអនុញ្ញាតសាងសាង់
- វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ អចលនវត្ថុ ឬលិខិតកាន់កាប់ដីជាបណ្តោះអាសន្ន
- សលាកបត្រដីឡូត៍
- ប្លង់ទីតាំងអគារក្នុងដីឡូត៍
- ប្លង់អគារគ្រប់ជាន់ មាត្រដ្ឋាន ១/១០០
- ប្លង់ផ្នែកបណ្តាញក្រោមដីនានា និងអាងបង្គន់អនាម័យ មាត្រដ្ឋាន ១/១០០
- ប្លង់មុខភាពនៃអគារ មាត្រដ្ឋាន ១/១០០
- ប្លង់ពុះពីរយ៉ាងតិច មាត្រាដ្ឋាន ១/១០០
- តារាងផ្ទៃក្រឡាមួយសម្រាប់ជាន់នីមួយៗ
- សលាកបត្រគណនាផ្ទៃបាតផ្ទាល់ដី និងសន្ទទស្សន៍នៃការប្រើប្រាស់ ។

ទន្ទឹមនឹងការស្នើសុំលិខិតអនុញ្ញាតសាងសង់នេះដែរ មុនពេលដែលចាប់ផ្តើមសាងសង់ និងក្រោយពេលការសាងសង់បានបញ្ចប់តម្រូវឱ្យអ្នកសាងសង់ចាំបាច់ត្រូវស្នើសុំលិខិតបើក និងបិទការដ្ឋានសំណង់ ហើយចំពោះការដ្ឋានសំណង់នីមួយៗ ចាំបាច់ត្រូវហ៊ុំព័ទ្ធដោយរបងកម្ពស់២ម៉ែត្រយ៉ាងទាបបំផុត និងមិនត្រូវធ្វើលើថ្នល់សាធារណៈ ហើយសំណង់ដែលសាងសង់ចាប់ពី៥ម៉ែត្រឡើងទៅ ត្រូវហ៊ុំព័ទ្ធដោយក្រណាត់កៅស៊ូ ឬសំណាញ់សុវត្ថិភាព[94] បើករណីដែលទីតាំងការដ្ឋានតូចចង្អៀតវិញ ការធ្វើរបងបិទបាំងបណ្តោះអាសន្នលើចិញ្ចើមថ្នល់សាធារណៈត្រូវទុកឱ្យមានចន្លោះផ្លូវដើរ និងមានរបាំងការពារតាមទំហំដែលអនុញ្ញាត និងកំណត់ដោយអាជ្ញាធរ ។ ងាកមកចាប់អារម្មណ៍ទៅលើក្រុមជាងសំណង់ ដែលជាតួអង្គក៏សំខាន់ក្នុងកិច្ចការសាងសង់ និងសហគ្រាស និងក្រុមហ៊ុន ដែលសិក្សាលើគម្រោងប្លង់វិញ គឺចាំបាច់ត្រូវតែធ្វើការសុំប្រកបអាជីវកម្ម និងចុះបញ្ជីពាណិជ្ជកម្មដើម្បី

[91] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់, មាត្រា៥

[92] មាត្រា១៦ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, ១៩៩៤

[93] អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់, មាត្រា៩

[94] ប្រកាសលេខ៣២ ប្រ.ក/ស.ណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់, ប្រការ៥

ទទួលបានការគ្រប់គ្រង និងធានានូវភាពស្របច្បាប់ជាចាំបាច់ ។

ដើម្បីពង្រឹងនូវប្រសិទ្ធភាពនៃការគ្រប់គ្រងរាជរដ្ឋាភិបាលបានបង្កើតឱ្យមានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាស្ថាប័នដែលមានសមត្ថកិច្ចគ្រប់គ្រងលើវិស័យសំណង់នេះផងដែរ ។ ជាងនេះទៅទៀតនោះ ដើម្បីបង្កភាពងាយស្រួលក្នុងការគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ក្រសួងរៀបចំដែនដីបង្កើតឱ្យមាននាយកដ្ឋានសំណង់ ដែលធ្វើការងារគ្រប់គ្រងលើផ្នែកសំណង់ និងបង្កើតឱ្យមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានី/ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក/ខណ្ឌ អាជ្ញាធរទាំងអស់នេះជាសេនាធិការ និងជាអ្នកដោះស្រាយនូវបញ្ហាមួយចំនួន ដែលកើតមានឡើងស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃការគ្រប់គ្រងរបស់ខ្លួន នេះជាការបង្ហាញនូវការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធនៃវិស័យសំណង់ ក្នុងគោលបំណងធ្វើវិមជ្ឈការនៃការគ្រប់គ្រងវិស័យសំណង់ដើម្បីធានានូវប្រសិទ្ធភាព និរន្តរភាព និងការអនុវត្តនៃរបបគតិយុត្ត ។

បើសិនក្រឡេកមើលពីបច្ចុប្បន្នភាពនៃវិស័យសំណង់វិញ យើងឃើញថាមានការរីកចម្រើនយ៉ាងច្រើន ជាពិសេសនោះសំណង់ប្រភេទជា អគារប្រណិតខ្ពស់ៗ និងបុរីជាដើម។ល។ ជាហេតុចាំបាច់ត្រូវតែតម្រូវឱ្យមានការគ្រប់គ្រងចំពោះសំណង់ប្រភេទនេះឱ្យកាន់តែមានភាពល្អប្រសើរ ដោយផ្តោតសំខាន់លើគុណភាព សុវត្ថិភាពជាចម្បង បន្ថែមលើសនេះគឺចាំបាច់ត្រូវតែមានភាពស្របច្បាប់ ចៀសវាងនូវហានិភ័យណាមួយ ដែលបណ្តាលមកពីកង្វះការយកចិត្តទុកដាក់ពីសំណាក់អ្នកវិនិយោគ ឬ អ្នកអភិវឌ្ឍ ។ ម៉្យាងវិញទៀត អ្នកអភិវឌ្ឍវិស័យសំណង់ និងសាធារណជនដែលជាម្ចាស់កម្មសិទ្ធិទាំងអស់ ក៏ត្រូវស្វែងយល់ពីសិទ្ធិ និងកាតព្វកិច្ចដែលត្រូវបំពេញ និងទទួលបានផងដែរ ។ ចំពោះអ្នកវិជ្ជាជីវៈ និងអ្នកផ្គត់ផ្គង់នូវសម្ភារៈសំណង់ក៏ដូចគ្នាដែរ គឺចាំបាច់ត្រូវមានការលិខិតប្រកបអាជីវកម្ម ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ហើយត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានវិញ្ញាបនបត្រធានារ៉ាប់រងដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈ និងអាជីវកម្មខ្លួន ។ កិច្ចសន្យាធានារ៉ាប់រងសំដៅដល់ការបំពេញកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យារវាងអ្នកប្រកបវិជ្ជាជីវៈ និងអតិថិជន ។

មួយវិញទៀត ការធ្វើអធិការកិច្ចសំណង់គឺជានីតិវិធីមួយដែលធ្វើឡើងដើម្បីពិនិត្យមើលពីភាពស្របច្បាប់នៃដំណើរការសាងសង់ផ្ទាល់នៅក្នុងការដ្ឋានសំណង់ ។ អធិការកិច្ចសំណង់នេះ ធ្វើឡើងដើម្បីធានាការគ្រប់គ្រងសំណង់ឱ្យមានប្រសិទ្ធភាព គុណភាព សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៃការរស់នៅឱ្យមានសុខដុមនីយកម្ម និងដើម្បីបង្កា និងទប់ស្កាត់នូវបណ្តាបទល្មើស ហានិភ័យ ឬគ្រោះថ្នាក់នានាដែលបណ្តាលមកពីការរំលោភបំពាន ឬការប្រព្រឹត្តផ្ទុយពីបទប្បញ្ញត្តិច្បាប់ ឬបទដ្ឋានគតិយុត្តគ្រប់គ្រងលើវិស័យសំណង់ ។ បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីធ្វើអធិការកិច្ចសំណង់ត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួង រវាង

រដ្ឋមន្ត្រី នៃក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។[95]

ទន្ទឹមនឹងការគ្រប់គ្រងការសាងសង់ ការដោះស្រាយវិវាទដែលកើតមានឡើងនៅក្នុងវិស័យសំណង់នេះក៏ជាផ្នែកមួយដ៏សំខាន់ផងដែរ ។ ដើម្បីធ្វើការដោះស្រាយនូវបណ្តាវិវាទទាំងឡាយក្នុងវិស័យសំណង់ គូភាគីដែលមានទំនាស់មានសិទ្ធិក្នុងការជ្រើសរើសបាន អាចធ្វើការដោះស្រាយតាមពីរប្រព័ន្ធ គឺ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ។ ដែលការធ្វើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះដែរ គឺធ្វើឡើងតែចំពោះវិវាទរដ្ឋប្បវេណី និងបទលហុ តែប៉ុណ្ណោះ ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាដំណាក់កាលដំបូងបង្អស់ក្នុងការដោះស្រាយនូវទំនាស់ និងជាជម្រើសដ៏ល្អប្រសើរដល់គូភាគីវិវាទដែលបានឯកភាពគ្នា និងទាមទារឱ្យគូភាគីត្រូវព្យាយាមដោះស្រាយដោយសន្តិវិធីដើម្បីទទួលបានជោគជ័យ ។ ការដោះស្រាយតាមប្រព័ន្ធនេះអាចថាមានភាពងាយស្រួល និងចំណាយថវិកាតិចក៏បាន បើកាលណាការលើក/ដាក់លក្ខខណ្ឌរបស់គូភាគីមានភាពសមរម្យអាចទទួលយកបាននោះ ការដោះស្រាយប្រាកដជាមានភាពរលូន ប៉ុន្តែបើការចរចា ឬការលើកលក្ខខណ្ឌពុំអាចទទួលយកបាននោះ ការដោះស្រាយនឹងត្រូវអូសបន្លាយពេលយូរ ជាហេតុនាំឱ្យមានការខាតបង់នូវពេលវេលា និងប្រយោជន៍ផ្សេងៗទៀត ដែលបណ្តាលមកពីការអូសបន្លាយពេលវេលានោះ ។ ផ្ទុយទៅវិញ វិធីសាស្ត្រនេះមិនមែនជាជម្រើសចុងក្រោយបង្អស់របស់គូភាគីឡើយ ព្រោះគូភាគីអាចជ្រើសរើសនូវការដោះស្រាយតាមផ្លូវតុលាការដោយផ្ទាល់ ឬបន្ទាប់ពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនទទួលបានជោគជ័យ ឬមានការអូសបន្លាយពេលយូរ ដែលនាំឱ្យខាតពេលវេលា ។ រីឯការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការវិញគឺធ្វើឡើងតាមនីតិវិធីទូទៅ ដែលបានកំណត់ដោយច្បាប់ ។

សរុបជារួមមក ប្រធានបទនេះពិតជាមានសារសំខាន់ណាស់សម្រាប់សាធារណជនទូទៅ អ្នកវិនិយោគ ឬអ្នកអភិវឌ្ឍ ជាពិសេសនោះសម្រាប់បងប្អូន មិត្តនិស្សិត ក៏ដូចជាអ្នកស្រាវជ្រាវទាំងអស់ដែលមានបំណងស្វែងយល់ ដើម្បីពង្រឹង និងពង្រីកនូវពុទ្ធិ ដែលទាក់ទងនឹងការគ្រប់គ្រងលើវិស័យសំណង់ ។

[95] មាត្រា៥៣ កថាខណ្ឌទី៣ នៃច្បាប់សំណង់ ២០១៩

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវនូវប្រធានបទស្តីពី **"របបគតិយុត្តគ្រប់គ្រងលើវិស័យសំណង់នៅកម្ពុជា"** នេះរួចមក ក្រុមយើងខ្ញុំពេញចិត្តនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ដូចជាស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដែលបានខិតខំ យកចិត្តទុកដាក់ ក្នុងការគ្រប់គ្រងលើវិស័យមួយនេះដើម្បីឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រង ក្នុងគោលដៅរក្សាសណ្តាប់ធ្នាប់សាធារណៈ គុណភាព សុវត្ថិភាព និងធានាភាពស្របច្បាប់ ។ ទន្ទឹមនឹងគុណសម្បត្តិនេះផងដែរ ក៏មាននូវកង្វះខាតមួយចំនួនផងដែរ ព្រោះថាថ្វីត្បិតតែស្ថាប័នគ្រប់គ្រងធ្វើការគ្រប់បានល្អ និងមានរបបគតិយុត្តគ្រប់គ្រងវិស័យសំណង់ក៏ដោយ ក៏នៅតែមានសាធារណជនទូទៅភាគច្រើនពុំទាន់បានយល់ច្បាប់អំពីវិធានទាំងនោះដដែរ ។ ដូច្នេះគួរតែមានកម្មវិធីណាមួយក្នុងការផ្សព្វផ្សាយនូវរបបគតិយុត្តទាំងនេះដល់សាធារណជនបានជ្រាប ព្រមទាំងមានវាគ្មិនដើម្បីធ្វើការឆ្លើយតបនឹងរាល់ចម្ងល់ដែលទាក់ទងនឹងវិស័យនេះ ។ មួយវិញទៀត ចាត់វិធានការឱ្យមានប្រសិទ្ធិភាពដល់ជនខិលខូចដែលនៅតែប្រព្រឹត្តសកម្មភាពយ៉ាងគឃ្លើន ល្មើសនឹងបច្ចេកទេសក្នុងការសាងសង់ ក៏ដូចជាបទល្មើសដទៃទៀតដែលទាក់ទងនឹងវិស័យសំណង់នេះដែរ ដើម្បីចៀសវាងការកើតមាននូវហានិភ័យផលប៉ះពាល់ផ្សេងៗ ជាពិសេសឧទ្ទេវហេតុបាក់ស្រុតរលំអគារ ដែលបានកើតមានឡើងកាលពីកន្លងទៅនាខេត្តព្រះសីហនុ និងខេត្តកែប ជាងនេះទៀតនោះ ចំពោះមន្ត្រីដែលគ្រប់គ្រងវិស័យសំណង់ណាមួយដែល ក្នុងដែនសមត្ថកិច្ចមានបញ្ហាទាំងនេះគួរតែមានវិធានការដ៏សមស្របមួយ ឱ្យស័ក្តិសមនឹងការធ្វេសប្រហែសរបស់គាត់ ។ ឆ្លើយតបនឹងហានិភ័យទាំងនេះ អ្នករងគ្រោះដំបូងគេនោះគឺកម្មករសំណង់ ហើយកម្មករសំណង់នេះដែរ គឺជាតួអង្គដ៏សំខាន់នៃការសាងសង់ ដូចនេះគួរតែមានការការពារ និងការធានារ៉ាប់ពីហានិភ័យផ្សេងៗមកលើកម្មករសំណង់ទាំងនោះ ដើម្បីគាំពារពួកគាត់ពីហានិភ័យទាំងឡាយ និងការពារអត្ថប្រយោជន៍ផ្សេងៗដល់កម្មករសំណង់ទាំងនោះ ។

# ឯកសារយោង

## ឯកសារយោង

### ១.ច្បាប់

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣
- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយ៍កម្ម និងសំណង់, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤
- ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩, ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩
- ច្បាប់ភូមិបាល, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤, ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១
- ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥
- ច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១០/០០៦, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០
- ច្បាប់ស្តីពីផ្លូវថ្នល់, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨, ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤
- ច្បាប់ស្តីពីសំណង់, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩, ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

### ២. អនុក្រឹត្យ

- អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧
- អនុក្រឹត្យលេខ៦២ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩
- អនុក្រឹត្យ១២៦ អនក្រ.បក ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ, ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩
- អនុក្រឹត្យលេខ១៩៧ អនក្រ.បក ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិ និងផ្លូវរថភ្លើង នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩
- អនុក្រឹត្យលេខ៨២ អនក្រ.បក ស្តីពីការកំណត់ចំនួនសមាមាត្រ និងរបៀបគិតគូរចំណែកឯកជនដែល

អាចជាកម្មសិទ្ធិរបស់ជនបរទេស នៅក្នុងអគារសហកម្មសិទ្ធិ, ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០

- អនុក្រឹត្យលេខ៣៩ អនក្រ.បក ស្តីពីការគ្រប់គ្រងបុរី, ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១
- អនុក្រឹត្យលេខ១១៤ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ, ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤
- អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥
- អនុក្រឹត្យលេខ៧៦ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃ អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥
- អនុក្រឹត្យលេខ២៣៥ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧

**៣. ប្រកាស**

- ប្រកាសលេខ៧៥ ប្រក/ដ.ន.ស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់, ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩
- ប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១
- ប្រកាសអន្តរក្រសួងលេខ៦៥៥ ប្រក.សហវ-ដនស-មផ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២
- ប្រកាសលេខ១៦៦ ប្រក.ដនស/អសណ ស្តីពីការកែសម្រួលប្រការ៧ និងប្រការ១០ នៃប្រកាសលេខ៧៥ ប្រក/ដនស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់, ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧
- ប្រកាសលេខ១៩២ ប្រក.ដនស/អសណ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់, ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧
- ប្រកាសលេខ៩៣ ប្រក.ដនស/អសណ ស្តីពីការការសម្រួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់, ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩
- ប្រកាសលេខ១២២២ សហវ.ប្រក ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩

- ប្រកាសលេខ០៧៤ ប្រក/អសណ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣
- ប្រកាសលេខ៩៦៥ សហវ/ប្រក ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន,ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦
- ប្រកាសអន្តរក្រសួងលេខ៣៥៦ សហវ-ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩
- ប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ជនស-កយ ស្តីពីនីតិវិធី និងបែបបទនៃការធ្វើអធិការកិច្ចសំណង់, ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

## ៤. សារាចរណែនាំ

- សារាចរណែនាំលេខ០០១ ស្តីពីការគ្រប់គ្រងក្រុមជាងសំណង់,ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០
- សារាចរណែនាំលេខ០០២ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ និងសាងសង់ របស់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គលបរទេស, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

## ៥. សៀវភៅ

- សម្តេចព្រះសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរ ភាគ១ ភាគ២*.ភ្នំពេញ, ឆ្នាំ១៩៦៧
- សាលារាជធានីភ្នំពេញ, *ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព សម្រាប់រាជធានីភ្នំពេញ ២០១៩-២០៣០*. ភ្នំពេញ, ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, *របាយការណ៍បូកសរុបលទ្ធផលការងារ ប្រចាំខែឧសភា ឆ្នាំ២០២០ និងលើកទិសដៅបន្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*. ភ្នំពេញ, ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០

## ៦. គេហទំព័រ

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, http://www.mlmupc.gov.kh/
- សាលារាជធានីភ្នំពេញ, http://www.phnompenh.gov.kh/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយ៍កម្ម និងសំណង់
- ឧបសម្ព័ន្ធទី២ អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ១៩៩៧
- ឧបសម្ព័ន្ធទី៣ ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩, ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ច្បាប់ស្តីពីសំណង់

# ឧបសម្ព័ន្ធទី១

# ច្បាប់ ស្តីពី

# ការរៀបចំទឹកដី នគរូបនីយកម្ម

# និងសំណង់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

........

# ច្បាប់

## ស្តីពី

# ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

ព.ស ២៥៣៨ គ.ស ១៩៩៤

# ច្បាប់
# ស្ដីពី
# ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

## ជំពូកទី ១
## កម្មវត្ថុ

មាត្រា ១.-

ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានកម្មវត្ថុជំរុញអោយមានការរៀបចំកែលំអទីក្រុងនិងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេស ក្នុងស្មារតី :

- គោរពប្រយោជន៍រួមនិងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផងនិងត្រួតពិនិត្យការសាងសង់ផង ។
- ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុងនិងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រនិងលក្ខណៈពិសេសនៃជនបទនីមួយៗ ។
- ធានាលើកតំលៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌និងធានាការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍និងរក្សាបាននូវគុណភាពបរិដ្ឋាន ។

មាត្រា ២.-

ច្បាប់រៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នេះ ត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន ។ ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែឬផ្លាស់ប្ដូរ ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នឹងត្រូវកែច្នៃអោយស្របទៅតាមច្បាប់ភូមិបាលនេះដែរ ។

មាត្រា ៣.-

ដើម្បីសំរេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតអោយមានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលមានសមាជិកនិងសំណើការតែងតាំងនឹងរៀបចំដោយអនុក្រឹត្យ ។

ចំពោះរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់សំរាប់ក្រុងភ្នំពេញមួយត្រូវបង្កើត ។ គណៈកម្មាធិការនេះដឹកនាំដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ហើយដែលមានប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំ-ពេញឬអភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេស ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផងដែរ ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ សំរាប់ក្រុងភ្នំពេញត្រូវកំរិតដោយអនុក្រឹត្យ ។

ចំពោះខេត្ត ក្រុងនានា ត្រូវបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលដឹកនាំដោយអភិបាលខេត្ត ក្រុង និងអង្គភាពបច្ចេកទេសខេត្ត ក្រុង ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផង ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយសេចក្តីសំ-រេចរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ក្រោយពីមានការយល់ព្រមរបស់គណៈកម្មាធិការជាតិនេះ ។

# ជំពូកទី ២
## ឯកសារទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

មាត្រា ៤.-

ឯកសារទាំងឡាយ ដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ត្រូវរៀបចំតាមករណីនីមួយៗ អោយសមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដី ខេត្ត ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិដ្ឋានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។

មាត្រា ៥.-

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានីភ្នំពេញឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ខេត្ត ក្រុងនីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំនិងអភិវឌ្ឍន៍នៃរាជធានី ខេត្ត ក្រុងរបស់ខ្លួន ។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់និងកំណត់ដោយអនុក្រឹត្យ ។

ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិដ្ឋាននិងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានភារៈរៀបចំប្លង់គោលសំរាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត ។

# ជំពូកទី ៣
## ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់

មាត្រា ៦.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវរៀបចំឡើងសំរាប់រាជធានី ខេត្ត ក្រុង ។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជនក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន ។

មាត្រា ៧.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវតែបញ្ជាក់អោយច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្ម សំរាប់ សិប្បកម្ម សំរាប់វប្បធម៌ សំរាប់ទេសចរណ៍ សំរាប់សាសនា ព្រមទាំងសំរាប់សំណង់នៃរដ្ឋបាលនិងបរិក្ខាសាធារណៈ ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសំរាប់សាងសង់ ។

មាត្រា ៨.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

មាត្រា ៩.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់សំរាប់រាជធានីនិងខេត្ត ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានី ឬ អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ខេត្ត ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ទៀត ។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងដែរ ។

មាត្រា ១០.-

រាជរដ្ឋាភិបាលរៀបចំបទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារនិងលើកតម្លៃរមណីយដ្ឋានឬអចលនវត្ថុណាដែលនឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពឬបច្ចេកទេស ។ បញ្ជីអចលនវត្ថុឬ

រមណីយដ្ឋានទាំងនោះនិងកំណត់ដោយអនុក្រឹត្យ ។ ការរុះរើ ការផ្លាស់ប្តូរទ្រង់ទ្រាយនិងការគ្រប់គ្រងអចលនវត្ថុនិងរមណីយដ្ឋានទាំងនោះ ត្រូវកំណត់ដោយច្បាប់ស្តីពីការការពារបេតិកភណ្ឌ ។

បទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារនិងលើកតម្លៃរមណីយដ្ឋានឬអចលនវត្ថុដែលផ្តល់ផលប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពឬបច្ចេកទេសត្រូវចារឹកក្នុងប្លង់គោលរៀបចំទឹកដី នគរូបនីយកម្មនិងអភិវឌ្ឍន៍និងចារឹកក្នុងប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ។

រាជរដ្ឋាភិបាលកំណត់ដោយអនុក្រឹត្យនូវបញ្ជីអចលនវត្ថុដែលមានប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពនិងបច្ចេកទេស ដើម្បីធានាការគ្រប់គ្រងអចលនវត្ថុទាំងនេះ តាមបញ្ញត្តិច្បាប់ស្តីពីការការពារបេតិកភណ្ឌ ។

# ជំពូកទី ៤
# ការងារនិងសំណង់

មាត្រា ១១.-

រាល់ការកកាយរុករកឬការស្ទង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យា ចាំបាច់ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យាឬប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋានត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចអោយបានជ្រាបភ្លាមៗ ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់ផ្អាកសំណង់ជាបន្ទាន់ ។

មាត្រា ១២.-

រាល់បុគ្គលឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនអោយសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅ ៖

- ទីបំរុងទុកទឹកនិងទំនប់ទឹក
- ទីបំរុងជីករ៉ែនិងតំបន់ព្រៃឈើ
- រមណីយដ្ឋានបុរាណវិទ្យានិងប្រវត្តិសាស្ត្រ
- សួនច្បារ ឧទ្យានសាធារណៈនិងតំបន់អភិរក្ស
- ដីបំរុងទុកសំរាប់ផ្លូវ បំរុងសំរាប់ចំណីផ្លូវនិងដីបំរុងទុកសំរាប់ផ្លូវរថភ្លើងនិងអាកាសយានដ្ឋាន
- ទន្លេ សមុទ្រ ព្រែក ស្ទឹងព្រមទាំងឆ្នេរច្រាំង
- ជាទូទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនឲ្យសង់ ។

លក្ខខ័ណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ លក្ខខ័ណ្ឌសំណង់ឬតាំងទីលំនៅធុនស្រាល បណ្តោះអាសន្ន អនុញ្ញាតបានដោយអនុក្រឹត្យ

មាត្រា ១៣.-

ការងារសាងសង់និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាមឯកសារដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ គោរពតាមប្លង់គោលដែលមានចែងក្នុងមាត្រា ៤ និង ៥ នៃច្បាប់នេះ ។

មាត្រា ១៤.-

រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាពឬការកែប្រែការប្រើប្រាស់សំណង់ណាមួយ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

ពាក្យស្នើសុំអនុញ្ញាតសាងសង់ត្រូវមានឯកសារនិងប្លង់ចាំបាច់ ។ និតិវិធីក្នុងការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៥.-

ឯកសារនិងប្លង់ចាំបាច់សំរាប់ភ្ជាប់ពាក្យសុំអនុញ្ញាតសាងសង់សំណង់ធំៗ ត្រូវរៀបចំឡើងដោយស្ថាបត្យករខ្មែរមានសញ្ញាប័ត្រឬជនណាដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ។

លក្ខខ័ណ្ឌដែលទាមទារអំពីសញ្ញាបត្រនិងទាមទារការទទួលស្គាល់ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៦.-

ពាក្យសុំអនុញ្ញាតសាងសង់ត្រូវយកមកដាក់សុំដោយម្ចាស់កម្មសិទ្ធិដីឬអ្នកបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ។ ពាក្យសុំអនុញ្ញាតនេះត្រូវមានភ្ជាប់មកជាមួយផងនូវឯកសារបញ្ជាក់អំពីកម្មសិទ្ធិរបស់ម្ចាស់ដី ។

មាត្រា ១៧.-

មិនអនុញ្ញាតអោយសាងសង់នូវសំណង់ណាក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោលឬប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ។

មិនអនុញ្ញាតអោយសាងសង់ បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិដ្ឋាន ប៉ះពាល់ដល់អនាម័យសាធារណៈ សំណង់ឬអចលនវត្ថុដែលមានសារប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពបច្ចេកទេសឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ ។

មិនអនុញ្ញាតអោយសាងសង់ បើសិនជាពុំមានការរៀបចំអោយមានហេដ្ឋារចនាសម្ព័ន្ធឬបរិក្ខាសាធារណៈអោយបានគ្រប់គ្រាន់និងគំរោងសំណង់ដែលសុំ ។

មាត្រា ១៨.-

ក្នុងករណីពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ អាជ្ញាធរខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មការដើម្បីពិនិត្យពាក្យសុំនិងចេញលិខិតអនុញ្ញាតសាងសង់ ។

មាត្រា ១៩.-

ចំពោះគំរោងសំណង់រដ្ឋបាល អង្គភាពដែលស្នើសុំសាងសង់ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ។

ការអនុញ្ញាតនោះអាចផ្តល់បានតែចំពោះសំណង់ណាដែលមានលក្ខណៈចាំបាច់សំរាប់ដំណើរការផ្នែករដ្ឋបាល ។

ការអនុញ្ញាតនេះមិនអាចនាំអោយមានការផ្លាស់ប្តូរនូវការប្រើប្រាស់ដីធ្លីដែលបានកំណត់មកហើយ ហើយក៏មិនអាចកែប្រែនូវលក្ខណៈសាធារណៈនិងអត្ថប្រយោជន៍ទូទៅនៃតំបន់នេះឡើយ ។

មាត្រា ២០.-

សំណង់ទាំងឡាយណាដែលអ្នកវិនិយោគទុនឯកជនបានសាងសង់នៅលើដីរបស់រដ្ឋស្របតាមកិច្ចសន្យាណាមួយ ត្រូវប្រគល់មកអោយរដ្ឋវិញពេលផុតកំណត់ចែងក្នុងកិច្ចសន្យានោះ ។

មាត្រា ២១.-

បើគ្មានមូលហេតុត្រឹមត្រូវដែលបានបញ្ជាក់ក្នុងច្បាប់នេះ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យពាក្យសុំសាងសង់ឬចេញលិខិតអនុញ្ញាតសាងសង់ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលមួយយ៉ាងយូរ ៤៥ ថ្ងៃទេនោះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ក៏ត្រូវផ្តន្ទាទោសផងដែរ ចំពោះភ្នាក់ងារណាដែលបានពិនិត្យគំរោងសាងសង់និងចេញលិខិតអនុញ្ញាតសាងសង់ដែលមិនស្របនឹងបទបញ្ញត្តិ ។

ភ្នាក់ងារត្រួតពិនិត្យលើសំណង់ដែលពុំបានជំទាស់ ពេលដែលខ្លួនឃើញសំណង់លើការដ្ឋានណាមួយមិនគោរពតាមគំរោងដែលបានអនុញ្ញាត ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ទណ្ឌកម្មផ្នែករដ្ឋបាលដែលត្រូវយកមកអនុវត្តចំពោះភ្នាក់ងារដែលមានកំហុសដូចបានរៀបរាប់ខាងលើនេះ ត្រូវកំណត់ដោយច្បាប់រដ្ឋបាល ។

ចំណែកឯអ្នកសាងសង់ដែលមិនគោរពលិខិតអនុញ្ញាតសាងសង់ទេនោះ នឹងត្រូវទទួលបង្គាប់អោយរុះរើកែសំណង់អោយស្របតាមលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ គឺចាប់ពីថ្ងៃទទួលលិខិតបញ្ជាផ្លូវការ ។

មន្ត្រីរាជការណាដែលរួមគំនិត នឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ ។

នៅពេលពិនិត្យឃើញមានសំណង់ខុសឆ្គង ការដ្ឋានត្រូវបញ្ឈប់ ហើយជាយថា-ហេតុ សម្ភារៈនិងឧបករណ៍សំណង់នៅទីនោះ ត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួន អ្នករងគ្រោះអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងទៅតុលាការទារជម្ងឺចិត្ត ។

មាត្រា ២២.-

ម្ចាស់សំណង់ មុនពេលវាយកំទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតរុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

បែបបទនៃការរុះរើវាយកំទេចសំណង់នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតអោយរុះរើវាយកំទេចសំណង់អាចត្រូវបដិសេធបាន ក្នុងលក្ខណៈដែលការរុះរើវាយកំទេចសំណង់នោះមានទាក់ទិននឹងបញ្ហាសង្គមកិច្ច បច្ចេកទេសនិងបេតិកភណ្ឌ ដែលរដ្ឋបានកត់ត្រា។

មាត្រា ២៣.-

បទបញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងច្បាប់ពីមុន ស្តីពីការរៀបចំទឹកដី នគរូប-នីយកម្មនិងសំណង់ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ ច័ន្ទ ទី ២៣ ខែឧសភា ឆ្នាំ១៩៩៤ នាសម័យប្រជុំ
រដ្ឋសភាលើកទី ២ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ១៩៩៤

ប្រធានរដ្ឋសភាស្តីទី

# ឧបសម្ព័ន្ធទី២

# អនុក្រឹត្យលេខ៨៦ អនក្រ.បក

# ស្តីពីលិខិតអនុញ្ញាតសាងសង់

# ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៩៦...អនក្រ.បក

2 5 DEC. 1997

# អនុក្រឹត្យ
## ស្តីពី
## លិខិតអនុញ្ញាតសាងសង់

* * * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៨៩៧/ ១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៤ នស ៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

## សំរេច

មាត្រា ១ : រាល់រូបវន្តបុគ្គល ឬនីតិបុគ្គល សាធារណៈ ឬឯកជន មានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះត្រូវបានទទួលការការពារដោយអនុក្រឹត្យនេះ ។ លិខិតអនុញ្ញាតសាងសង់ដែលត្រូវបានចេញអោយមុនការសាងសង់ ជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់ ។ ឯរបៀបសុំលិខិតអនុញ្ញាតសាងសង់មានអធិប្បាយនៅក្នុងវគ្គទី ១ នៃអនុក្រឹត្យនេះ ។

ដើម្បីឱ្យប្រជាពលរដ្ឋ ជាពិសេសប្រជាជនក្រីក្រមានលំនៅដ្ឋានសម្រាប់រស់នៅ រាល់សំណង់តូចតាចធ្វើអំពីឈើ ឬស្លឹក រុក្ខជាតិនានា ពុំទាមទារអោយសុំលិខិតអនុញ្ញាតសាងសង់ឡើយ ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

ដើម្បីធានាសុខមាលភាពនៃសំណង់ និង សុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារបីធីសាធារណៈចាំបាច់ សំរាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មបានល្អប្រសើរ បទបញ្ញត្តិទូទៅនៃសំណង់មានកំណត់អំពីសិទ្ធិ និងអំពីករណីយកិច្ចនៃប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈ ក្នុងការសាងសង់សំណង់សាធារណៈ និង សំណង់ឯកជន ។

រាល់ការគោរពនូវបទបញ្ញត្តិដែលមានចែងក្នុងវគ្គទី ២នៃអនុក្រឹត្យនេះ នឹងត្រូវបានទទួលលិខិតអនុញ្ញាតសាងសង់ ។

បទបញ្ញត្តិទាំងនេះ ត្រូវយកមកអនុវត្តក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និង ប្លង់គោល អនុម័តដោយរាជរដ្ឋាភិបាល ។

បទបញ្ញត្តិនេះអាចនឹងបំពេញបន្ថែម ដើម្បីឱ្យស្របទៅស្ថានភាពមូលដ្ឋាន ដោយស្ថិតក្នុងបទបញ្ញត្តិសំណង់ជាក់ស្តែងក្នុងប្លង់ប្រើប្រាស់ដីធ្លីរបស់ខេត្ត-ក្រុង ។

អនុក្រឹត្យនេះពុំងយកទៅអនុវត្ត លើសំណង់មានស្រាប់ដែលមានការអនុញ្ញាត ។
ចំពោះសំណង់មានស្រាប់ដែលគ្មានការអនុញ្ញាត ហើយដែលប៉ះពាល់យ៉ាងខ្លាំងដល់ប្រយោជន៍ ឬសោភ័ណភាពសាធារណៈ ការរុះរើត្រូវសំរេចដោយរាជរដ្ឋាភិបាល ឬតំណាងដែលបានទទួលសិទ្ធិប្រទាន តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច ។

# ជំពូកទី ១

# លិខិតអនុញ្ញាតសាងសង់ និង លិខិតអនុញ្ញាតរុះរើ

## ផ្នែក ១

## កាតព្វកិច្ចនៃលិខិតអនុញ្ញាតសាងសង់

មាត្រា ២: **សំណង់ដែលតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ជាមុន**

រាល់ការសាងសង់ក្នុងទីក្រុង និង ទីប្រជុំជន ត្រូវមានលិខិតអនុញ្ញាតសាងសង់

រាល់សំណង់ថ្មី សុទ្ធតែត្រូវមានលិខិតអនុញ្ញាតសាងសង់ ។

ការសាងសង់ឡើងវិញជាថ្មី ការពង្រីក និង ការសង់បន្ថែមពីលើអគារដែលមានស្រាប់ ក៏សុទ្ធតែតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ដែរ ។

ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើការងារនេះកែប្រែ :

- ការប្រើប្រាស់របស់ផ្នែកអគារ
- ទិដ្ឋភាពនៃអគារ ( Aspect des Bâtiments )
- ការធ្វើបង្គន់អនាម័យ និង ការបន្តភ្ជាប់ទៅបំពង់លូ
- ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ
- បង្កើនផ្ទៃក្រឡាកម្រាលសំណង់
- កន្លែងទទួលសាធារណៈជន ( Locaux ouverts au public )
- ទំរង់ដី (ចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចំការជាដីសាងសង់) ឬ ប៉ះពាល់ខ្លាំងដល់ទិដ្ឋភាពទីដ្ឋានណាមួយ ដូចជាលប់បំបាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ ការកាប់ដើមឈើដែលមានស្រាប់ ។ល។

ការសាងសង់ ឬ ការកែទ្រង់ទ្រាយបទភណ្ឌផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គីភ័យ (ការដាក់ស៊ីទែនកន្លែងស្តុកប្រេងឥន្ធនៈ រោងជាងដែលមានផលិតផលគ្រឿងផ្ទុះ កន្លែងទទួលសាធារណៈជន) ។ល។ ការប្តូរទ្រង់ទ្រាយអគារឧស្សាហកម្ម ការដាក់ផ្លាកផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍ និងទូរគមនាគមន៍ ផ្លាកស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀតដែលបំពាក់ទៅនឹងអគារ ហើយស្ថិតនៅជិតមាត់ផ្លូវ ឬ តាំងចំទិសដែលគេអាចមើលឃើញ សាលាក្រុង និង សាលាខេត្តនឹងធ្វើសេចក្តីណែនាំដោយឡែក ។

៥/៥

មាត្រា ៣: សំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់

- សំណង់ជាលំនៅដ្ឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និង ឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬ សម្ភារៈសំណង់ប្រើប្រាស់ឡើយ ។

- ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ លើលែងតែការជួសជុលនោះអាចបណ្តាលអោយប៉ះពាល់ដល់អ្នកជិតខាង ។

- បណ្តាសំណង់ដូចខាងក្រោមនេះ ដោយគ្រាន់តែជូនដំណឹងអំពីគំរោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន ដូចតទៅ :
- ទីសក្ការៈបូជា
- សាលាសំណាក់សាធារណៈ
- បណ្តាការស្ថាបត្យកម្មរបស់រដ្ឋសំរាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ

## ជំពូក ២

## សមត្ថកិច្ច ដែលចេញលិខិតអនុញ្ញាតសាងសង់

មាត្រា ៤ : សមត្ថកិច្ចរបស់សាលាខេត្ត និង សាលាក្រុង

៤.១ ខេត្ត-ក្រុង មានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

៤.២ លិខិតអនុញ្ញាតសាងសង់ ត្រូវបានចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង ឬ ដោយអភិបាលខេត្ត-ក្រុង ឬ អភិបាលរងដែលបានទទួលសិទ្ធិប្រទាន ។ រាល់ការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវមានការបញ្ជាក់ជាលាយល័ក្ខណ៍អក្សរ នូវមូលហេតុច្បាស់លាស់ ។

មាត្រា ៥ : សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល

៥.១ មានលិខិតអនុញ្ញាតសាងសង់មួយចំនួន ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលមានសមត្ថកិច្ចសំរេចផ្តល់ លិខិតអនុញ្ញាតសាងសង់ ចំពោះប្រភេទសំណង់ដូចតទៅ :

- បណ្តាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម និង ឧស្សាហកម្ម ដែលមានផ្ទៃក្រឡាក្រោលលើសពី ៣.០០០ ម៉ែត្រក្រឡា ។

- រាល់សណ្ឋាគារ ត្រូវចាត់ទុកជាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម ។

- បណ្តាអគារសំរាប់ការបង្កបង្កើនផលកសិកម្ម សំរាប់ធ្វើអាជីវកម្មពី ៥០០ហិចតាឡើងទៅ ។

- បណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអយស្ម័យយាន និង ស្ថានីយរថយន្ត ។

- បណ្តាសំណង់សាធារណៈ និង ឯកជន ដែលមានផ្ទៃក្រឡាក្រោលលើសពី ៣.០០០

ម៉ែត្រទ្ធេគុណ និងផ្នែកពង្រីកបន្ថែមដោយគិតទាំងអគារមានស្រាប់ ដែលលើសពី ៣.០០០ ម៉ែត្រទ្ធេគុណ ( វប្បធម៌ អប់រំកីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ថាមពលទឹក...) ។

- បណ្តាសំណង់សំខាន់ ៗ ក្នុងទីដ្ឋានការពារ និងក្នុងក្របខ័ណ្ឌបរិស្ថាន ទេសភាព បេតិកភ័ណ្ឌ ប្រវត្តិសាស្ត្រ បូរាណវត្ថុ និង វប្បធម៌ ។

- ការកែប្រែបណ្តាអគារ ជាផលប្រយោជន៍បេតិកភ័ណ្ឌដែលបានកំណត់ទុក ។

- បណ្តាសំណង់លើទីដីក្នុងភាពមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រ។

- បណ្តាសំណង់ និង ការ្យ សំរាប់ការពារ និង អគារយោធា ។

៥.២ ក្នុងករណីនេះ លិខិតអនុញ្ញាតសាងសង់ ត្រូវចុះហត្ថលេខា ដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

**មាត្រា ៦ : គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់របស់សាលាខេត្ត ឬ សាលាក្រុង**

៦.១ សមត្ថកិច្ច

អនុលោមតាមមាត្រា ១៨ នៃច្បាប់រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានបង្កើតឡើងក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី និង សំណង់ ។ គណៈកម្មការនេះ ត្រូវដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ។

គណៈកម្មការនេះពិនិត្យរាល់សំណុំលិខិតសុំអនុញ្ញាតសាងសង់ ។

ចំពោះលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ក្រោយពីគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ពិនិត្យសំណុំលិខិតហើយ ប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង និង អភិបាលខេត្ត-ក្រុង បញ្ជូនរបាយការណ៍ និង យោបល់ទៅគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ ដើម្បីសំរេច ។

៦.២ សមាសភាពរបស់គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ :

គណៈកម្មការមានសមាសភាពដូចតទៅ :

- ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ជាប្រធាន
- មន្ទីរ សុរិយោដី សមាជិក
- មន្ទីរ រៀបចំក្រុង និង សំណង់ ឬ ការិយាល័យសំណង់ ក្នុងករណីដែលមាន សមាជិក
- មន្ទីរ សាធារណៈការ សមាជិក

- មន្ទីរ បរិស្ថាន សមាជិក
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាងស្ថាប័នពាក់ព័ន្ធទៅលើគំរោងសំណង់នោះ សមាជិក
- ការិយាល័យ (មូលដ្ឋាន) កិច្ចការនគរោបនីយកម្ម សមាជិក

គណៈកម្មការមានសិទ្ធិកោះអញ្ជើញដើម្បីសាកសួរ ឬស្តាប់រាល់បុគ្គលដែលបានដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និង ម្ចាស់កម្មសិទ្ធិ បើម្ចាស់កម្មសិទ្ធិនោះពុំមែនជាអ្នកដាក់ពាក្យសុំ នៅពេលដែលសំណុំលិខិតអនុញ្ញាតសាងសង់នោះ បានចុះបញ្ជីជាផ្លូវការរួចហើយ ។

## ជំពូក ៣

## ការពិនិត្យមើលលើការចេញលិខិតអនុញ្ញាតសាងសង់

មាត្រា ៧ : គ្មានលិខិតអនុញ្ញាតសាងសង់ណាមួយ អាចចេញអោយបានទេ បើលិខិតអនុញ្ញាតសាងសង់នោះពុំគោរពតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី (ក្នុងករណីដែលមានប្លង់ទាំងពីរនេះ) ឬ ប្រសិនបើពុំមានប្លង់ទាំងពីរនេះទេ នោះការអនុញ្ញាត ត្រូវអនុវត្តតាមបទបញ្ញាទូទៅស្តីពីការប្រើប្រាស់ដីធ្លីវិញ ។

ជនទាំងឡាយរួចជា នីតិបុគ្គល សាធារណៈ ឬ ឯកជន ត្រូវគោរពវិធានការនេះជាចាំបាច់ ។

មាត្រា ៨ : សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ចំពោះក្រុងភ្នំពេញ និង ទីក្រុងដទៃទៀត ត្រូវដាក់នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និង សំណង់) ហើយ ចំពោះខេត្ត ត្រូវដាក់នៅសាលាស្រុក ឬ សាលាខេត្ត (មន្ទីរសំណង់) ។ បង្កាន់ដៃទទួលពាក្យសុំលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានចេញអោយអ្នកសុំ កាលណាសំណុំលិខិតពាក្យសុំមានគ្រប់គ្រាន់ហើយ ។

មាត្រា ៩ : **បណ្តាឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់**

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើលើគំរូលិខិតជាផ្លូវការ ហើយត្រូវមានភ្ជាប់សំណុំលិខិត ដែលមានយ៉ាងតិចបំផុតនូវបណ្តាប្លង់ដូចបញ្ជាក់ខាងក្រោមនេះ ជា១០ច្បាប់ បត់ទំហំ (២១×២៩,៧ស.ម) :

៩.១ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ អចលនវត្ថុ ឬលិខិតកាន់កាប់ដីជាបណ្តោះអាសន្ន ។

៩.២ សលាកប័ត្រដីឡូតិ៍ :

ប្លង់ដីនេះធ្វើឡើងដោយភ្នាក់ងារមន្ទីរសុរិយោដី ឬ ដោយវេខាគណិតឯកជន ។ ប្លង់នេះ ត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយអ្នកធ្វើ និង អនុម័តដោយមន្ទីរសុរិយោដី ។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

- ទីតាំងនៃដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ ទីតាំងនៃដីឡូតិ៍ដែលនៅជាប់ផ្លូវចូលទៅដីឡូតិ៍នោះ ហើយនិងលក្ខណៈរបស់ផ្លូវនោះ (សាធារណៈ ឬ ឯកជន ឈ្មោះម្ចាស់កម្មសិទ្ធិ) ។
- ឈ្មោះ ឬ លេខ ផ្លូវធំ និង ផ្លូវតូច

- ផ្ទៃក្រឡាដីឡូត៍
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ ( ទីតាំង និង កំពស់ )
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ជាប់គ្នា ផ្ទៃបាត និងកំពស់របស់វា
- មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស
- ចំណុចនីវ៉ូសំរាប់ជាគោលសំគាល់កំពស់ ដែលបោះនៅលើដីឡូត៍
- បន្ទាត់ជួរតម្រង់ផ្លូវសាធារណៈ

៩.៣ ប្លង់ទីតាំងអគារក្នុងដីឡូត៍ :

មាត្រដ្ឋាន ១:២០០(ឬ ១:៥០០ ក្រោយទទួលការយល់ព្រមពីបណ្តាមន្ទីរទទួលបន្ទុកដីឡូត៍ធំ ៗ )។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

- ការបោះទីតាំងនៃសំណង់ក្នុងដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ ដោយមានការបញ្ជាក់អំពីចម្ងាយ រវាងអគារមួយឬច្រើន និង ព្រំប្រទល់ដីឡូត៍ ហើយនិងចំងាយទៅបណ្តាអគារនៅជិតខាងដែលមានស្រាប់ ។

- រាល់ការរៀបចំផ្នែកផ្សេងៗ នៃដីទំនេរ ដោយបញ្ជាក់ប្រភេទដីនិងដំណាំមានស្រាប់ និង ទៅអនាគត បណ្តាកន្លែងចតរថយន្ត និងរបង (កំពស់ និង ទីតាំង) ។

- បំពង់លូក្រៅអគារ (រូបធាតុ វិជ្ជមាត្រ ចំណោត កំរិតកំពស់ រណ្តៅពិនិត្យ) រហូតដល់ កន្លែងតភ្ជាប់ទៅបណ្តាញសាធារណៈ សំរាប់បង្ហូរទឹកស្អុយ និងសំរាប់ទឹកស្អាត អាងបង្គន់អនាម័យ អណ្តូង។

- ចំណុចនីវ៉ូនៃកំពស់ដីឡូត៍ ក្រោយការងាររៀបចំហើយ ។

៩.៤ ប្លង់អគារគ្រប់ជាន់ : មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់នេះមានបញ្ជាក់ពី :

- គោលដៅប្រើប្រាស់រាល់បន្ទប់ និង ផ្ទៃក្រឡារបស់វា
- បណ្តាបរិភោគអនាម័យ និង កន្លែងដាក់បំពង់លូ
- ចំពោះការរៀបចំទីតាំងឧស្សាហកម្ម : របៀបរៀបចំទីតាំងគ្រឿងយន្ត

៩.៥ ប្លង់ផ្នែកបណ្តាញក្រោមដីនានា និង អាងបង្គន់អនាម័យ មាត្រដ្ឋាន ១ : ១០០

៩.៦ ប្លង់មុខភាពនៃអគារ : ( Façades ) មាត្រដ្ឋាន ១ : ១០០

នៅលើបណ្តាប្លង់មុខភាពមានបង្ហាញអំពី :

- កំរិតកំពស់កំរាលនីមួយៗ កំរិតកំពស់ដីនៅជើងអគារ ដោយបញ្ជាក់កំរិតកំពស់ដីធម្មជាតិ ដីចាក់បំពេញ ឬ ដីចូកចេញ ។

- កំរិតកំពស់ដំបូល និង ព្រំដំបូល ឬ កំរិតកំពស់នៅពេលសង់ហើយនៃដំបូលតែរ៉ាស់ និង ក្បាំងក្បាលជញ្ជាំង ។

- កំរិតកំពស់សង់ហើយនៃទ្រើងផ្កា

- រូបធាតុសំរាប់មុខភាព (Matériaux de façade)

៩.៧ ប្លង់ពុះពីរយ៉ាងតិច : មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់ពុះមានការបង្ហាញដូចប្លង់មុខភាព ពុះមួយបង្ហាញរាងបង្គន់អនាម័យ ។

៩.៨ តារាងផ្ទៃក្រឡាមួយសំរាប់ជាន់នីមួយៗ

៩.៩ សលាកប័ត្រគណនាផ្ទៃបាតផ្ទាល់ដី និង សន្ទស្សន៍នៃការប្រើប្រាស់ ។

ចំពោះបណ្តាការផ្លាស់ប្តូរទ្រង់ទ្រាយ ពង្រីកទំហំ ពង្រីកតឡើងលើ ប្លង់ត្រូវបង្ហាញរបៀបខុសពីគ្នាចំពោះផ្នែកមានពីមុន ការរុះរើ និង សភាពគ្រោងធ្វើ ។

សាលាក្រុង និង សាលាខេត្តនីមួយៗ ត្រូវចេញសារាចរបញ្ជាក់អំពីខ្លឹមសារចាំបាច់ និង ឯកសារបន្ថែមពាក់ព័ន្ធនឹងសំណុំលិខិតអនុញ្ញាតសាងសង់ ។

អាចអោយអ្នកសុំសាងសង់ផ្តល់បណ្តាលិខិតស្នាមបន្ថែម ដោយមូលហេតុផ្នែកធារាសាស្ត្រ ផ្នែកការពារប្រឆាំងចោរគ្រប់ប្រភេទ ផ្នែកសណ្តាប់ធ្នាប់សាធារណៈ ការពារបេតិកភ័ណ្ឌ និង ទេសភាព ។

៩.១០ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ហើយ ត្រូវមានប្លង់លំអិតគ្រឿងផ្គុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារណការ និង ដឹកជញ្ជូនមុនបើកការដ្ឋានសាងសង់ ។

មាត្រា ១០ : ភាសាផ្លូវការ

សំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់ ត្រូវជាភាសាខ្មែរ ។ អត្ថបទជាភាសាអង់គ្លេស ឬ បារាំងអាចផ្តល់ភ្ជាប់ជាមួយនឹងលិខិតនេះ ។

មាត្រា ១១ : អត្តលេខាលើពាក្យសុំ

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងបណ្តាប្លង់ ត្រូវចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគំរោង ។

កាលណាអ្នកសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកសុំដែលបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ក៏ត្រូវចុះហត្ថលេខាលើសំណុំលិខិតពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ដែរ ។

អ្នកធ្វើគំរោងត្រូវតែជាស្ថាបត្យករខ្មែរ ឬបុគ្គលមានការរួមចំណែកជាមួយស្ថាបត្យករខ្មែរ ហើយដែលត្រូវបានទទួលស្គាល់ពីរាជរដ្ឋាភិបាល ស្នើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយគណៈស្ថាបត្យករ បន្ទាប់ពីគណៈស្ថាបត្យករខ្មែរនេះ ត្រូវបានបង្កើតឡើង ។

ក្នុងករណីដែលសំណង់មានទំហំលើសពី ៥០០ ម៉ែត្រទ្វេគុណ គំរោងអាចធ្វើបានដោយស្ថាបត្យករតែប៉ុណ្ណោះ ។

មាត្រា ១២ : ការផ្សព្វផ្សាយលិខិតអនុញ្ញាតសាងសង់ និង អង្កេតសាធារណៈ

អាជ្ញាធរមានសមត្ថកិច្ចផ្សព្វផ្សាយដំណឹងដល់សាធារណជន អំពីការដាក់ពាក្យសុំដោយបិទប្រកាសផ្សាយនៅសាលាខណ្ឌ ស្រុក ខេត្ត និងនៅកន្លែង សាងសង់ គម្រោង ។

កាលបរិច្ឆេទជាផ្លូវការនៃការដាក់ពាក្យស្នើសុំ ត្រូវចារក្នុងសំណុំលិខិត ហើយជូនដំណឹងដល់អ្នកស្នើសុំ ។

ម៉្យាងទៀតចំពោះអគារ និង បណ្ដាការ្យធំៗ ឬ ដែលមានប្រភេទអាចធ្វើអោយរំខានដល់សុវត្ថិភាព សុខមាលភាពសាធារណៈនោះ ត្រូវផ្សព្វផ្សាយដល់សាធារណៈជន ពីការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដោយវិធីណាមួយផ្សេងទៀត ដែលគេយល់ឃើញថាមានប្រសិទ្ធិភាពជាង ដោយផ្អែកលើមធ្យោបាយផ្សាយពត៌មាន នៅតាមមូលដ្ឋាន ។

ប្រកាសមួយរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ កំណត់បញ្ជីអគារ និង ការ្យដែលពាក់ព័ន្ធ ។

រាល់បុគ្គលពាក់ព័ន្ធអាចសាកសួរសុំមើលសំណុំលិខិត នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និង សំណង់ ) ចំពោះក្រុងភ្នំពេញ និងសាលាស្រុក ឬសាលាខេត្ត (មន្ទីរសំណង់) ចំពោះខេត្ត ក្នុងរយៈពេល ២៥ ថ្ងៃ និងអាចធ្វើការតវ៉ា ឬ ទាមទារទៅអាជ្ញាធរមានសមត្ថកិច្ច ។

បណ្ដឹងតវ៉ាទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងសំណុំលិខិតពាក្យសុំ ។

អាជ្ញាធរមូលដ្ឋានពិនិត្យមើលការជំទាស់ ដែលទទួលបានក្នុងពេលអង្កេត និង ធ្វើរបាយការណ៍មួយជូនទៅសាលាខេត្ត សាលាក្រុង ក្នុងរយៈពេល ៥ ថ្ងៃ ។ សាលាខេត្ត សាលាក្រុង ឬ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) គណៈកម្មការនេះត្រូវសំរេចអំពីសុពលភាពនៃបណ្ដឹងតវ៉ា ។

## មាត្រា ១៣ : អង្កេតនៅតាមបណ្ដាមន្ទីរមានសមត្ថកិច្ច

គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ក្នុងករណីផ្សេងទៀត មន្ទីររៀបចំក្រុង និង សំណង់ នៃបណ្ដាខេត្ត-ក្រុង ប្រមូលយោបល់ពីមន្ទីរមានសមត្ថកិច្ច ហើយធ្វើសំយោគមួយ ។

យោបល់ និង សំយោគទាំងនោះជាលាយល័ក្ខអក្សរ ត្រូវដាក់ជូនអភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងពិនិត្យ និង សំរេច ។

បណ្ដាមន្ទីរដែលត្រូវចូលរួមពិភាក្សាជាចាំបាច់ ក្នុងពេលពុំទាន់មានគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់រួមមាន :-

- មន្ទីរសុរិយោដី
- មន្ទីររៀបចំក្រុង និង សំណង់
- មន្ទីរសាធារណការ
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
- មន្ទីរហិរញ្ញវត្ថុ
- មន្ទីរបរិស្ថាន
- និងតំណាងស្ថាប័នពាក់ព័ន្ធ

## មាត្រា ១៤ : រយៈពេលពិនិត្យសំណុំលិខិត

រយៈពេលសំរាប់ពិនិត្យសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ត្រឹម ៤៥ ថ្ងៃធ្វើការ ។ រយៈពេលនេះគិតចាប់ពីថ្ងៃ ដែលរាល់លិខិតស្នាមភ្ជាប់ជាមួយនឹងពាក្យសុំលិខិត អនុញ្ញាតសាងសង់បានបំពេញ

សព្វគ្រប់ ។ នៅមុនរយៈពេលកំណត់នេះ អ្នកស្នើសុំត្រូវបានទទួលដំណឹងអំពីសេចក្តីសម្រេច ជាលាយលក្ខណ៍អក្សរ ស្តីពីការអនុញ្ញាត ឬ ការមិនអនុញ្ញាត ឬមួយការអនុញ្ញាតដែរ តែស្នើសុំអោយកែសំរួលបន្ថែម ។

ក្នុងករណីគ្មានចម្លើយណាមួយពីអាជ្ញាធរ នោះត្រូវចាត់ទុកបានចម្លើយជាវិជ្ជមាន ។

កាលបរិច្ឆេទថ្ងៃទី ០១ នេះ ត្រូវបានកំណត់ដោយគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ដោយមន្ទីររៀបចំក្រុង និង សំណង់ក្នុងករណីផ្សេងទៀត ។

បើអាជ្ញាធរមានសមត្ថកិច្ច បានស្នើដល់អ្នកសុំអោយធ្វើការកែប្រែតម្រូវនោះ រយៈពេល ៤៥ ថ្ងៃធ្វើការថ្មីមួយទៀត នឹងត្រូវគិតចាប់ពីថ្ងៃដាក់ពាក្យសុំមានការកែតម្រូវជាផ្លូវការ ។

ការបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ និងការស្នើសុំអោយកែសំរួល ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកសុំ ដោយអាជ្ញាធរមានសមត្ថកិច្ច ។

## ជំពូក ៤

## ទម្រង់បែបបទបន្ទាប់ពីបានលិខិតអនុញ្ញាតសាងសង់

**មាត្រា ១៥ : ការប្រគល់លិខិតអនុញ្ញាតសាងសង់**

លិខិតអនុញ្ញាតសាងសង់ ត្រូវប្រគល់អោយអ្នកសុំដោយអាជ្ញាធរដែលបានអនុញ្ញាតអោយ ។

លិខិតអនុញ្ញាតសាងសង់មួយច្បាប់ អមដោយសំណុំលិខិតគ្រប់សព្វ (ប្លង់ លិខិតស្នាមជាឧបសម្ព័ន្ធ ជាដើម...) ត្រូវរក្សាទុកជាឯកសារដាច់ខាត ដោយសាលាខេត្ត ឬ សាលាក្រុង ។

ក្នុងករណីដែលលិខិតអនុញ្ញាតសាងសង់ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល នោះគណៈកម្មាធិការជាតិរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ត្រូវរក្សាទុកជាឯកសារ ១ ច្បាប់ផងដែរ ។

**មាត្រា ១៦ : លិខិតអនុញ្ញាតសាងសង់ផុតកំណត់កាល និង ការងារបោះបង់ចោល**

១៦.១ លិខិតអនុញ្ញាតសាងសង់អស់សុពលភាព បើការងារពុំដំណើរការក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតសាងសង់ ។

លិខិតនេះ អាចអនុញ្ញាតពន្យារពេលបានមួយដង ។

សំណង់ដែលត្រូវចាត់ទុកថាបានចាប់ផ្តើមសាងសង់ កាលណាជើងគ្រឹះត្រូវបានធ្វើហើយ ។

ចំពោះការសាងសង់បន្ថែមជាន់ ត្រូវចាត់ទុកថាបានចាប់ផ្តើម កាលណាសសរទីមួយត្រូវបានធ្វើហើយ។

១៦.២ កាលណាការងារសាងសង់ ត្រូវបានផ្អាកលើសពីមួយឆ្នាំ អាជ្ញាធរក្រុង ឬ ខេត្ត អាចបង្ខំអោយធ្វើបញ្ចប់ ឬបង្ខំអោយរុះរើសំណង់ដែលបានចាប់ផ្តើម និងអោយរៀបចំទីកន្លែងអោយបានត្រឹមត្រូវដូចដើមវិញ ក្នុងរយៈពេលមួយដែលបានកំណត់ និងដោយសោហ៊ុយរបស់ម្ចាស់លិខិតអនុញ្ញាតសាងសង់ ។

**មាត្រា ១៧ : ការចាប់ដំណើរការការដ្ឋាន**

ការដ្ឋាន ពុំត្រូវចាប់ដំណើរការមុនពេលបានទទួលលិខិតអនុញ្ញាតសាងសង់ និងមុនពេលទទួលបានការអនុម័ត លើប្លង់លំអិតគ្រឿងផ្គុំសំណង់ឡើយ ។

រាល់សហគ្រិនទទួលបន្ទុកស្ថាបនាសំណង់ ត្រូវបញ្ជាក់អោយដឹងច្បាស់ថា លិខិតអនុញ្ញាតសាងសង់ត្រូវបានអនុញ្ញាតរួចហើយ ពីព្រោះជាប់ទទួលខុសត្រូវរួមជាមួយម្ចាស់សំណង់ ។

អ្នកកាន់លិខិតអនុញ្ញាតសាងសង់ ត្រូវតំកល់ទុកនៅការដ្ឋាន នូវសេចក្តីចម្លងឯកសាររដ្ឋបាលពីការចេញលិខិតអនុញ្ញាតសាងសង់មួយច្បាប់ សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

ប្លង់អនុវត្តការសាងសង់ និង ប្លង់លំអិតសំណង់មួយច្បាប់ ត្រូវតំកល់ទុកជាប្រចាំនៅការដ្ឋាន សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

**មាត្រា ១៨ : ដំណើរការទៅមុខនៃការងារ**

១៨.១ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ និង ប្លង់លំអិតគ្រឿងផ្គុំសំណង់ ហើយម្ចាស់សំណង់ត្រូវជូនដំណឹងទៅសាលាស្រុក-ខ័ណ្ឌ និង ចុះទិដ្ឋាការនៅមន្ទីរមានសមត្ថកិច្ច ។

មុនចាប់ដំណើរការការដ្ឋាន ម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋាន ពីមន្ទីររៀបចំក្រុង និងសំណង់ ឬការិយាល័យខេត្ត-ក្រុង ។

ស្ថាប័នសមត្ថកិច្ចបច្ចេកទេស ត្រូវតាមដានការអនុវត្តជាជំហាន ៗដូចតទៅ :

- ក្រោយការបោះបង្គោលកំណត់ទីតាំងសំណង់
- ក្រោយការងារផ្នែកគ្រឹះ និងមុនការធ្វើកម្រាលក្រោមនៃជាន់ផ្ទាល់ដី
- នៅទីបញ្ចប់នៃការងារធំៗ (គ្រឹះ-សសរ-ជញ្ជាំង-កម្រាល...) ផ្នែកសំខាន់ៗ នៃសំណង់
- នៅពេលតភ្ជាប់ទៅបណ្តាញលូទឹកស្អុយ ទឹកស្អាត និង បណ្តាញអគ្គីសនី

១៨.២ រាល់ការផ្លាស់ប្តូរម្ចាស់សំណង់ ក្នុងពេលកំពុងដំណើរការសាងសង់ ត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ១៩ : ការរៀបចំការដ្ឋានសំណង់**

ការដាក់គរសំភារៈសំណង់លើផ្លូវសាធារណៈត្រូវហាមឃាត់ :

- កាលណាសំណង់ ត្រូវការកន្លែងតាំងការដ្ឋានលយទៅលើផ្លូវសាធារណៈ កន្លែងលយនោះត្រូវកំណត់ត្រឹម ២ម ទៅលើចិញ្ចើមផ្លូវ ។ កន្លែងនោះត្រូវធ្វើរបងហ៊ុំព័ទ្ធ ក្នុងរយៈពេលដំណើការរបស់ការដ្ឋាន ។

- រាល់កន្លែងតាំងការដ្ឋាន ត្រូវរុះរើចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការដ្ឋាន។

- ជំនរសំភារៈ កាកសំណល់បានមកពីការរុះរើ ឬពីការសាងសង់ ឬការផ្លាស់ប្តូរត្រូវយកចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការងារ ។

ក្រោយពីពុំបានរើយកសំភារៈកាកសំណល់ចេញពីកន្លែងតាំងការដ្ឋានទេ សាលាខ័ណ្ឌ ឬ សាលាស្រុកមានភារកិច្ច ចាត់ចែងដឹកជញ្ជូនចេញដោយស្វ័យប្រវត្តិ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

**មាត្រា ២០ : ការត្រួតពិនិត្យ និង ការបញ្ចប់ការងារ**

អាជ្ញាធរក្រុង ឬ ខេត្ត អាចចូលមើលនិងត្រួតពិនិត្យការដ្ឋានគ្រប់ពេលវេលា ហើយនិងពិនិត្យប្លង់ដែលបានអនុម័តរួច ។ បើពិនិត្យឃើញភាពមិនត្រឹមត្រូវ អាជ្ញាធរនោះជំរាបជាលាយល័ក្ខណ៍អក្សរទៅម្ចាស់សំណង់ អោយកែតម្រូវក្នុងរយៈពេលកំណត់មួយ ។

ក្នុងករណីពុំបានអនុវត្ត ឬ បានអនុវត្តពុំត្រឹមត្រូវតាមបញ្ជា ការផ្អាកការងារត្រូវចេញបញ្ជាជាបន្ទាន់ ដោយអាជ្ញាធរ ក្រុង ឬ ខេត្ត ។

សាលាក្រុង ឬ សាលាខេត្ត អាចប្តឹងទៅតុលាការមានសមត្ថកិច្ចអោយចេញដីការកិច្ចការប្រញាប់ អោយផ្អាកការសាងសង់ ឬ ផ្លាស់ប្តូរទ្រង់ទ្រាយសំណង់ដែលពុំត្រឹមត្រូវ ឬផ្ទុយនឹងច្បាប់នោះ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

អនុលោមទៅតាមសភាពធ្ងន់ធ្ងរនៃការខុសឆ្គង បណ្តាសំភារៈនិងទព្វសំភារៈរបស់ការដ្ឋាន អាចត្រូវរឹបអូសតាមបង្គាប់តុលាការ ។

**មាត្រា ២១ : វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ**

អ្នកសុំលិខិតអនុញ្ញាតសាងសង់ ត្រូវប្រកាសប្រាប់អំពីការចប់ការងារ ដល់សាលាខ័ណ្ឌ ឬសាលាស្រុក។

ពេលបញ្ចប់ការដ្ឋាន សាលាខ័ណ្ឌ ឬសាលាស្រុកជាមួយនិងការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (បន្ទីរ រៀបចំក្រុង និង សំណង់) អាចត្រួតពិនិត្យភាពត្រឹមត្រូវស្របគ្នា រវាងសំណង់ដែលធ្វើរួចហើយ និង លិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ត្រូវចាត់ទុកថាពុំត្រឹមត្រូវ បើផ្ទៃបាតសំណង់ ឬ ផ្ទៃក្រឡាកម្រាលបានសាងសង់ លើសពីកំរិតអនុញ្ញាត។

អាចចាត់ទុកថាពុំត្រឹមត្រូវ បើទិដ្ឋភាពនៃអគារមានភាពងាយឃើញខុសគ្នា ពីលិខិតអនុញ្ញាតសាងសង់ ដែលបានចេញអោយ ។

ក្នុងករណីពុំត្រឹមត្រូវទេ អាជ្ញាធរក្រុង ឬ ខេត្តអាចបង្ខំម្ចាស់សំណង់ អោយកែតម្រូវអគារអោយបាន ត្រឹមត្រូវ ស្របគ្នានឹងលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ក្នុងករណីមិនគោរពតាមទេ សាលាក្រុង ឬសាលាខេត្ត ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច អោយចេញសាលក្រម ឬ សាលដីកា ។

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវមួយ ដែលចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្ត ត្រូវតែមានជាចាំបាច់ជានិច្ច ចំពោះបណ្តាអគារសំរាប់ទទួលសាធារណៈជន សណ្ឋាគារ ការិយាល័យ ក៏ដូចជាចំពោះបណ្តាកន្លែងធ្វើការរបស់អ្នកមានបៀវត្ស ។ វិញ្ញាបនប័ត្រនេះ ត្រូវបានទទួលមុនការបើកប្រើប្រាស់កន្លែងធ្វើការនោះ ។

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវមួយ ចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្ត ត្រូវតែមានជាចាំបាច់ខានពុំបាន មុនពេលបើកអោយប្រើប្រាស់ ចំពោះបណ្តាអគារដែលសាងសង់នៅក្នុងរមណីយដ្ឋាន និងទេសភាពធម្មជាតិ ឬ ក្រុង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ បុរាណសាស្ត្រ បេតិកភ័ណ្ឌ ឬនៅកន្លែងមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រណាមួយ ។

## ជំពូក ៥
## លិខិតអនុញ្ញាតរុះរើ

មាត្រា ២២ : រាល់ម្ចាស់កម្មសិទ្ធិ ឬ អ្នកទទួលសិទ្ធិតំណាងក្នុងអាណត្តិ ដែលមានបំណងរុះរើអគារណាមួយដែលមានស្រាប់ ក្រៅពីសំណង់បណ្តោះអាសន្នមិនបិតបេរ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតរុះរើ នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ។

សំណុំពាក្យសុំលិខិតអនុញ្ញាតរុះរើត្រូវមាន :

ប្លង់ដីឡូតិ៍ និង ប្លង់អគារ រូបថតអគារ ឬឯកសារផ្សេង ៗ ទៀតដែលចាំបាច់ ។

ចំពោះរាល់អគារដែលមានចុះក្នុងបញ្ជីបេតិកភ័ណ្ឌ ពាក្យសុំអនុញ្ញាតរុះរើ ត្រូវឆ្លងតាមគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ហើយត្រូវបានអនុញ្ញាតដោយអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ។

លិខិតអនុញ្ញាតរុះរើ ត្រូវផ្សព្វផ្សាយភ្លាមជាសាធារណៈ ដោយការបិតប្រកាសនៅកន្លែងដែលអាចមើលឃើញពីផ្លូវសាធារណៈ នៅកន្លែងគ្រោងធ្វើការរុះរើ ។ ការងាររុះរើ ពុំអាចចាប់ផ្តើមក្នុងរយៈពេលតិចជាង ១៥ ថ្ងៃ បន្ទាប់ពីការចេញលិខិតអនុញ្ញាតឡើយ ។

លិខិតអនុញ្ញាតរុះរើ ត្រូវចាត់ទុកយល់ព្រម បើពុំមានចំឡើយណាមួយក្រោយពីថ្ងៃដាក់ពាក្យសុំ ៣ខែ ។

រាល់ជំទាស់ ត្រូវផ្តល់ដំណឹងទៅអ្នកសុំជាលាយល័ក្ខណ៍អក្សរ ។

មាត្រា ២៣ : បណ្តាបទបញ្ញត្តិពីសមត្ថកិច្ច និង ការពិនិត្យពាក្យសុំដែលអនុវត្តចំពោះលិខិតអនុញ្ញាតសាងសង់ត្រូវអនុវត្តបានដូចគ្នាចំពោះពាក្យសុំលិខិតអនុញ្ញាតរុះរើ ។

## ជំពូក ៦
## បទល្មើស និង បណ្តឹងតវ៉ា

មាត្រា ២៤ : **ករណីបទល្មើស**

រាល់សំណង់ ដែលបានចាប់ផ្តើមដំណើរមុនចេញលិខិតអនុញ្ញាតសាងសង់ ដោយអាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់ទុកជាល្មើសច្បាប់ ។ ការដ្ឋានត្រូវបញ្ឈប់ជាបន្ទាន់ ។

ស

បណ្តាបុគ្គល ដែលបានប្រព្រឹត្តល្មើសនឹងបញ្ជារបស់មន្ត្រី និង ភ្នាក់ងាររបស់រាជការ ត្រូវជាប់ចោទ ហើយឧបករណ៍ទាំងឡាយនៅក្នុងការដ្ឋានត្រូវរឹបអូស ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាបទលហុ ។ បើពុំព្រមបញ្ឈប់ការងារ ត្រូវបញ្ជូនជនល្មើសទៅតុលាការ ដែលត្រូវវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

មាត្រា ២៥ : **បណ្តឹងតវ៉ា**

រាល់សេចក្តីសំរេចទាក់ទងនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់ មុនឡើងទៅតុលាការមានសមត្ថកិច្ច អាចជាកម្មវត្ថុនៃបណ្តឹងតវ៉ា ទៅអាជ្ញាធរមានសមត្ថកិច្ច ដូចបានបញ្ជាក់ក្នុងមាត្រា ៤ និង ៥ នៃអនុក្រឹត្យនេះ ដើម្បីធ្វើការពិនិត្យលើបណ្តឹងតវ៉ានេះ ។

អាជ្ញាធរមានសមត្ថកិច្ច មាននីតិសម្បទាសំរបសំរួលជាមួយម្ចាស់បណ្តឹង ។ ក្នុងករណីមិនបានសំរេច អ្នកប្តឹងអាចតវ៉ា ទៅដល់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ បើអាជ្ញាធរមានសមត្ថកិច្ចជាអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬនឹងទៅដល់នាយករដ្ឋមន្ត្រី បើអាជ្ញាធរមានសមត្ថកិច្ច ជា តំណាងរាជរដ្ឋាភិបាល ។

សំរាប់កិច្ចការនេះ ត្រូវបានបង្កើតផ្នែកវិវាទមួយនៅគ្រប់សាលាខេត្ត ឬសាលាក្រុង និងក្នុងគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

# ជំពូកទី ២

# **បទបញ្ជាទូទៅនៃការប្រើប្រាស់ដី-ធ្លី**

មាត្រា ២៦ : បទបញ្ជាទូទៅនៃការប្រើប្រាស់ដី-ធ្លីនេះ ត្រូវយកមកអនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយតំរូវអោយរាល់បុគ្គលសាធារណៈ និង ឯកជន ជារូបវន្តបុគ្គលក្តី ឬ នីតិបុគ្គលក្តី គោរពប្រតិបត្តិតាមលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលដែលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី និង ប្លង់គោលនៅឡើយនោះ ។

## ផ្នែក ១

## ប្រភេទ ការកំណត់ទីតាំង និង ផ្លូវចាក់ព័ន្ធចូលដល់ទីតាំងសំណង់

មាត្រា ២៧ : **សុវត្ថិភាព និង សុខមាលភាពសាធារណៈ**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះសំណង់ទាំងឡាយណាដែលទីតាំង ប្រភេទ ឬ ទំហំ មានលក្ខណៈនាំអោយប៉ះពាល់ដល់សុខមាលភាព ឬ ដល់សុវត្ថិភាពសាធារណៈ នាំអោយរំខាន ឬ បណ្តាលអោយមានមហន្តរាយ ។

២៧.១ ទីដីគ្រោះថ្នាក់ ( ទីដីដែលអាចមានគ្រោះថ្នាក់ )

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះទីដីដែលអាចមានមហន្តរាយ : តំបន់ជាក់ស្រុតឈើ តំបន់ដីសើមដែលត្រូវការពារ តាមមាត់ច្រាំង ទន្លេ ព្រែក ស្ទឹង បឹងបួរ ដែលពុំមានភាពរឹងមាំគ្រប់គ្រាន់

ហើយអាចបណ្តាលអោយមានគ្រោះថ្នាក់ ចំពោះសុវត្ថិភាពរបស់មនុស្ស និងសម្បត្តិទ្រព្យ លើកលែងតែភូមិដ្ឋានទាំងនោះបានអនុម័តតាមប្លង់គោល ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីអាចលិចទឹក កាលណាសំណង់នោះស្ថិតតាមមាត់ច្រាំងទន្លេ លើព្រែក ស្ទឹង ឬបឹង បណ្តាលអោយថយចុះលទ្ធភាពរក្សាទឹកទុក ឬ លទ្ធភាពបង្ហូរទឹកពីទីដីនោះ និង ទីដីជិតខាង និងប៉ះពាល់ដល់គុណភាពទឹក ។

២៧.២ ធាតុរំខានដោយសម្លេង

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ឬអាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស បើសំណង់នោះអាចត្រូវទទួលរងធាតុរំខានដោយសំលេងខ្លាំង ។ ឬ បើសំណង់នោះអាចបង្កធាតុរំខានដោយសំលេងខ្លាំង ។ ។

<u>មាត្រា ២៨</u> : **ការការពាររមណីយដ្ឋាន**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះមានប្រភេទ ទំហំ ឬ ទីតាំងអាចបណ្តាលអោយអន្តរាយដល់ការអភិរក្ស ឬ អន្តរាយដល់ការលើកតំលៃនៃរមណីដ្ឋានធម្មជាតិ ឬក្រុង ឬ កេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ និងបូរាណវត្ថុ ឬ អាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស ។

<u>មាត្រា ២៩</u> : **បណ្តាញផ្លូវតាក់ព័ន្ធ និង ចំណត**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីដែលពុំមានផ្លូវចេញ-ចូល ដូចជា : ផ្លូវសាធារណៈ ផ្លូវឯកជន ច្រកផ្លូវ ឬ ផ្លូវឆ្លងកាត់ ដែលទទឹងត្រូវសមាមាត្រសមស្របទៅនឹងទំហំ និងការប្រើប្រាស់នៃអគារ ។

រាល់ផ្លូវ ផ្លូវឆ្លងកាត់ ច្រកផ្លូវ សំរាប់ប្រើប្រាស់ចំពោះសំណង់មួយ ឬ ច្រើន ពុំអាចមានទទឹងតិចជាង ៣,៥០ម ដែលជាទំហំចាំបាច់សំរាប់អោយរថយន្តពន្លត់អគ្គីភ័យចូលបាន ។

ចំណតរថយន្ត ត្រូវមានគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់អគារ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ។

បទដ្ឋានចំណតរថយន្តត្រូវបានកំណត់ដោយបណ្តាសាលាក្រុង និងសាលាខេត្ត ប៉ុន្តែពុំអាចតិចជាង :

- ចំពោះសណ្ឋាគារ :

. ចំណតរថយន្តតូច ១កន្លែង សំរាប់ ៥ បន្ទប់

. ចំណតរថយន្តធំ ១កន្លែង សំរាប់ ៣០ បន្ទប់

- ចំពោះការិយាល័យឯកជន និង រដ្ឋបាលសាធារណៈ

. ចំណតរថយន្ត ១កន្លែង សំរាប់ផ្ទៃក្រឡាកម្រាលសរុបទំហំ ២៥០ម៉ែត្រទ្រេគុណ

- ចំពោះបណ្ដាសកម្មភាព ឧស្សាហកម្ម សិប្បកម្ម និងឃ្លាំងស្ដុកទំនិញ ចំនួនចំណតរថយន្តត្រូវមាន គ្រប់គ្រាន់សំរាប់ការលើកដាក់ ផ្ទុក និង ផ្ទេរទំនិញនៅក្រៅពីផ្លូវសាធារណៈ និងចំណតរថយន្តគ្រប់ប្រភេទ នៅក្នុងបរិវេណដីឡូត៍ ។

មាត្រា ៣០: **ការបោះទីតាំងសំណង់ តាមដងផ្លូវសាធារណៈ**

៣០.១ ការបោះទីតាំងសំណង់នៅតាមដងផ្លូវជាតិ និង ផ្លូវទំនប់ព័ទ្ធជុំវិញទីក្រុង អភិបាលខេត្ត ឬ ប្រតិភូ-រាជរដ្ឋាភិបាលប្រចាំក្រុងនានា និង រាជធានីភ្នំពេញ ត្រូវកំណត់ដោយមានការយល់ព្រម ពីគណៈកម្មាធិការជាតិ រៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ នូវដីចំណីសាធារណៈ និងច្បាតម្លាតនៃផ្លូវជាតិ ផ្លូវសំខាន់ៗដែលពាក់ព័ន្ធនឹងការរៀបចំទីក្រុង និង នគរូបនីយកម្ម ជាអាទិផ្លូវទំនប់ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្ដល់ជូនឡើយ នៅក្នុងតំបន់ដែលបានរៀបរាប់ខាងលើ ។

៣០.២ ការបោះទីតាំងសំណង់ នៅតាមដងផ្លូវសាធារណៈក្នុងក្រុង

សំណង់ទាំងឡាយ ត្រូវបោះទីតាំងលើជួរតម្រង់ផ្លូវសាធារណៈ ឬឃ្លាតឆ្ងាយពីជួរតម្រង់យ៉ាងតិច ៤ម ។

នៅតាមច្រកផ្លូវ បណ្ដាសំណង់អាចបោះទីតាំងលើជួរតម្រង់ផ្លូវច្រក ។

អភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និង រាជធានីភ្នំពេញ កំណត់ជួរតម្រង់នៃផ្លូវសាធារណៈ និង ច្បាតម្លាតលើប្លង់មួយហៅថា ប្លង់ជួរតម្រង់ ។ ប្លង់ជួរតម្រង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ចំពោះក្រុងទាំងឡាយណាដែលមានប្រជាជនលើសពី ២០.០០០នាក់ ។ ប្លង់ទាំងនោះ ត្រូវផ្សព្វផ្សាយអោយសាធារណៈជនបានដឹង ។

មាត្រា ៣១ : **ការផ្គត់ផ្គង់ទឹកស្អាត និង ការបញ្ចេញចោលទឹកកខ្វក់**

៣១.១ ការផ្គត់ផ្គង់ទឹកស្អាត ត្រូវធានាអោយបានចំពោះរាល់សំណង់ ដែលតំរូវអោយមានលិខិតអនុញ្ញាតសាងសង់ ។

ក្នុងករណីដែលបណ្ដាញទឹកស្អាត ពុំផ្គត់ផ្គង់អោយទៅដល់ទីដីដែលនៅលើទីដីនោះ មានសំណង់មួយត្រូវបានគ្រោងទុកនោះ អ្នកស្នើសុំត្រូវបង្ហាញភស្តុតាងថា ខ្លួនអាចនឹងផ្គត់ផ្គង់ទឹកស្អាតក្នុងបរិមាណគ្រប់គ្រាន់ដល់អគាររបស់ខ្លួន និងបញ្ជាក់ថាតាមមធ្យោបាយអ្វី ទោះបីតាមការបន្តភ្ជាប់ទៅនឹងបណ្ដាញទឹកស្អាតណាមួយដែលនៅជិត ឬជាអណ្ដូងទឹកដែលមានស្រាប់នៅជិតនោះ ឬដែលត្រូវជីកថ្មីក្ដី ។

អ្នកស្នើសុំត្រូវបញ្ជាក់អំពីលក្ខណៈបច្ចេកទេសរបស់អណ្ដូង និងគុណភាពទឹក ។ ក្នុងករណីការប្រើប្រាស់អណ្ដូងសមូហភាព សំណុំលិខិតនៃលិខិតអនុញ្ញាតសាងសង់ ត្រូវមានសេចក្ដីយល់ព្រមឱ្យប្រើប្រាស់ទឹកជាលាយលក្ខណ៍អក្សរ ។

៣១.២ បណ្តាដីឡូត៍ ឬសំណុំលំនៅដ្ឋាន ត្រូវតែមានការផ្គត់ផ្គង់ដោយបណ្តាញចែកចាយទឹកស្អាត និងមានប្រព័ន្ធលូទឹកស្អុយ ដែលនាំបង្ហូរចេញដល់ទីដៅតែម្តង ដោយគ្មានកន្លែងណាមួយអាចអោយទឹកស្អុយដក់នៅបាន ។

៣១.៣ - ក្នុងករណីគ្មានប្រព័ន្ធលូទឹកស្អុយ ម្ចាស់សំណង់មានកាតព្វកិច្ចត្រូវគ្រោងសំអាត និងបញ្ចេញទឹកដែលប្រើប្រាស់ហើយទៅទីធម្មជាតិ តាមរយៈអាងបង្គន់អនាម័យ និងបណ្តាញបំពង់មានប្រហោងរាយកប់ក្នុងដី ។

បណ្តាញនេះបែងចែកទឹកដែលចេញពីបង្គន់អនាម័យ នៅក្រោមដីធ្វើអោយជ្រាប និង ជម្រះបាន ។

ម្ចាស់កម្មសិទ្ធនៅក្នុងក្រុង ចាំបាច់ត្រូវធ្វើអាងបង្គន់អនាម័យ ហើយបន្តភ្ជាប់ទៅប្រព័ន្ធលូ ។

បទដ្ឋានអាងបង្គន់អនាម័យ កំណត់ដូចតទៅ :

ទំហំប្រើប្រាស់នៃអាងបង្គន់អនាម័យ ដោយគិតពីបាតអាងឡើងមកដល់បំពង់បង្ហូរចេញ :

- ជាអប្បបរមា ៣ម៉ែត្រត្រីគុណសំរាប់លំនៅដ្ឋានមួយ ឬ ៣ម៉ែត្រត្រីគុណក្នុងមួយជាន់នៃផ្ទះល្វែង ឬនៃភូមិគ្រឹះ ឬ ៣ម៉ែត្រត្រីគុណសំរាប់ផ្ទៃក្រឡាកំរាលសរុបទំហំ ៨០ម៉ែត្រទ្វេគុណ ។

ចំពោះសណ្ឋាគារ ២ ម៉ែត្រត្រីគុណ បូកបន្ថែម ០,៥ម៉ែត្រត្រីគុណក្នុងមួយបន្ទប់ :

- កំពស់អាងបង្គន់អនាម័យពុំអាចទាបជាង ១,៥០ម ។

- អាងបង្គន់អនាម័យត្រូវមានរន្ធបង្ហុយបន្តខ្ពស់ទៅលើ ។

- មិនត្រូវអោយទឹកភ្លៀងហូរចូលទៅក្នុងអាងបង្គន់អនាម័យជាដាច់ខាត់ ។

៣១.៤ - សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវមានគំនូរអាងបង្គន់អនាម័យ និង ប្រព័ន្ធបន្តភ្ជាប់ទៅលូបង្ហូរទឹកស្អុយ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើពុំបង្ហាញការធានាគ្រប់គ្រាន់អំពីអនាម័យ និងសុខមាលភាពចំពោះសំណង់ដែលបានគ្រោង និងបណ្តាសំណង់នៅជុំវិញដែលមានស្រាប់ ។

**<u>មាត្រា ៣២</u> : តំបន់មិនអាចសាងសង់បាន**

ខេត្ត និង ក្រុង នីមួយៗ ត្រូវកំណត់ជាបន្ទាន់នូវប្លង់តំបន់មិនអាចសាងសង់បាន ។

ប្លង់នេះ ត្រូវមានបញ្ចូលតំបន់ការពារធម្មជាតិ តំបន់កសិកម្ម តំបន់ព្រៃឈើ និង រ៉ែ ដែលជាគោលដៅប្រើប្រាស់ពុំអាចផ្លាស់ប្តូរបានដោយមូលហេតុផលប្រយោជន៍សេដ្ឋកិច្ច និង បរិស្ថាន ។

ប្លង់នេះ ត្រូវមានបញ្ចូលរមណីយដ្ឋានធម្មជាតិ ដូចជា ឆ្នេរសមុទ្រ មាត់ទន្លេ ព្រែក ស្ទឹង បឹងបួរ ដោយមូលហេតុផលប្រយោជន៍បេតិកភ័ណ្ឌ និង បរិស្ថាន ។

ប្លង់នេះ ត្រូវមានបញ្ចូលគ្រប់តំបន់អាចលិចទឹក ដែលត្រូវការពារដោយមូលហេតុជាផលប្រយោជន៍ សំរាប់បង្ហូរទឹកភ្លៀងចេញ និង ការប្រយុទ្ធប្រឆាំងនឹងទឹកជំនន់ ។

អាជ្ញាធរតាមមូលដ្ឋានត្រូវចាត់វិធានការសមស្រប ដើម្បីការពារ និងបង្កើនគុណសម្បត្តិតំបន់មិនអាចសាងសង់បានទាំងនោះ ។

រាល់លិខិតអនុញ្ញាតសាងសង់ មិនផ្តល់ជូនឡើយក្នុងតំបន់ទាំងនោះ ។

ក្នុងករណីមានការសាងសង់ដោយល្មើសច្បាប់ ក្នុងតំបន់ហាមឃាត់ទាំងនេះ អាជ្ញាធរដែនដីត្រូវបង្ខំឱ្យជនល្មើសរុះរើដោយខ្លួនឯង ហើយធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ក្នុងរយៈកាលមួយកំណត់ ។

ក្នុងករណីមិនអនុវត្តតាមការកំណត់ អាជ្ញាធរដែនដីត្រូវធ្វើការផាកពិន័យ និង ចាត់អោយរុះរើ និងធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ដោយចាប់បង្ខំអោយអ្នកល្មើសច្បាប់ ត្រូវតែចេញសោហ៊ុយចំណាយទាំងអស់នោះ ឬ ក្នុងករណីចាំបាច់ អាជ្ញាធរមូលដ្ឋានត្រូវប្តឹងទៅតុលាការ ដើម្បីអោយចេញដីការកិច្ចការប្រញាប់បញ្ជាអោយរុះរើ ។

ប្លង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ និងត្រូវផ្សព្វផ្សាយជាសាធារណៈដល់មន្ត្រីរាជការ ផ្នែករាជ្ញាធរដែនដីមូលដ្ឋាន និងមន្ត្រីជំនាញទទួលខុសត្រូវលើ << តំបន់មិនអាចសាងសង់បាន >> ដែលពុំបានចាត់វិធានការចាំបាច់ ដើម្បីអោយមានការគោរពតំបន់ទាំងនោះទេ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ជាធរមាន ។

## មាត្រា ៣៣ : ផលប៉ះពាល់ពីសំណង់ឧស្សាហកម្ម

សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់សំណង់ឧស្សាហកម្ម ត្រូវបញ្ជាក់អំពីការបំពុលបណ្តាលមកពីសកម្មភាពឧស្សហកម្ម និងវិធីដែលបានគ្រោងទុក ដើម្បីលុបបំបាត់ការបំពុលទាំងនោះ ។

គំរោងស្ថានីយសំរាប់ធ្វើសំអាតតាមយថាប្រភេទ ត្រូវមានបញ្ចូលក្នុងសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ។

រាល់កាកសំណល់ពីឧស្សាហកម្ម ត្រូវតែបានទទួលការសំអាតជាមុន ដើម្បីបង្ការកុំអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់ ឬ សុខភាពសាធារណៈ ។ ទឹកកខ្វក់សំណល់ឧស្សាហកម្ម ពុំត្រូវឱ្យលាយឡំជាមួយទឹកភ្លៀង និងជាមួយទឹកកខ្វក់ដទៃទៀត ហើយក៏ពុំត្រូវបង្ហូរចូលត្រង់ៗទៅកន្លែងធម្មជាតិ ដោយពុំបានធ្វើការសំអាតជាមុនឡើយ ។

ចម្ងាយអប្បបរមា ដែលត្រូវគោរពរវាងសំណង់ឧស្សាហកម្មមួយដែលមានធាតុកខ្វក់ និង លំនៅដ្ឋាននៅជិតបំផុត ត្រូវបានរដ្ឋអំណាចមូលដ្ឋានអនុវត្ត ស្របទៅតាមការណែនាំផ្ទាល់របស់រាជរដ្ឋាភិបាល ។

ចំពោះឃ្លាំងស្តុកឧទស្ពារ និង អាងប្រេងឥន្ធនៈទាំងឡាយ ត្រូវគោរពបទបញ្ញត្តិអន្តរជាតិ អនុម័តដោយរាជរដ្ឋាភិបាល ។

រាល់អំពើល្មើសនឹងបណ្តាបទបញ្ញត្តិខាងលើនេះ រដ្ឋអំណាចមូលដ្ឋានអាចបញ្ជាផ្អាកសកម្មភាពជាបន្ទាន់ ហើយត្រូវរាយការណ៍ជូនស្ថាប័នជំនាញ ។ រដ្ឋអំណាច ត្រូវជូនដំណឹងតាមផ្លូវច្បាប់ដល់ម្ចាស់សំណង់ នូវបណ្តាបទបញ្ញត្តិដែលត្រូវគោរពតាម ។

# ជំពូក ២

## ការបោះទីតាំង និង ទំនាក់ទំនងនាំ

**មាត្រា ៣៤ : ការបោះទីតាំងធៀបនិងព្រំដីឡូត៍ជិតខាង**

ធៀបនឹងព្រំដីឡូត៍ សំណង់ទាំងឡាយនឹងត្រូវសាងសង់ ឬមួយនៅជាប់នឹងព្រំ ឬមួយជាជញ្ជាំងអឌ្ឍសិទ្ធិ ឬមួយនៅចម្ងាយអប្បបរមា ២ម ពីព្រំ ។ ចន្លោះ ២ម នេះ ត្រូវទុកអោយនៅទំនេរពុំមានសំណង់អ្វីឡើយ ។

ហាមមិនអោយចោះទ្វារ ឬ បង្អួច នៅលើជញ្ជាំងអឌ្ឍសិទ្ធិ ឬជញ្ជាំងជាប់ព្រំ ។

ចំពោះសំណង់ជាប់ព្រំ ឬ សំណង់ជាជញ្ជាំងអឌ្ឍសិទ្ធិ នឹងមានកំណត់ក្នុងសេចក្តីណែនាំអនុវត្ត របស់គណៈ-កម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ តាមសំណើរបស់ខេត្ត-ក្រុង ។

ត្រូវបានចាត់ទុកថាជាបន្ទប់រស់នៅ រាល់បន្ទប់ទាំងអស់លើកលែងតែផ្ទះបាយ បន្ទប់អនាម័យ បន្ទប់សេវាផ្សេងៗ និង ចន្លោះដើរក្នុងអគារ ។ បទបញ្ញត្តិនេះ ត្រូវដាក់អោយអនុវត្តផងដែរចំពោះសណ្ឋាគារ ។

ក្នុងករណីនេះ រាល់បន្ទប់ដេក ក៏ដូចជារាល់បន្ទប់ទទួលភ្ញៀវ សុទ្ធតែត្រូវចាត់ទុកថាជាបន្ទប់រស់នៅ ។

បទបញ្ញត្តិនេះ ក៏ត្រូវដាក់អោយអនុវត្តផងដែរ ចំពោះកន្លែងធ្វើការ ។ ក្នុងករណីនេះ រាល់បន្ទប់ដែលមានមុខងារជាការិយាល័យ ឬ រោងជាងប្រើប្រាស់ជាទម្លាប់ ឬជាប្រចាំថ្ងៃ ត្រូវចាត់ទុកដូចជាបន្ទប់រស់នៅដែរ លើកលែងតែបន្ទប់មិនត្រូវការជាចាំបាច់នូវពន្លឺថ្ងៃ តាមមុខងារយថាប្រភេទរបស់វា ដូចជាបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ ស្តូឌីយោភាពយន្ត ។ ល ។

សាលាក្រុង ឬ សាលាខេត្ត អាចមានសិទ្ធិអោយបិទរាល់ច្រកប្រហោងណា ដែលពុំគោរពតាមចម្ងាយដូចបានរៀបរាប់ខាងលើនេះ ។

ចំពោះអគារមានពីមុនស្រាប់ ដែលពុំគោរពតាមបទបញ្ញត្តិដូចបានរៀបរាប់ខាងលើនេះទេ សាលាក្រុង ឬ សាលាខេត្ត អាចទាមទារអោយបង្កើតរបាំងការពារ កុំអោយមានគំហើញត្រង់ទៅលើដីឡូត៍អ្នកជិតខាង ។

របាំងការពារទាំងនេះ អាចជាជញ្ជាំងមានប្រឡោះខ្យល់ ផ្ទាំងឈើ ឬអ្វីៗផ្សេងទៀត ដែលពុំរាំងខ្ទប់ដំណើរខ្យល់បក់ចេញចូលក្នុងបន្ទប់រស់នៅ ។

ចាត់ទុកជាបង្អួច រាល់ប្រហោងនានាដែលបណ្តាលអោយមានគំហើញត្រង់ ឆ្ពោះទៅលើអ្នកជិតខាង ។ ក្នុងករណីណាក៏ដោយ គេអាចប្រើប្រាស់បានរាល់របាំងធ្វើពីឈើ ឬបេតុង ស្លាបព្រិលបាក់ប៉ើក ធ្វើពីឈើ ឬ កញ្ចក់ស្រអាប់ និង ស្លាបព្រិលនៅនឹងថ្កល់ ។

**មាត្រា ៣៥ : ផ្ទៃបាត**

ចំពោះផ្ទះល្វែង និង អគារលំនៅឋានសមូហភាព ផ្ទៃបាតសំណង់ធៀបទៅនឹងផ្ទៃក្រឡារបស់ដីឡូត៍ ពុំអាចលើសពី ៧៥% ឡើយ ។

ចំពោះផ្ទះជាលំនៅឋាន ផ្ទៃបាតសំណង់នោះពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដីឡូត៍ ដែលនៅសល់ពីការសាងសង់ ត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្តាលផ្ទៃក្រឡានេះ ។

ចំពោះអគារដែលមានយ៉ាងតិច ១៥លំនៅ សណ្ឋាគារ អគារការិយាល័យ និង អគារឧស្សាហកម្ម ផ្ទៃបាតសំណង់ពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដែលនៅសល់ពីសំណង់ នឹងត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្តាលផ្ទៃក្រឡានេះ ។

សាលាក្រុង និង សាលាខេត្ត ត្រូវកំណត់តំបន់រៀបចំក្រុង ដែលត្រូវយកបទបញ្ជាខាងលើនេះមកអនុវត្ត ហើយនិងត្រូវកំណត់បទបញ្ញត្តិពិសេស ចំពោះស្ថានភាពជាក់ស្តែង ។

## មាត្រា ៣៦ : ប្លង់កំពស់

សាលាក្រុង និង សាលាខេត្តនីមួយៗ នឹងលើកគំរោងប្លង់កំពស់ក្នុងរយៈពេលមួយឆ្នាំ ក្រោយពីបានការអនុម័តលើអនុក្រឹត្យនេះរួច ដោយកំណត់អោយតំបន់នីមួយៗនៃក្រុងនូវកំពស់អតិបរិមានៃសំណង់ ។

ប្លង់កំពស់នេះត្រូវគិតដល់ :

. កំពស់មធ្យមបច្ចុប្បន្នតាមសង្កាត់នីមួយ ៗ ។

. លក្ខណៈសំខាន់នៃតំបន់ (ពាណិជ្ជកម្ម លំនៅឋាន ឧស្សាហកម្មនៅកណ្តាលក្រុង ឬជាយក្រុង ដីចាក់បំពេញ ឬរត់ ការប្រើប្រាស់ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ ។ ល ។) ។

. ប្រភេទនៃសំណង់ (ផ្ទះល្វែង ភូមិគ្រឹះ គ្រឹះស្ថាន ឃ្លាំងស្តុកទំនិញ និង អគារឧស្សាហកម្ម...។ ល ។) ។

ប្លង់កំពស់នេះ ត្រូវបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ហើយផ្សព្វផ្សាយជាសាធារណៈ ។

## មាត្រា ៣៧ : ការការពារប្រាង្គប្រាសាទ និង ទេសភាព

សាលាក្រុង និង សាលាខេត្តនីមួយ ៗ អាចកំណត់កំពស់អតិបរិមាទាបជាងកំពស់អតិបរិមាក្នុង << ប្លង់កំពស់ >> ដើម្បីការពារបូជនីយស្ថានប្រវត្តិសាស្ត្រ រមណីយដ្ឋានធម្មជាតិ ក៏ដូចជាកន្លែងនៅជិត ៗ ប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ឬ ដើម្បីរក្សាទុកនូវទស្សនវិស័យ នៃប្រាង្គប្រាសាទ និង ទស្សនវិស័យដ៏ស្អំស្អែ ។

ការបន្ថយកំពស់នេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ និង ប្រាប់ដល់អ្នកសុំលិខិតអនុញ្ញាតសាងសង់មុនពេលដាក់សំណុំលិខិតស្នើសុំ ។

## ជំពូក ៣

## ទិដ្ឋភាពនៃសំណង់

មាត្រា ៣៨ : លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់ដែលគ្រោងនោះមានទីតាំង ស្ថាបត្យកម្ម (Architecture) ទំហំ ឬ ទិដ្ឋភាពក្រៅអាចនាំអោយប៉ះពាល់ដល់លក្ខណៈ ឬ ផលប្រយោជន៍របស់ទីតាំងនៅជុំវិញ ប៉ះពាល់ដល់ទេសភាពធម្មជាតិ ឬទីក្រុង ភាពស្ងប់របស់ទីសក្ការបូជា រមណីយដ្ឋានប្រវត្តិសាស្ត្រ ឬបុរាណសាស្ត្រ រាជវាំង និង រាជព្រះប្រាសាទ ។

មាត្រា ៣៩ : លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើង បើលក្ខណៈសំណង់នោះមិនធានាសុខមាលភាព បន្ទប់ស្នាក់នៅ ឬ បន្ទប់ធ្វើការនីមួយ ៗ ត្រូវអោយមានខ្យល់ចេញ-ចូល ហើយត្រូវមានបង្អួចមួយយ៉ាងតិច ។

ផ្ទៃក្រឡាបញ្ចូលពន្លឺថ្ងៃសំរាប់បន្ទប់នីមួយ ៗ ត្រូវមានយ៉ាងតិច ១,៥០ម$^{២}$ ។

មាត្រា ៤០ : បណ្តាសំណង់ឧស្សាហកម្ម អាចតម្រូវអោយគោរពល័ក្ខខ័ណ្ឌពិសេសចំពោះការរៀបចំ ឬការបោះទីតាំង ដើម្បីធានាការបញ្ចូលឱ្យបានល្អទៅក្នុងទេសភាព និង រមណីយដ្ឋានធម្មជាតិ ឬ ទីក្រុង ។

មាត្រា ៤១ : នៅតាមឆ្នេរសមុទ្រ តាមមាត់បឹង ស្ទឹង និងទន្លេ លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះធ្វើអោយខូចនូវសោភ័ណភាពរបស់ទេសភាព និង រមណីយដ្ឋាន ដោយសារទិដ្ឋភាព ឬ កំពស់របស់សំណង់ បើមើលពីមាត់ឆ្នេរ ពីមាត់ច្រាំង ពីសមុទ្រ ស្ទឹង ទន្លេ ឬបឹងបួរ និង ប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូក ៤

## សន្ទភាព ( ដង់ស៊ីតេ ) : កំរិតស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់

មាត្រា ៤២ : ការស្ថាបនាសំណង់មួយមានសន្ទភាព លើសពីកំរិតអតិបរមាស្របច្បាប់ តម្រូវអោយអ្នកទទួលលិខិតអនុញ្ញាតសាងសង់ បង់ប្រាក់ស្មើនឹងតំលៃដីដែលចាំបាច់ ដើម្បីអោយ << សន្ទស្សន៍ប្រើប្រាស់ >> សំណង់មិនលើស ពីកំរិតនេះ ។

មាត្រា ៤៣ : << សន្ទស្សន៍ប្រើប្រាស់ >> ត្រូវបានកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសរុបជាផ្លូវការ ( Hors oeuvre nette ) នៃសំណង់នោះ និងផ្ទៃក្រឡាដីដែលសំណង់នោះនឹងត្រូវ ឬបានតាំងនៅលើ ។

កាលណាសំណង់ថ្មីមួយ បានត្រូវសាងសង់លើដីមួយកន្លែងដែលមានអគារចាស់មួយ ឬច្រើន ហើយគ្មានគម្រោងរុះរើពេលនោះទេ សន្ទភាពត្រូវគណនាដោយថែមផ្ទៃក្រឡាកម្រាលនៃសំណង់ចាស់ ទៅលើផ្ទៃក្រឡាកំរាលនៃសំណង់ថ្មី ។

<u>មាត្រា ៤៤</u> : ក៏រិតអតិបរមាស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់ ត្រូវកំណត់ដល់ (១) សំរាប់ទូទាំងដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា ។

<u>មាត្រា ៤៥</u> : ការផ្តល់លិខិតអនុញ្ញាតសាងសង់ នាំមកអោយអ្នកបានទទួលលិខិតអនុញ្ញាតសាងសង់ នូវកាតព្វកិច្ចអោយបង់ប្រាក់នោះ ។ ការបង់ប្រាក់ត្រូវធ្វើជាបីភាគស្មើគ្នា ភាគទី ១ នៅពេលបានទទួលលិខិតអនុញ្ញាតសាងសង់ ភាគទី ២ នៅពេលបើកការដ្ឋាន ភាគទី ៣ នៅពេលបញ្ចប់សំណង់ ។

<u>មាត្រា ៤៦</u> : តំលៃដីសំរាប់ការគណនាចំនួនទឹកប្រាក់ដែលត្រូវបង់ ត្រូវបានកំណត់ដោយក្រសួងហិរញ្ញវត្ថុ ។

<u>មាត្រា ៤៧</u> : ក៏រិតស្របច្បាប់នៃ << សន្ទស្សន៍ប្រើប្រាស់ >> ពុំត្រូវអនុវត្តឡើយ ចំពោះសំណង់ដែលពុំតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ ចំពោះគ្រឹះស្ថានសាធារណៈ និង ចំពោះអគាររដ្ឋបាលសាធារណៈសំរាប់បំរើផ្ទាល់មុខ ជាកន្លែងធ្វើការសំរាប់ស្ថាប័នសាធារណៈ ។

នាយករដ្ឋមន្ត្រី អាចសំរេចលើកលែងការអនុវត្តក៏រិតស្របច្បាប់នៃ << សន្ទស្សន៍ប្រើប្រាស់ >> ចំពោះបណ្តាតំបន់រៀបចំពិសេស បន្ទាប់ពីបានយោបល់ពីគណៈកម្មាធិការជាតិ រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

<< វាសនដ្ឋានសង្គម >> ទាំងឡាយអាចទទួលនូវការលើកលែងមិនអោយបង់ពន្ធអាករ តាមសេចក្តីសំរេចរបស់អភិបាលខេត្ត-ក្រុង បន្ទាប់ពីបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

## ជំពូក ៥

## បទបញ្ញាពិសេស សំរាប់អនុវត្តលើភាគខ្លះ នៃដែនដី

<u>មាត្រា ៤៨</u> : ជាការបន្ថែមដល់បទបញ្ញាទូទៅនៃការប្រើប្រាស់ដី-ធ្លី ការណែនាំមួយចំនួនសំរាប់ការរៀបចំតំបន់ និង បទបញ្ញានគរូបនីយកម្មពិសេសមួយចំនួន អាចត្រូវដាក់តែងឡើងដោយអនុក្រឹត្យដែលអាច មានរហូតដល់ការហាមមិនអោយសាងសង់នៅក្នុង << តំបន់ចាប់អារម្មណ៍ >> ដូចជា ឆ្នេរសមុទ្រ មាត់ច្រាំងទន្លេ និង បឹងធំ ៗ ។ រាល់ឯកសារ << នគរូបនីយកម្មមូលដ្ឋាន >> និង ប្លង់ខេត្តនៃ តំបន់ហាមមិនអោយមានសំណង់ ដែលចែងក្នុងមាត្រា ៣២ វគ្គទី ២ នៃអនុក្រឹត្យនេះត្រូវទុកជាការណែនាំ ទាំងនេះ និង ការហាមដាយថាហេតុមិនអោយសាងសង់ ។

<u>មាត្រា ៤៩</u> : បទបញ្ញត្តិទាំងឡាយមានពីមុនដែលផ្ទុយនឹងអនុក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥០ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និង វិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង អភិបាលខេត្ត សមាជិកគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមតួនាទីចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ ៨ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

អ៊ុង ហួត ហ៊ុន សែន

**កន្លែងទទួល :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ៥០
- ឯកសារ-កាលប្បវត្តិ

ជំរាបជូន :
ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
សម្តេចនាយករដ្ឋមន្ត្រីទី ២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ
រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់

ខណ្ឌ ម៉ូលីខណ្ឌ

---

059 សក.ចល
ថតចម្លងតាមច្បាប់ដើម
- ជូន ឯកឧត្តម រដ្ឋមន្ត្រី ស្តីទី
- - ឯកឧត្តម អគ្គលេខាធិការ
- - លេខាធិការ ជ.ឧ ឧបនាយករដ្ឋមន្ត្រី
- - ភូមិបាល នគរូបនីយកម្ម និង សំណង់

ដើម្បីជូនជ្រាបជាព័ត៌មាន
ភ្នំពេញ ថ្ងៃទី 12 ខែ មករា ឆ្នាំ 1998
រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន
[illegible]ការិយាល័យ

យី ស៊ុនចន

# ឧបសម្ព័ន្ធទី៣

# ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

# ច្បាប់ ស្ដីពី សំណង់

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

# ស្ដីពី

# សំណង់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងធានា៖

- គុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- សោភណភាពនិងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយចីរភាព សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ
- គណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបការងារនិងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់
- ការបង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

**មាត្រា២ .-**

ច្បាប់នេះមានគោលដៅកំណត់គោលការណ៍ បទប្បញ្ញត្តិបច្ចេកទេសសំណង់ វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រភេទសំណង់ដែលកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

# ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

# ជំពូកទី៣

## គោលការណ៍

**មាត្រា៦ .-**

រាល់ការងារសំណង់ត្រូវគោរពគោលការណ៍៖

- ការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល
- ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន
- រៀបចំដែនដីនិងនគរូបនីយកម្ម
- អភិវឌ្ឍបៃតង ការពារធនធានធម្មជាតិ និងបរិស្ថាន
- រក្សានិងលើកកម្ពស់អត្តសញ្ញាណជាតិ។

## ជំពូកទី៤

## បទប្បញ្ញត្តិបច្ចេកទេសសំណង់

**មាត្រា៧ .-**

រាល់ការងារសំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការត្រួតពិនិត្យអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ .-**

រាល់សំណង់ត្រូវមានគ្រឿងផ្គុំដែលអាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពគ្រឿងផ្គុំត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៩ .-**

រាល់សំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០ .-**

បទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ត្រូវដាក់ឱ្យប្រើប្រាស់ដោយអនុក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀតក្រៅពីបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដារណាមួយជាកំណត់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យ

ឧស្សាហកម្ម តាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមការសម្រេចរបស់ក្រុមប្រឹក្សាស្តង់ដាជាតិ។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដទៃទៀតដែលមិនទាន់ត្រូវបានកំណត់ជាស្តង់ដាកម្ពុជា ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដែលមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាននិងមានតំណាងក្រសួងស្ថាប័ននិងវិស័យឯកជនពាក់ព័ន្ធជាសមាជិក។

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥

## ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់

**មាត្រា១២ .-**

រូបវន្តបុគ្គលដែលអាចបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ត្រូវចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនីមួយៗនៃវិស័យសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈវិជ្ជាជីវៈនីមួយៗពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា១៣ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

ក្រមសីលធម៌សម្រាប់អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៤ .-**

ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ផ្សេងទៀតដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦

## ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់

**មាត្រា១៥ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលអាចប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យបាន ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលបំពេញមុខងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើយ។

នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

**មាត្រា១៦ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈ ក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- បានប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំទៅដល់ការផ្អាកឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានបញ្ជាក់ពីគ្រូពេទ្យជំនាញឬបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ។

ការផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់មិនត្រូវលើសពី៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

ក្នុងករណីបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដោយមូលហេតុត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈនេះ អាចត្រូវបានផ្តល់ឡើងវិញ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៧ .-**

រាល់ការប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតរបស់រដ្ឋបាលរាជធានី ខេត្តទៅតាមប្រភេទអាជីវកម្ម។

**មាត្រា១៨ .-**

ក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវណាមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលបានទទួលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្ដើមហិត្វបត្ថម្ភដោយតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃមានសាលក្រមឬសាលដីកាស្ថាពរ។

ការផ្អាកអាជ្ញាបណ្ណប្រកបអាជីវកម្មក្នុងវិស័យសំណង់មិនត្រូវមានរយៈពេលលើសពី១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចត្រូវបានផ្ដល់ឡើងវិញក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៩ .-**

បុគ្គលដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជានិងមានវិញ្ញាបនបត្រធានារ៉ាប់រង ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។

កម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រង សំដៅធានាការបំពេញកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យារវាងអ្នកប្រកបវិជ្ជាជីវៈឬអ្នកប្រកបអាជីវកម្មនិងអតិថិជនរបស់ខ្លួន។

ចំនួនទឹកប្រាក់អប្បបរមាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០ ._**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការព្យួរ និងការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈនិងអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតឱ្យប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១ ._**

ការស្នើសុំអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបង់កម្រៃសេវា។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិនិងថវិកាថ្នាក់ក្រោមជាតិ។

## ជំពូកទី៧

## ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ និងមន្ទីរពិសោធន៍សំណង់

**មាត្រា២២ ._**

សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវមានការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬតាមស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិ ដោយត្រូវមានបិទឬបោះពុម្ពសញ្ញាស្តង់ដាកម្ពុជានិងត្រូវមានអាជ្ញាបណ្ណប្រើសញ្ញាស្តង់ដាកម្ពុជា។

បែបបទនិងនីតិវិធីនៃការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពនិងប្រភេទនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៣ ._**

ការផលិត ការចែកចាយ ការនាំចូល ការដាក់លក់ ការផ្គត់ផ្គង់ ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ដែលគ្មានបិទសញ្ញាស្តង់ដាកម្ពុជា ឬគ្មានការបញ្ជាក់ទទួលស្គាល់ ឬគ្មានការបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់

ឬផលិតផលសំណង់នោះ តម្រូវឱ្យមានបិទសញ្ញាស្តង់ដាកម្ពុជា ឬការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យអនុលោមភាពនៃការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៤ ._**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍ជាតិសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៥ ._**

មន្ទីរពិសោធន៍សំណង់ក្នុងគោលដៅអាជីវកម្មត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាល ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨

## លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ

**មាត្រា២៦ ._**

រាល់ការងារសាងសង់ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៧ ._**

ការងារសាងសង់ឬរុះរើក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការ មិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៨ .-**

រាល់ការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាតមានដូចខាងក្រោម៖

- សំណង់ទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះគៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ
- សំណង់បម្រើដល់សន្តិសុខជាតិនិងការពារជាតិ។

ប្រភេទនិងទំហំនៃការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៩ .-**

រាល់ការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់មិនតម្រូវឱ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែលការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូលឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវជូនដំណឹងជាមុនទៅអាជ្ញាធរមានសមត្ថកិច្ច។

ប្រភេទនិងទំហំការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣០ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣១ .-**

លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើមិននាំឱ្យបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនោះរួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវ តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

ការអនុវត្តការងារសាងសង់ឬរុះរើចំពោះសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតមិននាំឱ្យម្ចាស់សំណង់រួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

## ជំពូកទី៩
## ការគ្រប់គ្រងគម្រោងប្លង់

**មាត្រា៣២ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម។

គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើសំណង់គ្រប់ប្រភេទ លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាពជាអាទិ៍ ផ្លូវនិងជម្រាលសម្រាប់ផ្លាស់ទី ឧបករណ៍ធ្នាក់ដៃ ជណ្តើរយន្ត បន្ទប់អនាម័យ ចំណតយានយន្តពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា។

អនុលោមភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គម្រោងប្លង់សាងសង់ឬរុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ .-**

ម្ចាស់សំណង់ត្រូវធានាថាការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវបានអនុវត្តត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

មុនការអនុវត្តការងារសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យកែសម្រួលគម្រោងប្លង់ដែលបានទទួលការយល់ព្រមរួចហើយ។

ការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលគម្រោងប្លង់។

លក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥ .-**

រាល់ស្នាដៃរបស់អ្នកសិក្សាគម្រោងប្លង់ដែលមានលក្ខណៈដើមទាំងមូលឬដោយផ្នែកដែលបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាតសាងសង់ ត្រូវបានការពារពីការលួចចម្លងស្របតាមបទប្បញ្ញត្តិជាធរមាន។

គម្រោងប្លង់មួយមិនអាចយកទៅអនុវត្តនៅទីតាំងផ្សេងទៀតដោយគ្មានការអនុញ្ញាតពីអ្នកសិក្សាដែលបានចុះហត្ថលេខាលើគម្រោងប្លង់នោះនិងម្ចាស់សំណង់បានឡើយ។

រាល់ការអនុវត្តគម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មនៅទីតាំងផ្សេងទៀតត្រូវបានហាមឃាត់។ គម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១០

## ការគ្រប់គ្រងការងារសាងសង់ឬស្សីរើ

**មាត្រា៣៦ .-**

រាល់ការងារសាងសង់ឬស្សីរើត្រូវអនុវត្តដោយអ្នកសាងសង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត។

អ្នកសាងសង់មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត លុះត្រាតែអ្នកសាងសង់នោះបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់
- សាងសង់ឬស្សីរើសំណង់ដែលជាលំនៅឋានផ្ទាល់ខ្លួន និង
- សាងសង់ឬស្សីរើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា៣៧ .-**

រាល់ការងារសាងសង់ឬស្សីរើត្រូវអនុវត្តស្របតាម៖

- គម្រោងប្លង់
- បទប្បញ្ញត្តិបច្ចេកទេសសំណង់
- បទប្បញ្ញត្តិជាធរមានដទៃទៀត។

រាល់ការងារសាងសង់ឬស្សីរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវអនុវត្តតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

**មាត្រា៣៨ .-**

រាល់ការងារសាងសង់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន។

លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៩ .-**

អ្នកសាងសង់ត្រូវធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៅការដ្ឋានសំណង់របស់ខ្លួន។

**មាត្រា៤០ .-**

ម្ចាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវផ្ដល់របាយការណ៍ស្ដីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើជូនអាជ្ញាធរមានសមត្ថកិច្ច។

របាយការណ៍ស្ដីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើត្រូវរៀបចំដោយអ្នកសាងសង់និងមានការឯកភាពពីម្ចាស់សំណង់។

បែបបទនិងនីតិវិធីនៃការផ្ដល់របាយការណ៍ស្ដីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៤១ .-**

នៅពេលដំណើរការការដ្ឋាន រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើត្រូវធ្វើរបាយការណ៍និងចេញលិខិតបញ្ជាក់ពីអនុលោមភាពនៃការងារតាមគម្រោងប្លង់ដែលបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ចនិងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

**មាត្រា៤២ .-**

ក្នុងករណីចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីត្រួតពិនិត្យការងារសាងសង់ឬរុះរើ។

ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ បុគ្គលដែលពាក់ព័ន្ធការងារសាងសង់ រាប់បញ្ចូលទាំងអ្នកអភិវឌ្ឍអចលនវត្ថុ អ្នកសាងសង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវផ្ដល់កិច្ចសហការដល់មន្ត្រីត្រួតពិនិត្យសំណង់។

អាជ្ញាធរមានសមត្ថកិច្ចអាចសម្រេចផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើ ឬចាត់វិធានការចាំបាច់ផ្សេងទៀត ក្នុងករណី រកឃើញថាការងារសាងសង់ឬរុះរើមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត។

**មាត្រា៤៣ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការគ្រប់គ្រងនិងត្រួតពិនិត្យការងារសាងសង់ឬរុះរើត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១១

## ការប្រើប្រាស់សំណង់

**មាត្រា៤៤ .-**

ការប្រើប្រាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មុននឹងប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ នោះ។

រាល់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មុននឹងអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់។

**មាត្រា៤៥ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់ក្នុងរយៈពេលណាមួយជាបណ្ដោះអាសន្នបាន ចំពោះសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់ ក្នុងករណីដែលសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់នោះអាចប្រើប្រាស់បានដោយសុវត្ថិភាព។

**មាត្រា៤៦ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៧ .-**

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់រៀងរាល់៥(ប្រាំ)ឆ្នាំម្តងយ៉ាងយូរ។

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់ក្នុងរយៈពេលរៀងរាល់១០(ដប់)ឆ្នាំម្តងយ៉ាងយូរ។

ការត្រួតពិនិត្យនិងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនៃសំណង់ត្រូវធ្វើឡើងសម្រាប់រយៈពេល២(ពីរ)ឆ្នាំម្តង។

បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់តម្រូវឱ្យមានការត្រួតពិនិត្យរៀងរាល់១(មួយ)ឆ្នាំម្តង។ ប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ម្ចាស់សំណង់ឬអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចប្រគល់លទ្ធផលនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល១(មួយ)ខែក្រោយថ្ងៃផុតកំណត់រយៈពេលដែលតម្រូវឱ្យអនុវត្តការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

មាត្រា៤៨ .-

អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ក្នុងករណីមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខឬសណ្តាប់ធ្នាប់សាធារណៈ។

មាត្រា៤៩ .-

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាបន្ទុករបស់ម្ចាស់សំណង់។

ចំពោះអគារសហកម្មសិទ្ធិ ម្ចាស់នៃចំណែកឯកជនទាំងអស់ត្រូវទទួលបន្ទុករួមគ្នាលើរាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ស្របតាមសមាមាត្រទៅនឹងទំហំនៃចំណែកឯកជន។

មាត្រា៥០ .-

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី១២

## សំណង់ដែលមានសភាពគ្រោះថ្នាក់

មាត្រា៥១ .-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យ តាមដានរាល់សំណង់ ទាំងឡាយណាដែលមានសភាពគ្រោះថ្នាក់ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

មាត្រា៥២ .-

ចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនិងអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់ជាអាទិ៍ ហ៊ុំព័ទ្ធ ហាមចូល ហាមប្រើប្រាស់ និងតម្រូវឱ្យរុះរើសំណង់។

រាល់ការចំណាយក្នុងការបញ្ចៀសគ្រោះថ្នាក់ជាបន្ទុករបស់ម្ចាស់សំណង់។

មាត្រា៥៣ .-

កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១៣

## សំណង់ដែលសាងសង់ឬរុះរើដោយគ្មានឬខុសពីលិខិតអនុញ្ញាត

**មាត្រា៥៤ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ការងារសាងសង់ឬរុះរើដែលគ្មានលិខិតអនុញ្ញាត ក្នុងករណីការសាងសង់ឬរុះរើនោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

**មាត្រា៥៥ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាកការងារសាងសង់ឬរុះរើដែលបានធ្វើឡើងខុសពីលិខិតអនុញ្ញាត និងតម្រូវឱ្យម្ចាស់សំណង់កែតម្រូវឱ្យស្របតាមលិខិតអនុញ្ញាត។

**មាត្រា៥៦ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការកែសម្រួលឬរុះរើរាល់សំណង់ដែលសាងសង់ដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការហាមឃាត់រាល់ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

## ជំពូកទី១៤

## អធិការកិច្ចសំណង់

**មាត្រា៥៧ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តែងតាំងមន្ត្រីអធិការកិច្ចសំណង់ ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចសំណង់ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៥៨ .-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសំណង់ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៩ .-**

មន្ត្រីអធិការកិច្ចសំណង់មានភារកិច្ចនិងសិទ្ធិដូចខាងក្រោម៖

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់នេះ
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ
- ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសសំណង់
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចសំណង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៦០ .-**

មន្ត្រីអធិការកិច្ចសំណង់អាចចូលទៅក្នុងការដ្ឋានសំណង់គ្រប់ពេលវេលាក្នុងពេលការដ្ឋានកំពុងដំណើរការ ឬក្នុងអគារនៅក្នុងម៉ោងធ្វើការដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា៦១ .-**

រាល់ប្រតិបត្តិការអធិការកិច្ចសំណង់ក្នុងការពិនិត្យបទល្មើសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចសំណង់អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្តែងឬមិនមានលិខិតអនុញ្ញាតសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសំណង់មានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់ការតាមនីតិវិធី។

## ជំពូកទី១៥
## វិសមិតភាព

**មាត្រា៦២ .-**

មន្ត្រីរាជការដែលមានសមត្ថកិច្ចត្រួតពិនិត្យនិង/ឬសម្រេចលើគម្រោងប្លង់មិនអាចជាអ្នកសិក្សាគម្រោងប្លង់ឬអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ដែលខ្លួនបានសិក្សាឬត្រួតពិនិត្យនិងបញ្ជាក់បានឡើយ។

**មាត្រា៦៣ .-**

មន្ត្រីអធិការកិច្ចសំណង់ មន្ត្រីត្រួតពិនិត្យសំណង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់ មិនអាចជាម្ចាស់សំណង់ ឬជាសហព័ន្ធ ឬជាញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣(បី)ថ្នាក់ ឬញាតិពន្ធក្នុង៣(បី)ថ្នាក់របស់ម្ចាស់សំណង់ ឬជាអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់បានឡើយ។

**មាត្រា៦៤ ._**

ការបំពេញមុខងារជាអ្នកសិក្សាគម្រោងប្លង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់របស់ខ្លួន។

**មាត្រា៦៥ ._**

ការបំពេញមុខងារជាអ្នកសាងសង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់របស់ខ្លួន។

**មាត្រា៦៦ ._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់មិនអាចជាសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ (បី) ថ្នាក់របស់ម្ចាស់សំណង់បានឡើយ។

សមាជិកភាគហ៊ុននៃក្រុមហ៊ុនដែលជាម្ចាស់សំណង់ បុគ្គលិកក្រុមហ៊ុនដែលជាម្ចាស់សំណង់ ឬអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់ មិនអាចបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់សំណង់នោះបានឡើយ។

## ជំពូកទី១៦

## កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៦៧ ._**

កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវមានចែងខអប្បបរមាដូចខាងក្រោម៖

- អត្តសញ្ញាណរបស់ភាគីនៃកិច្ចសន្យា
- ទីតាំង ទំហំ និងប្រភេទការងារ
- តម្លៃនៃកិច្ចសន្យានិងកាលបរិច្ឆេទនិងរបៀបនៃការទូទាត់
- ការធានារបស់ភាគីនៃកិច្ចសន្យាចំពោះការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា
- លក្ខខណ្ឌបច្ចេកទេសនិងលក្ខខណ្ឌសុវត្ថិភាពនៃការងារ
- លក្ខខណ្ឌពាក់ព័ន្ធនឹងការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬឧបករណ៍និងគ្រឿងចក្រសម្រាប់បម្រើឱ្យការងារសាងសង់ឬរុះរើនិងសម្រាប់បំពាក់លើសំណង់
- លក្ខខណ្ឌនៃការកែប្រែនិងរំលាយកិច្ចសន្យា
- ការធានារ៉ាប់រងឬបញ្ញត្តិផ្សេងទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះការខូចខាតដែលបង្កឡើងដោយការងារ
- ការអះអាងអំពីអនុលោមភាពនៃគម្រោងប្លង់ដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើតាមមទប្បញ្ញត្តិជាធរមាន
- កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់ការងារនិងកាលបរិច្ឆេទប្រគល់ទទួល

- លក្ខខណ្ឌពាក់ព័ន្ធនឹងករណីប្រធានសក្តិ

- ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យា។

**មាត្រា៦៨ .-**

ចំពោះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន ខដែលរំលោភបំពានត្រូវទុកជាមោឃៈ។

ខដែលរំលោភបំពាននៅក្នុងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន មានដូចខាងក្រោម៖

១- ខដែលតម្រូវឱ្យម្ចាស់សំណង់ផ្តល់អាណត្តិឱ្យអ្នកម៉ៅការស្វែងរកកម្ចីចាំបាច់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការសាងសង់។

២- ខដែលតម្រូវឱ្យម្ចាស់សំណង់ធ្វើការទូទាត់តម្លៃនៃកិច្ចសន្យាទាំងស្រុងជាមុនដើម្បីឱ្យអ្នកម៉ៅការប្រគល់សំណង់មកម្ចាស់សំណង់។

៣- ខដែលហាមឃាត់ម្ចាស់សំណង់ឬតំណាងមិនឱ្យចូលពិនិត្យក្នុងការដ្ឋាន មុនការទូទាត់តម្លៃនៃកិច្ចសន្យាក្នុងដំណាក់កាលនីមួយៗនិងមុនការប្រគល់ទទួល។

៤- ខដែលតម្រូវឱ្យអ្នកម៉ៅការអនុវត្តការងារសាងសង់ឬរុះរើ តាមលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ដែលលក្ខខណ្ឌបច្ចេកទេសមានការប្រែប្រួលធ្ងន់ធ្ងរខុសពីលក្ខខណ្ឌបច្ចេកទេសនៃគម្រោងសាងសង់ ជួសជុល ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យា។

៥- ខដែលដោះបន្ទុកអ្នកម៉ៅការពីកាតព្វកិច្ចអនុវត្តការងារពេញលេញតាមពេលកំណត់ក្នុងកិច្ចសន្យាដោយទទួលស្គាល់មូលហេតុនៃការយឺតយ៉ាវផ្សេងៗ លើកលែងតែមូលហេតុប្រធានសក្តិនិងមូលហេតុដែលបង្កដោយម្ចាស់សំណង់ផ្ទាល់។

**មាត្រា៦៩ .-**

ភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចដាក់លក្ខខណ្ឌបង្អង់លើកាតព្វកិច្ចឬសិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ដូចខាងក្រោម៖

១- លទ្ធកម្មដីឬសិទ្ធិប្រត្យក្សដែលអនុញ្ញាតឱ្យសាងសង់ ក្នុងករណីដែលម្ចាស់សំណង់ទទួលបានការសន្យាលក់។

២- ការទទួលបានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ឬការអនុញ្ញាតផ្សេងទៀតរបស់អាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវបញ្ជាក់កាលបរិច្ឆេទដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតឱ្យបានច្បាស់លាស់។

៣- ការទទួលបានកម្ចីដើម្បីធ្វើហិរញ្ញប្បទានដល់ការងារសាងសង់ឬរុះរើ។

៤- ការទទួលបាននូវការធានារ៉ាប់រងចំពោះការខូចខាតបង្កដោយការងារសាងសង់ឬរុះរើ។

៥- ការទទួលបាននូវការធានាការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ការដ្ឋានសំណង់។

**មាត្រា៧០.-**

ករណីយកិច្ចសម្រេចការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើដោយគ្មានវិការៈមានដូចខាងក្រោម៖

១- ការងារសាងសង់ត្រូវបានអនុវត្តស្របតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិ និងសេចក្ដីណែនាំជាធរមានដទៃទៀត។

២- ការងារសាងសង់ត្រូវបានអនុវត្តដោយប្រើវិធីសាស្ត្រសមស្របនិងប្រកបដោយសមត្ថភាពជំនាញ។

៣- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវសមស្របតាមមុខងារប្រើប្រាស់អនុលោមតាមគម្រោងប្លង់និងមានគុណភាពត្រឹមត្រូវតាមបទប្បញ្ញត្តិបច្ចេកទេស។

៤- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវតែជាសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ថ្មី លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា។

**មាត្រា៧១.-**

រយៈពេលនៃការធានាចំពោះវិការៈនៃការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ គិតចាប់ពីថ្ងៃប្រគល់ទទួលសំណង់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ១០(ដប់)ឆ្នាំយ៉ាងតិច ចំពោះគ្រឿងផ្គុំសំណង់ធ្វើពីបេតុងសរសៃដែក បេតុងដែក ឬដែក។

ខ- ៥(ប្រាំ)ឆ្នាំយ៉ាងតិច ចំពោះជញ្ជាំងខាងក្រៅ បង្អួច ទ្វារ និងដំបូលអគារ។

គ- ២(ពីរ)ឆ្នាំយ៉ាងតិច ចំពោះការងារផ្នែកអគ្គិសនី ទឹក មេកានិក និងការងារពាក់ព័ន្ធផ្សេងទៀត។

គូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់អាចព្រមព្រៀងគ្នាកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារវែងជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ។

ការកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារខ្លីជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ត្រូវចាត់ទុកជាមោឃៈ។

## ជំពូកទី១៧

## ការធានារ៉ាប់រង

**មាត្រា៧២.-**

អ្នកម៉ៅការសាងសង់ឬរុះរើត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានចំពោះការងារសាងសង់ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ ដើម្បីផ្ដល់សំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិ ការមានរបួស ការមានពិការភាព ឬការបាត់បង់ជីវិត ដែលបង្កឡើងដោយការងារនោះដល់អ្នកដែលប្រតិបត្តិការងារនិងតតិយជន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថាអ្នកម៉ៅការសាងសង់បានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ មុននឹងអនុញ្ញាតឱ្យបើកការដ្ឋាន។

**មាត្រា៧៣.-**

ក្នុងករណីអ្នកម៉ៅការសាងសង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើបន្ត កាតព្វកិច្ចចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានគឺជាបន្ទុករបស់អ្នកម៉ៅការសាងសង់ឬរុះរើនោះ។ ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានត្រូវគ្របដណ្តប់លើប្រតិបត្តិការការងាររបស់អ្នកម៉ៅការសាងសង់ឬរុះរើបន្តទាំងអស់។

ក្នុងករណីម្ចាស់សំណង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើជាមួយអ្នកម៉ៅការសាងសង់ឬរុះរើច្រើនសម្រាប់ប្រតិបត្តិការការងារសាងសង់ឬរុះរើសំណង់តែមួយ អ្នកម៉ៅការសាងសង់ឬរុះរើទាំងអស់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានរៀងៗខ្លួន។

**មាត្រា៧៤.-**

ក្នុងករណីប្រតិបត្តិការការងារសាងសង់ឬរុះរើរបស់គម្រោងអភិវឌ្ឍអចលនវត្ថុ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានជាមួយក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់។

**មាត្រា៧៥.-**

ប្រភេទនិងទំហំសំណង់ដែលតម្រូវឱ្យមានការធានារ៉ាប់រងចំពោះការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១៨

## ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់

**មាត្រា៧៦.-**

អ្នកសិក្សាគម្រោងប្លង់ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ប្រសិនបើគម្រោងប្លង់នៃសំណង់នោះមានវិការៈ លើកលែងតែករណីដែលអ្នកសិក្សាគម្រោងប្លង់អាចបង្ហាញភស្តុតាងថាគម្រោងប្លង់របស់ខ្លួនបានអនុលោមតាមបទប្បញ្ញត្តិតម្រូវជាធរមាន។

**មាត្រា៧៧.-**

នៅក្នុងពេលអនុវត្តការងារសាងសង់ឬរុះរើ ម្ចាស់សំណង់និងអ្នកសាងសង់ឬរុះរើត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការងារសាងសង់ឬរុះរើ ឬការងារគ្រប់គ្រងការដ្ឋានសំណង់នោះមានវិការៈ។

**មាត្រា៧៨.-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់របស់ខ្លួន។

**មាត្រា៧៩.-**

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។

**មាត្រា៨០ ..**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ឬរុះរើ ឬការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ និងការគ្រប់គ្រងសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថាអាចទាមទារសំណងការខូចខាត ឬ
- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីការខូតខាតបានកើតឡើង។

**មាត្រា៨១ ..**

ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់អ្នកដទៃដែលបង្កឡើងដោយវិការៈនៃផលិតផលរបស់ខ្លួន លើកលែងតែផលិតករនោះអាចបង្ហាញភស្តុតាងណាមួយដូចខាងក្រោម៖

១- នៅខណៈដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានដាក់លក់ឬចែកចាយ ចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសពុំអាចរកឃើញវិការៈដែលបង្កឱ្យមានការខូចខាត។

២- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសតម្រូវ។

**មាត្រា៨២ ..**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

១- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងស្របច្បាប់បានដឹងថាអាចទាមទារសំណងការខូចខាត ឬ

២- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវបានប្រគល់លើកដំបូងដោយផលិតករ។ ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់មានសារធាតុបង្កឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស រយៈពេលនេះត្រូវបន្ថែម២០(ម្ភៃ)ឆ្នាំទៀត។

# ជំពូកទី១៩
# ការដោះស្រាយវិវាទក្នុងវិស័យសំណង់
## ផ្នែកទី១
## ការប្តឹងតវ៉ាក្នុងវិស័យសំណង់

**មាត្រា៨៣ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបណ្តឹងត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើបណ្តឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចទទួលបណ្តឹង មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចលើបណ្តឹងតវ៉ាមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៤ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ ត្រូវប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុន មុននឹងប្តឹងទៅតុលាការ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

**មាត្រា៨៥ .-**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចសំណង់អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ ឬអាចប្ដឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្ដឹងតវ៉ា។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្ដឹងអាចប្ដឹងទៅតុលាការក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

## ផ្នែកទី២

## ការដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិបុគ្គលក្នុងវិស័យសំណង់ និងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៨៦ .-**

បុគ្គលដែលរងការខូចខាតឬមានការបារម្ភជាក់ស្ដែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ក្នុងវិស័យសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួល មុននឹងប្ដឹងទៅតុលាការ។

សំណើសុំសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលរងផលប៉ះពាល់។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយភាគីនៃវិវាទក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់សម្រេចបដិសេធសំណើសុំសម្រុះសម្រួល គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ។ ក្នុងករណីនេះម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់មិនអនុវត្តនីតិវិធីសម្រុះសម្រួលក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីភាគីវិវាទពុំអាចព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទដើម្បីបញ្ចប់វិវាទតាមការសម្រុះសម្រួលរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៧ .-**

ភាគីឬគូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចធ្វើសំណើមកគណៈកម្មការដោះស្រាយវិវាទសំណង់ ដើម្បីសម្រុះសម្រួលនិងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើនោះ។

សំណើសុំការសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០( សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលវិវាទបានកើតឡើង។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយគូភាគីនៃវិវាទនិងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០( សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណើសុំការសម្រុះសម្រួល។

ភាគីនៃវិវាទអាចសម្រេចចិត្តឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់នៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួល ប៉ុន្តែភាគីនៃវិវាទត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការដោះស្រាយវិវាទសំណង់អំពីការឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ មុននឹងប្តឹងទៅតុលាការ។

**មាត្រា៨៨ .-**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវផ្អាក ក្នុងករណីមានសំណើសុំសម្រុះសម្រួលទៅគណៈកម្មការដោះស្រាយវិវាទសំណង់។

**មាត្រា៨៩ .-**

គណៈកម្មការដោះស្រាយវិវាទសំណង់មានរចនាសម្ព័ន្ធដូចតទៅៈ

១- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ជាតិ

២- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់រាជធានី ខេត្ត

៣- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE * MINISTRE DU PALAIS ROYAL

## ជំពូកទី២០
## ទោសប្បញ្ញត្តិ

**មាត្រា៩០ .-**

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ការពិន័យអន្តរការណ៍ ការហាមឃាត់ការប្រកបវិជ្ជាជីវៈ ការបង្ខំឱ្យរុះរើនិង/ឬសាងសង់ឡើងវិញឱ្យដូចសភាពដើម ទោសពិន័យជាប្រាក់និងទោសដាក់ពន្ធនាគារ។

**មាត្រា៩១ .-**

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចដូចមានចែងក្នុងមាត្រានេះជូនដល់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៩២ .-**

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចសំណង់អាចកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសក្នុងវិស័យសំណង់។

**មាត្រា៩៣ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះជនណាដែលមិនមែនជាវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតក្នុងវិស័យសំណង់ដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៤ ._**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ដោយមិនបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៥ ._**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យដោយគ្មានអាជ្ញាបណ្ណ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៦ ._**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះជនណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានលិខិតអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៧ ._**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៣(បី)ខែ និងពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចជាលើកទីពីររបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

**មាត្រា៩៨ ._**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលបានប្រើឬបំពាក់ក្នុងការសាងសង់នូវសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដាណាមួយជាកំណត់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS

**មាត្រា៩៩ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសិក្សាគម្រោងប្លង់ណាដែលបានសិក្សាគម្រោងប្លង់ដោយមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយការអនុវត្តតាមគម្រោងប្លង់នោះបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០០ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសាងសង់ដែលបានសាងសង់ឬរុះរើមិនអនុលោមតាមគម្រោងប្លង់និងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០១ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៣០ ០០០ ០០០(សាមសិបលាន)រៀលទៅ៦០ ០០០ ០០០(ហុកសិបលាន)រៀល ចំពោះអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលបានបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់ឬរុះរើថាត្រឹមត្រូវ ដែលតាមជាក់ស្តែង គម្រោងប្លង់ឬការងារសាងសង់ឬរុះរើនោះមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និង/ឬតាមគម្រោងប្លង់ដែលបានអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០២ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្មនូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០៣ ..**

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យមានការកាត់អវយវៈឬនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យមានមនុស្សស្លាប់។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា១០៤ .-**

ត្រូវផ្តន្ទាទោសដូចមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣ នៃច្បាប់នេះ កាលបើអំពើល្មើសដូចមានចែងក្នុងមាត្រាទាំងនោះ ប្រព្រឹត្តដោយនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់។

**មាត្រា១០៥ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀលទៅ៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល ចំពោះនីតិបុគ្គលណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានអាជ្ញាបណ្ណ។

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៦០ ០០០ ០០០(ហុកសិបលាន)រៀលទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ៖

១. ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២. ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។

៣. ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤. ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ)នៃក្រមព្រហ្មទណ្ឌ។

៥. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

៦. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី២១

## អន្តរប្បញ្ញត្តិ

**មាត្រា១០៦ .-**

ក្នុងរយៈពេល២(ពីរ)ឆ្នាំ ក្រោយច្បាប់នេះចូលជាធរមាន ម្ចាស់សំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ត្រូវមកដាក់ពាក្យស្នើសុំ

វិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីសំណង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ក្នុងរយៈពេលកំណត់ខាងលើ រាល់ទោសប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវបន្តអនុវត្តចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន។

**មាត្រា១០៧ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់និងសាធារណជន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់នេះចូលជាធរមាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១០៨ .-**

ក្រោយច្បាប់នេះចូលជាធរមានក្នុងរយៈពេល២(ពីរ)ឆ្នាំ មន្ទីរពិសោធន៍សំណង់ដែលបាននិងកំពុងប្រតិបត្តិការឬប្រកបអាជីវកម្មត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណប្រកបអាជីវកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១០៩ .-**

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចតម្រូវឱ្យអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់តម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចដកយកប្រាក់តម្កល់វិញនៅពេលឈប់ប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មនោះ និងនៅពេលអាជ្ញាបណ្ណផុតសុពលភាពឬត្រូវបានដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច។

អ្នកទទួលសេវាពីអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ដែលទទួលរងការខូចខាតមានឯកសិទ្ធិលំដាប់ទី២បន្ទាប់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិត ចំពោះប្រាក់តម្កល់ដូចមានចែងក្នុងកថាខណ្ឌខាងលើ។

លក្ខខណ្ឌនិងនីតិវិធីនៃការតម្កល់ប្រាក់ ការដកប្រាក់តម្កល់ និងចំនួនទឹកប្រាក់អប្បបរមាដែលត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ទៅតាមប្រភេទនៃអាជ្ញាបណ្ណដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី២២

អវសានបញ្ញត្តិ

**មាត្រា១១០ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា១១១ ..**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្ដិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៩

នស.រកម.១១១៩.០១៦

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

## ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីសំណង់

## សទ្ទានុក្រម

១. **ការងារសំណង់**(construction work) សំដៅដល់ការងារសិក្សាគម្រោងប្លង់ ការងារវាស់វែង ការងារសាងសង់(building work) ការងាររុះរើ ការងារគ្រប់គ្រងការដ្ឋាន ការងារត្រួតពិនិត្យនិងបញ្ជាក់ ការងារសិក្សាពិសោធ ការងារគ្រប់គ្រងគម្រោងសាងសង់ ឬការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

២. **ការងារសិក្សាគម្រោងប្លង់**(design work) សំដៅដល់ការងារគូរប្លង់ ការងារសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យសម្រាប់ការងារស្ថាបត្យកម្មនិងវិស្វកម្ម ការងារផែនការ ការងាររៀបចំបញ្ជីប៉ាន់តម្លៃ ការងាររៀបចំសេចក្ដីណែនាំបច្ចេកទេស និងការងារគូរប្លង់លម្អិត។

៣. **ការងារវាស់វែង**(surveying work) សំដៅដល់ការសិក្សានិងវិភាគទិន្នន័យនិងព័ត៌មានដែលបានពីការវាស់ ការស្ទង់ ការធ្វើថានលេខា និងការសង្កេត សម្រាប់បម្រើដល់ការធ្វើផែនការ ការសិក្សាគម្រោងប្លង់ និងការងារសាងសង់។

៤. **ការងារសាងសង់**(building work) សំដៅដល់ការងារដី ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ និងការដំឡើង។

៥. **ការងារជួសជុល**(repair work) សំដៅដល់ការជួសជុលផ្នែកណាមួយនៃសំណង់ឬការជួសជុលទាំងស្រុងដែលមានការខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្ដូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ និងការកែលម្អ ការបំពាក់សម្ភារៈបរិក្ខារផ្នែកផ្សេងទៀតនៅខាងក្នុងដោយរក្សាសោភណភាព ទ្រង់ទ្រាយដើម និងមិនប៉ះពាល់ដល់គ្រឿងផ្គុំសំណង់។

៦. **ការងារកែប្រែ**(modification work) សំដៅដល់ការផ្លាស់ប្ដូរមុខងារទ្រង់ទ្រាយទាំងស្រុងឬផ្នែកណាមួយនៃសំណង់។

៧. **ការងាររុះរើ**(demolition work) សំដៅដល់ការងារដោះឬដកចេញនូវចំណែកណាមួយ ឬដកចេញសំណង់ទាំងមូល ឬការងារវាយកម្ទេចសំណង់។

៨. **ការងារត្រួតពិនិត្យនិងបញ្ជាក់**(certification work) សំដៅដល់ការត្រួតពិនិត្យ ការវិភាគ និងការបញ្ជាក់ លើគម្រោងប្លង់ ការគណនា សេចក្ដីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់ឬរុះរើ និងប្រតិបត្តិការការងារសាងសង់ឬរុះរើ អំពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីធានាសុវត្ថិភាព សុខុមាលភាពក្នុងការសាងសង់ឬរុះរើ និងក្នុងការប្រើប្រាស់សំណង់។

៩. **ការងារសិក្សាពិសោធ**(testing work) សំដៅដល់ការសិក្សា ការវិភាគ និងការងារគណនាផ្នែកភូគព្ភសាស្ត្រ ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកឧបករណ៍និងគ្រឿងចក្រសំណង់ និងផ្នែកសម្ភារៈ បរិក្ខារ និងផលិតផលសំណង់។

១០. **ការងារគ្រប់គ្រងគម្រោងសាងសង់**(construction project management) សំដៅដល់ការងារដែលអ្នកគ្រប់គ្រងគម្រោងសាងសង់អនុវត្តក្នុងនាមម្ចាស់សំណង់ ដើម្បីធានាឱ្យគម្រោងសាងសង់ឬរុះរើដំណើរការទៅប្រកបដោយប្រសិទ្ធភាពលើពេលវេលា តម្លៃ គុណភាព និងសុវត្ថិភាព។

**១១. ការដកហូត**(revocation) សំដៅដល់ការសម្រេចនិរាករអាជ្ញាបណ្ណឬលិខិតអនុញ្ញាតក្នុងវិស័យសំណង់ដោយអាជ្ញាធរឬមន្ត្រីមានសមត្ថកិច្ច។

**១២. កិច្ចសន្យាម៉ៅការសាងសង់**(construction contract) សំដៅដល់កិច្ចសន្យារវាងម្ចាស់សំណង់និងអ្នកសាងសង់ និងកិច្ចសន្យារវាងអ្នកសាងសង់និងអ្នកម៉ៅការសាងសង់ឬរុះរើបន្តដើម្បីអនុវត្តការងារសាងសង់ឬរុះរើ។

**១៣. គម្រោងប្លង់**(design document) សំដៅដល់ឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការងារសំណង់ មានជាអាទិ៍ ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ ប្លង់ប្រព័ន្ធមេកានិក ប្លង់ប្រព័ន្ធអគ្គិសនី ប្លង់ប្រព័ន្ធទឹកស្អាត ទឹកកខ្វក់ ប្លង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ ឬប្លង់ ឯកសារ និងសេចក្តីណែនាំបច្ចេកទេសដទៃទៀត សម្រាប់ការងារសាងសង់ឬរុះរើនិងការប្រើប្រាស់សំណង់។

**១៤. តម្លៃនៃកិច្ចសន្យា**(contract fee) សំដៅដល់កម្រៃឬតម្លៃផ្សេងទៀតដែលម្ចាស់សំណង់ត្រូវបង់ជូនអ្នកសាងសង់តាមការកំណត់ក្នុងកិច្ចសន្យាសាងសង់។

**១៥. ប្រធានសក្តិ**(force majeure) សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

**១៦. បទប្បញ្ញត្តិបច្ចេកទេសសំណង់**(building technical regulations) សំដៅដល់បទដ្ឋានបច្ចេកទេស លក្ខខណ្ឌបច្ចេកទេស វិធានបច្ចេកទេសដែលមានលក្ខណៈបញ្ញា សម្រាប់អនុវត្តការងារសំណង់ដែលត្រូវបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច។

**១៧. បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម**(spatial and urban regulations) សំដៅដល់បទប្បញ្ញត្តិដែលមានចែងក្នុងបទដ្ឋានគតិយុត្តរៀបចំដែនដីនិងនគរូបនីយកម្ម ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

**១៨. បន្ទុក**(load) សំដៅដល់ទម្ងន់ សំពាធ ឬកម្លាំងទាំងឡាយដែលសង្កត់ឬមានឥទ្ធិពលលើគ្រឿងផ្គុំសំណង់។

**១៩. បរិក្ខារសំណង់**(construction equipment) សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើងដើម្បីប្រើប្រាស់ឬបំពាក់ភ្ជាប់នឹងសំណង់ដើម្បីបង្កើនគុណភាព ផាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែអុបទិក ឡាវ៉ាបូ រ៉ូប៊ីណេ ជើងងូតទឹក ម៉ាស៊ីនត្រជាក់ ជណ្តើរយន្ត ទុយោ។

**២០. ផលិតផលសំណង់**(construction product) សំដៅដល់ផលិតផលសម្រេចឬពាក់កណ្តាលសម្រេចដែលកើតចេញពីការបង្កើតឬការផលិតដោយប្រើប្រាស់សម្ភារៈសំណង់និងសម្រាប់យកទៅប្រើជាគ្រឿងផ្គុំសំណង់ មានជាអាទិ៍ ក្បឿង ឥដ្ឋ បាយអរ បេតុង សសរ ជញ្ជាំង ជហ្វា កម្រាលបេតុង បំពង់លូបេតុង ម្នាងសិលា ស័ង្កសី ស្មាតបត ក្រដាសជញ្ជាំង ថ្នាំលាប ជ័រស្អិតការ៉ូ។

**២១. ផលិតករ**(producer) សំដៅដល់អ្នកផលិត អ្នកនាំចូល ឬបុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករឬជាអ្នកលក់។

**២២- ម្ចាស់សំណង់**(construction owner) សំដៅដល់កម្មសិទ្ធិករនៃសំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលបានសាងសង់នៅលើដីរបស់ខ្លួនផ្ទាល់ឬនៅលើដីរបស់អ្នកដទៃដោយមានការអនុញ្ញាតពីម្ចាស់ដី ឬអ្នកជួលអចិន្ត្រៃយ៍ដែលបានសាងសង់លើដីរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍។

**២៣- មន្ត្រីត្រួតពិនិត្យសំណង់**(construction controller) សំដៅដល់មន្ត្រីជំនាញដែលត្រូវបានចាត់តាំងដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះត្រួតពិនិត្យការងារសាងសង់ឬរុះរើនិងត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

**២៤- វិការៈ**(defect) សំដៅដល់ការប្រែប្រួលចាកពីភាពប្រក្រតី។

**២៥- វិញ្ញាបនបត្រប្រើប្រាស់សំណង់**(occupancy certificate) សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

**២៦- សំណង់ដែលមានសភាពគ្រោះថ្នាក់**(dangerous building) សំដៅដល់សំណង់ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

**២៧- សំណង់**(construction) សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការ្យទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់។

**២៨- សម្ភារៈសំណង់**(construction material) សំដៅដល់វត្ថុធាតុដើមសម្រាប់ធ្វើការលាយ ផ្សំ ផ្គុំ ឬប្រើប្រាស់ជាគ្រឿងផ្គុំសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ មានជាអាទិ៍ ខ្សាច់ ថ្ម ក្រួស ស៊ីម៉ងត៍ ដែក កញ្ចក់ ដីឥដ្ឋ សេរ៉ាមិក ឈើ។

**២៩- អ្នកសាងសង់**(builder) សំដៅដល់អ្នកទទួលម៉ៅការសាងសង់ឬរុះរើ អ្នកសាងសង់ឬរុះរើតាមជំនាញ ឬក្រុមជាងសំណង់។

**៣០- អ្នកអភិវឌ្ឍអចលនវត្ថុ**(real estate developer) សំដៅដល់ពាណិជ្ជករ វិនិយោគិន ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មសាងសង់សំណង់សម្រាប់លក់ដើម្បីស្វែងរកផលចំណេញ។

**៣១- អាជ្ញាធរមានសមត្ថកិច្ច**(competent authority) សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**៣២- អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់**(construction professional) សំដៅដល់ស្ថាបត្យករឬវិស្វករដែលបានចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជាឬគណៈវិស្វករកម្ពុជា ឬអ្នកជំនាញដែលបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យសំណង់។

**៣៣- អ្នកជំនាញក្នុងវិស័យសំណង់**(tradesperson) សំដៅដល់អ្នកបច្ចេកទេសសំណង់(កម្មករជំនាញ/ជាង) ដែលបានទទួលការបណ្តុះបណ្តាលដោយសាលាបច្ចេកទេសជំនាញពាក់ព័ន្ធឬដែលមានជំនាញនិងបទពិសោធក្នុងការអនុវត្តការងារសាងសង់ឬអ្នកជំនាញក្នុងវិស័យសំណង់ដែលពុំទាន់មានបង្កើតគណៈវិជ្ជាជីវៈ។

៣៤  **អ្នកគ្រប់គ្រងសំណង់**(building manager)  សំដៅដល់អ្នកដែលបានទទួលអាណត្តិឬសិទ្ធិគ្រប់គ្រងសំណង់ពីម្ចាស់សំណង់ក្នុងរយៈពេលកំណត់។